**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

ROYAL UNIVERSITY OF LAW AND ECONOMIC

# សារណាបញ្ចប់ការសិក្សា

# ដំណើរការនៃការរៀបចំនិងការប្រព្រឹត្តទៅ

# នៃអង្គការអាស៊ាន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **សួ ខាសនា**

**ក្ញុយ ម៉េងហ័រ**

ណែនាំដោយ

លោក **អ៊ុំ រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ស្ទួ ទាសនា** និង ខ្ញុំបាទឈ្មោះ **គុយ ម៉េងហ័រ** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត៖

- សូមលើកអញ្ជលីលំឱនកាយវាចារចិត្តគោរពដល់ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈទាំងស្មារតី និងថវិកាឲ្យកូនបានសិក្សារៀនសូត្ររហូតដល់បច្ចុប្បន្ននេះ។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យនេះនិងបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- លោក **អ៊ឹង រដ្ឋា** ដែលជាលោកគ្រូណែនាំដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀនផ្តល់ការណែនាំ ថែមទាំងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ។
- ថ្នាក់ដឹកនាំបុគ្គលិកសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំបង្រៀន និងយកចិត្តទុកដាក់មកលើនិស្សិតគ្រប់រូប។

យើងខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀតចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញទាំងឡាយដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោក ក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមកនេះ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោកលោកស្រី និងសាស្ត្រាចារ្យទាំងអស់ រួមទាំងមិត្តអ្នកអានទាំងអស់សូមប្រកបតែជោគជ័យគ្រប់ភារៈកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទឈ្មោះ **សួ វាសនា** និង ខ្ញុំបាទឈ្មោះ **កុយ ម៉េងហ័រ** សូមធ្វើការគោរពលំឱនកាយទៅសាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបជាទីរាប់អាន។

ក្នុងនាមយើងខ្ញុំជានិស្សិតនៅសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្តីពី "**ដំណើរការនៃរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការអាស៊ាន**" នេះឡើងមកដោយត្រូវបានទទួលនូវការគាំទ្រនិងមានការជួយលើកទឹកចិត្តបង្ហាត់បង្ហាញ និងកែតម្រូវយ៉ាងពេញទំហឹងពីសំណាក់លោក **អ៊ឹម រដ្ឋា** ដែលលោកជាគ្រូបង្រៀននៅក្នុងសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណានេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់ហើយក៏ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ ដែលបំពេញឱ្យសេចក្តីត្រូវការជាចាំបាច់សម្រាប់អ្នកស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតពេលបច្ចុប្បន្ននេះ។

ម្យ៉ាងវិញទៀត យើងខ្ញុំក៏សូមអភ័យទោសផងដែលនូវរាល់កង្វះខ្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះ យើងខ្ញុំរងចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់លោកសាស្ត្រាចារ្យនិងមិត្តអ្នកអានទាំងអស់គ្នាគ្រប់វិនាទី។

ជាទីចុងបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនឹងសូមជូនពរដល់អ្នកអានគ្រប់រូបជួបប្រទះនូវសុខដុមរមនារុងរឿងថ្កុំថ្កើងនិងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**អក្សរកាត់** ........ iv

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការដោះស្រាយ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី ១៖ ប្រវត្តិនៃការកកើតអង្គការអាស៊ាន** ........ ៤

**ផ្នែកទី១. ប្រវត្តិនៃអង្គការមុនការកកើតអង្គការអាស៊ាន** ........ ៤

១. អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ........ ៤

២. សមាគមអាស៊ីអាគ្នេយ៍ ........ ៥

៣. អង្គការម៉ាហ្វីលីនដូ ........ ៧

**ផ្នែកទី២. ដំណើរការនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍** ........ ៨

១. សេចក្តីថ្លែងការណ៍អាស៊ានទីក្រុងបាងកក១៩៦៧ ក្នុងការបង្កើតអាស៊ាន ........ ៨

២. ដំណើរការវិវត្តនៃធម្មនុញ្ញអាស៊ាន ........ ១០

៣. ដំណើរការនៃការពង្រីកខ្លួនរបស់អាស៊ាន ........ ១៣

**ជំពូកទី២៖ ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អាស៊ាន** ........ ១៦

**ផ្នែកទី១. កិច្ចប្រជុំកំពូលអាស៊ាន** ........ ១៦

១. សមាសភាពរបស់កិច្ចប្រជុំកំពូលអាស៊ាន ........ ១៦

២. តួនាទីភារកិច្ចរបស់កិច្ចប្រជុំកំពូលអាស៊ាន ........ ១៧

**ផ្នែកទី២. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន** ........ ២៣

១. សមាសភាពរបស់កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន ........ ២៣

២. តួនាទីភារកិច្ចរបស់កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន ........ ២៣

៣. កិច្ចប្រជុំពិសេសនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន ........ ២៤

**ផ្នែកទី៣. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន** ........ ២៥
១. សមាសភាពរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ........ ២៥
២. តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ........ ២៥
**ផ្នែកទី៤. ក្រុមប្រឹក្សាសម្របសម្រួលសហគមន៍អាស៊ាន** ........ ២៦
១. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាន ........ ២៦
ក. សសរស្តម្ភសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ........ ២៦
ខ. សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន ........ ២៧
គ. សសរស្តម្ភសហគមន៍សង្គម-វប្បធម៌អាស៊ាន ........ ២៨
**ផ្នែកទី៥. ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន** ........ ២៨
១. សមាសភាពរបស់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន ........ ២៨
២. តួនាទីភារកិច្ចរបស់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន ........ ២៩
**ផ្នែកទី៦. លេខាធិការដ្ឋានអាស៊ាន** ........ ២៩
១. អគ្គលេខាធិការ ........ ២៩
២. អគ្គលេខាធិការរង និងមន្ត្រីបុគ្គលិក ........ ៣១
៣. ទីតាំងរបស់លេខាធិការដ្ឋានអាស៊ាន ........ ៣៣
**ជំពូកទី៣៖ ទំនាក់ទំនងរវាងអាស៊ានជាមួយ និងមជ្ឈដ្ឋានខាងក្រៅ** ........ ៣៤
**ផ្នែកទី១. សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍** ........ ៣៤
១. ទំនាក់ទំនងរវាងអាស៊ាន និងអន្តរជាតិ ........ ៣៥
**ផ្នែកទី២.ប្រតិបត្តិការដឹកនាំកិច្ចប្រជុំអាស៊ាននិងប្រទេសជាដៃគូអន្តរជាតិ** ........ ៣៥
១. កិច្ចប្រជុំអាស៊ានបូក១ ........ ៣៥
២. កិច្ចប្រជុំអាស៊ានបូក២ ........ ៣៨
៣. កិច្ចប្រជុំអាស៊ានបូក៣ ........ ៣៨
៤. កិច្ចប្រជុំអាស៊ានបូក៦ ........ ៤១
៥. កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ឬអាស៊ានបូក៨ ........ ៤៣
ក. កិច្ចប្រជុំមន្ត្រីការបរទេសនៃកិច្ចប្រជុំអាស៊ីបូព៌ា ........ ៤៥
ខ. កិច្ចប្រជុំឧត្តមមន្ត្រីនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ........ ៤៦
គ. កិច្ចប្រជុំឯកអគ្គរាជ/រដ្ឋទូតអាស៊ីបូព៌ាប្រចាំហ្សាការតា ........ ៤៦

**ផ្នែកទី៣. វេទិកានៅក្នុងតំបន់អាស៊ាន** ........ ៤៧
១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃវេទិកាតំបន់អាស៊ាន ........ ៤៧
២. កិច្ចប្រជុំឧត្តមមន្ត្រីនៃវេទិកាតំបន់អាស៊ាន ........ ៤៨
**ផ្នែកទី៤. កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក** ........ ៤៩
១. កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក ........ ៤៩
២. កិច្ចប្រជុំក្រុមការងាររដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក ........ ៥០
**ផ្នែកទី៥. កិច្ចប្រជុំរវាងអាស៊ាន និងក្រុមតំបន់ផ្សេងៗ** ........ ៥០
១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីនៃក្រុមតំបន់ផ្សេងៗ ........ ៥១
២. កិច្ចប្រជុំរវាងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាននិងតំបន់ផ្សេងៗ ........ ៥១
**សេចក្តីសន្និដ្ឋាន** ........ ៥៣
**អនុសាសន៍** ........ ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| ACC | = ASEAN Coordinating Council |
| | ( ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ) |
| ADMM-Plus | = ASEAN Defence Minister’s Meeting-Plus |
| | ( កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក ) |
| ADMM Plus WG | = ASEAN Defence Ministerial Meeting Plus Working Group Plus |
| | ( កិច្ចប្រជុំក្រុមការងាររដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក ) |
| AEC | = ASEAN Economic Community-AEC |
| | ( សហគមន៍សេដ្ឋកិច្ចអាស៊ាន ) |
| AMM | = ASEAN Foreign Ministers Meeting |
| | ( កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន ) |
| AMR | = ASEAN Foreign Ministers Retreat |
| | ( កិច្ចប្រជុំពិសេសនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន ) |
| ASA | = Association of Southeast Asia |
| | ( សមាគមអាស៊ីអាគ្នេយ៍ ) |
| ASC | = ASEAN Security Community |
| | ( សហគមន៍នយោបាយ-សន្តិសុខអាស៊ាន ) |
| ASCC | = ASEAN Socio-Cultural Community |
| | ( សហគមន៍សង្គម-វប្បធម៌អាស៊ាន ) |
| ASEAN | = Association of Southeast Asian Nations |
| | ( សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ) |
| ASMB | = ASEAN Sectoral Ministerial Bodies |
| | ( ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន ) |
| CPR | = Committee of Permanent Representatives to ASEAN |
| | ( គណៈកម្មាធិការតំណាងអចិន្ត្រៃប្រចាំអាស៊ាន ) |
| EAS | = East Asia summit |
| | ( កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ) |

| | |
|---|---|
| SEATO | = Southeast Asia Treaty Organization<br>(អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍) |
| TAC | = Treaty of Amity and Cooperation in Southeast Asia<br>( សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ) |

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាក់ស្ដែងនៅក្នុងបណ្ដាប្រទេសជាច្រើននៅក្នុងពិភពលោកនេះ គឺមានប្រទេសជាច្រើនបានខិតខំរួបរួមគ្នាសាមគ្គីគ្នាតាមរយៈការបង្កើតអង្គការសមាគមបង្កើតឱ្យមានសន្ធិសញ្ញាជាច្រើន ដើម្បីឱ្យបណ្ដាលប្រទេសនៅជុំវិញពិភពលោកមានការគោរពតាមដើម្បីជៀសវៀងនូវរាល់ជម្លោះនានារវាងប្រទេសមួយ និងប្រទេសមួយទៀត ហើយមិនតែប៉ុណ្ណោះការបង្កើតអង្គការសមាគមការបង្កើតសន្ធិសញ្ញាបានផ្ដល់ផលប្រយោជន៍ជាច្រើននៅជុំវិញពិភពលោកនេះដូចជាបានជួយឱ្យប្រទេសនៅក្នុងពិភពលោកមានសន្តិភាព សន្តិសុខសង្គមមានទំនាក់ទំនងទៅវិញទៅមករវាងប្រទេសមួយនឹងប្រទេសមួយទៀត ដែលអាចធ្វើឱ្យមានភាពងាយស្រួលក្នុងការចែករំលែកវប្បធម៌រវាងគ្នាទៅវិញទៅមក។ លើសពីនេះ ទៅទៀតការដែលបណ្ដាប្រទេសនៅជុំវិញពិភពលោកបាននាំគ្នាគោរពតាមគោលការណ៍របស់អង្គការសមាគមសន្ធិសញ្ញានិងមានការគោរពគ្នាទៅវិញទៅមកនោះ គឺជឿជាក់ថាប្រទេសនីមួយៗនៅជុំវិញពិភពលោក នឹងទទួលបានការអភិវឌ្ឍតាមរយៈការចូលរួមគ្នាពិភាក្សា ការចូលរួមប្រជុំកំពូលរបស់សមាគមអង្គការនិងសន្ធិសញ្ញាផ្សេងៗទៀតដែលបានបង្កើតឡើង។ បើគេសង្កេតមើលនៅតំបន់អាស៊ីអាគ្នេយ៍វិញ គឺជាតំបន់ដែលមានការអភិវឌ្ឍខ្លាំងបំផុតនាពេលបច្ចុប្បន្ន ដែលជំរុញឱ្យប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បាននាំគ្នាខិតខំបង្កើតសមាគមមួយ ដែលមានឈ្មោះថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា “អាស៊ាន” ដែលមានបណ្ដាប្រទេសនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍បានចូលរួមសហការសាមគ្គីគ្នាដើម្បីជួយឱ្យប្រទេសដែលជាសមាជិករបស់អង្គការអាស៊ានមួយនេះ មានទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមកតាមរយៈការចូលរួមកិច្ចប្រជុំកំពូលផ្សេងៗ ដែលរាល់កិច្ចប្រជុំទាំងនោះបានផ្ដល់ផលប្រយោជន៍ និងដំណោះស្រាយបញ្ហាផ្សេងៗរួមទាំងការចែករំលែកយោបល់គ្នាទៅវិញទៅមកពិភាក្សាគ្នាការអភិវឌ្ឍខាងសេដ្ឋកិច្ច និងរួមគ្នាជួយគ្នាបង្កើតផែនការថ្មីៗ ដែលជួយឱ្យសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មានការរីកចម្រើនកាន់ប្រសើរជាងនេះ ទៀត។ ជាពិសេស រាល់ការសម្រេចចិត្តសំខាន់ៗដែលពាក់ព័ន្ធនឹងជោគវាសនារបស់សមាគមអាស៊ានគឺសុទ្ធតែត្រូវធ្វើដោយមានកិច្ចប្រជុំកំពូលអាស៊ានដែលប្រព្រឹត្តទៅជារៀងរាល់ឆ្នាំនៅប្រទេសដែលមានតួនាទីជាប្រធានអាស៊ាន។ ជាងនេះ ទៅទៀតសមាគមអាស៊ាននៅមានកិច្ចប្រជុំដទៃទៀតដូចជាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកជាដើម។ ហើយរាល់ការសម្រេចចិត្តសំខាន់ៗ ដែលពាក់ព័ន្ធនឹងជោគវាសនារបស់សមាគមអាស៊ាន គឺត្រូវយោងលើគោលការណ៍កុងសង់ស៊ីស គឺមានន័យថាមានការសម្រេចជាឯកច្ឆន ដែលនេះជាគោលការណ៍គ្រឹះរបស់អាស៊ានទើបធ្វើការសម្រេចចិត្តបាន។

បើទោះបីពេលខ្លះមានបញ្ហាប្រឈមក្នុងសមាគមអាស៊ានក្ដីក៏សមាគមអាស៊ានបានខិតខំអនុវត្តគោលការណ៍នេះ និងបានដោះស្រាយរាល់បញ្ហាដែលកើតមានបានយ៉ាងប្រសើរបំផុត។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ដោយមើលឃើញថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ គឺជាសមាគមដ៏ធំមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានបណ្តាប្រទេសជាច្រើនដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានចូលរួមជាសមាជិករបស់សមាគមអាស៊ាន។ ដោយសារគេសង្កេតឃើញថាអង្គការតំបន់នេះ បានបង្កើតនូវគោលការណ៍ច្បាស់លាស់បញ្ចៀសកុំឱ្យមានសង្គ្រាម និងបានបង្កើនសន្តិភាពការចេះសាមគ្គីភាពរវាងគ្នានិងគ្នាមានទំនាក់ទំនងល្អជាមួយគ្នាការចេះចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកដូច្នេះហើយ គឺសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះមានសារៈសំខាន់ណាស់ ដែលប្រទេសដែលជាសមាជិកត្រូវការគោរពគោលការណ៍ជាចាំបាច់។ ប៉ុន្តែយើងក៏ត្រូវយល់ដឹងឱ្យបានច្បាស់ផងដែលពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះថា តើអ្វីទៅជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា “អាស៊ាន”? តើដំណើរការនៃការរៀបចំនិងការប្រព្រឹត្តទៅរបស់សមាគមមួយនេះមានដំណើរការយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណង នៃការសិក្សាស្រាវជ្រាវមួយនេះដើម្បីធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើមូលហេតុកត្តាផ្សេងដែលពាក់ព័ន្ធទៅ និងការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា “អាស៊ាន” ដែលបានបង្កើតឡើងដោយប្រទេសដែលមានវត្តមាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានគោលបំណងទាំងនេះរួមមានដូចជា៖

- ស្វែងយល់អំពីប្រវត្តិនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា “អាស៊ាន”
- ស្វែងយល់អំពីគោលបំណង និងវត្ថុបំណងក្នុងការបង្កើអាស៊ាន
- ស្វែងយល់អំពីការតាក់តែងធម្មនុញ្ញរបស់អាស៊ាន
- ស្វែងយល់អំពីដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅនៃអាស៊ាន
- ស្វែងយល់អំពីយន្តដឹកនាំទំនាក់ទំនងអាស៊ានរវាងរដ្ឋជាសមាជិក និងអន្តរជាតិដែលបានចូលរួមសហការជាមួយអាស៊ាន
- ស្វែងយល់អំពីកំណើនសេដ្ឋកិច្ច វឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌ក្នុងតំបន់អាស៊ាន
- ធ្វើការសន្និដ្ឋាន ផ្តល់អនុសាសន៍ដើម្បីអាចធ្វើការកែតម្រូវចំពោះបញ្ហា និងចងក្រងទុកជាឯកសារសម្រាប់ជាស្នាដៃ និងចំណុចចាប់ផ្តើមនៃការស្រាវជ្រាវបន្តសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ក្នុងការជ្រាវស្រាវសរសេរសារណាមួយនេះ គឺមានទំហំនិងដែនកំណត់ផ្តោតសំខាន់ទៅលើការសិក្សាទាក់ទងនឹងដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

នាពេលបច្ចុប្បន្ននេះ។ ក្នុងការសិក្សាស្រាវស្រាវនេះ គឺពួកយើងទាំងពីរនាក់បានពឹងផ្អែកទៅលើធម្មនុញ្ញរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឯកសារនានាដែលពាក់ព័ន្ធនឹងអាស៊ានផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទស្រាវជ្រាវមួយនេះ គឺអាចធ្វើឱ្យអ្នកសិក្សាទាំងឡាយយល់ដឹងកាន់តែស៊ីជម្រៅចំពោះដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅនៃអាស៊ាន រួមទាំងកិច្ចសហប្រតិបត្តិការរវាងរដ្ឋដែលជាសមាជិករបស់អាស៊ាន និងរដ្ឋដែលជាដៃគូសហការជាមួយគ្នា តាមរយៈការស្រាវជ្រាវអំពីអាស៊ាននេះអាចឱ្យយើងយប់ដឹងឱ្យច្បាស់បន្ថែមទៀតពីការចូលរួមចំណែករបស់សមាគមអាស៊ានមួយនេះ ទៅក្នុងពិភពលោកទាំងមូលផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យនៃការស្រាវជ្រាវដែលទាក់ទងទៅ នឹងប្រធានបទមួយនេះយើងខ្ញុំទាំងពីរនាក់បានខិតខំព្យាយាមស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទនៅតាមប្រព័ន្ធអ៊ីនធើណេតក៏ដូចជាការសាកសួរសុំយោបល់ពីសំណាក់សាស្ត្រចារ្យផ្នែកច្បាប់ សិស្សច្បង និងមិត្តរួមការងារ។ ជាពិសេស ឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរដូចជា៖ សៀវភៅអត្ថបទផ្សេងៗ ដែលយើងខ្ញុំទាំងពីរបានព្យាយាមរកនៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ តាមតូបសៀវភៅ បណ្ណាគារ គេហទំព័រជាតិ និងបរទេសមួយចំនួនទៀតដែលជាគ្រឹះនាំឱ្យដំណើរការសរសេរសារណារបស់យើងខ្ញុំទាំងពីរនាក់ទទួលបានជោគជ័យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវសរសេរសារណានេះ យើងខ្ញុំទាំងពីរនាក់បានបែងចែកជា **៣**( **បី** ) **ជំពូក៖**

- **ជំពូកទី១៖** ប្រវត្តិនៃការកកើតអង្គការអាស៊ាន។
- **ជំពូកទី២៖** ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អាស៊ាន។
- **ជំពូកទី៣៖** ទំនាក់ទំនងរវាងអាស៊ានជាមួយ និងមជ្ឈដ្ឋានខាងក្រៅ។

# ជំពូកទី ១
# ប្រវត្តិនៃការកកើតអង្គការអាស៊ាន

ប្រវត្តិនៃការកកើតអង្គការអាស៊ានត្រូវបានបែងចែកជាពីរផ្នែកធំៗ។ ដោយផ្នែកនីមួយៗ មានដូចតទៅៈ ប្រវត្តិនៃអង្គការមុខការកកើតអង្គការអាស៊ានHistory of the Organization of the Founding of ASEAN (ផ្នែកទី១), និងដំណើរការនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍Association of Southe ast Asian Nations-ASEAN(ផ្នែកទី២)។

## ផ្នែកទី១. ប្រវត្តិនៃអង្គការមុនការកកើតអង្គការអាស៊ាន

**១. អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍**(Southeast Asia Treaty Organization-SEATO) អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍SEATO គឺជាអង្គការអន្តរជាតិសម្រាប់ការការពារសមូហភាពនៅអាស៊ីអាគ្នេយ៍ ដែលបង្កើតឡើងដោយសន្ធិសញ្ញាការពារសមូហភាពអាស៊ីអាគ្នេយ៍បានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ១៩៥៤ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ស្ថាប័នផ្លូវការរបស់SEATO ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥ ក្នុងកិច្ចប្រជុំដៃគូសន្ធិសញ្ញានៅទីក្រុងបាងកកប្រទេសថៃ។ ទីស្នាក់ការកណ្តាលរបស់អង្គការនេះក៏ស្ថិតនៅក្នុងទីក្រុងបាងកកផងដែរសមាជិកប្រាំបីនាក់បានចូលរួមក្នុងអង្គការ។[១]

បង្កើតឡើងជាចម្បងដើម្បីទប់ស្កាត់ការទទួលបានកុម្មុយនិស្តបន្ថែមទៀតនៅអាស៊ីអាគ្នេយ៍SEATO ជាទូទៅត្រូវបានចាត់ទុកថាបរាជ័យដោយសារតែជម្លោះផ្ទៃក្នុង និងជម្លោះបានរារាំងការប្រើប្រាស់ជាទូទៅនៃយោធាSEATO ។ ទោះយ៉ាងណាក៏ដោយកម្មវិធីវប្បធម៌ និងការអប់រំដែលផ្តល់មូលនិធិដោយSEATO បានបន្សល់ទុកនូវឥទ្ធិពលយូរអង្វែងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ SEATO ត្រូវបានរំលាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់ពីសមាជិកជាច្រើនបាត់បង់ចំណាប់អារម្មណ៍ និងដកខ្លួនចេញ។[២]

ក្នុងអំឡុងទសវត្សរ៍ទី៥០ ដល់៦០ អង្គការតំបន់មួយចំនួនត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្សេងៗគ្នាក្នុងតំបន់អាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ នៅទីក្រុងបាងកកនៃប្រទេសថៃ។

នៅក្នុងចំណោមអង្គការតំបន់ដែលបានបង្កើតឡើងអំឡុងពេលនោះ គឺជាអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ដែលគេស្គាល់ថាជា "កិច្ចព្រមព្រៀងទីក្រុងម៉ានីល ឬជាសម្ព័ន្ធមិត្តយោធាក្នុងតំបន់" ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៤ ក្នុងគោលបំណងផ្តល់ជំនួយផ្នែកសេដ្ឋកិច្ចក្នុងបរិមាណជាក់លាក់ និងផ្តល់ដំបូន្មានផ្សេងៗ ប្រឆាំងនឹងការបោះបោរដល់រដ្ឋសមាជិករបស់ខ្លួនព្រមទាំងបង្កើតនៅជាសម្ព័ន្ធមិត្ត

[១] https://doi.org/10.1002/9781444338232.wbeow584

[២] https://en.wikipedia.org/wiki/Southeast_Asia_Treaty_Organization

យោធាដើម្បីឆ្លើយតបទៅនឹងបំណងឱ្យតំបន់អាស៊ីអាគ្នេយ៍ត្រូវបានការពារប្រឆាំង នឹងការពង្រីកឥទ្ធិពលលទ្ធិកុម្មុយនីសនៅ ឥណ្ឌូចិន និងតំបន់អាស៊ីដែលនៅក្នុងនោះក៏មានការបោះបោរគាំទ្រកុម្មុយនីសខ្លាំងនៅម៉ាឡេស៊ី និងឥណ្ឌូនេស៊ីផងដែរ។ ប៉ុន្តែសម្ព័ន្ធមិត្តយោធានេះពុំមានការបញ្ជារួម ឬកងកម្លាំងឈរជើងជាប្រចាំទេ។ បើនិយាយឱ្យងាយយល់ទៅអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍នេះ ត្រូវបានរៀបចំឱ្យទៅជាទម្រង់អង្គការសន្ធិសញ្ញាអាត្លង់ទិចខាងជើង "ណាតូ" ប្រចាំអាស៊ីអាគ្នេយ៍។

ក្រោយការចុះហត្ថលេខាលើសន្ធិសញ្ញាការពាររួមគ្នាក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅទីក្រុងម៉ានីលលើសន្ធិសញ្ញានេះបានចូលជាធរមាននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥ ដែលជាសក្ខីភាពកំណត់ពីការបង្កើតអង្គការនេះជាផ្លូវការ និងមានមូលដ្ឋាននៅទីក្រុងបាងកកនៃប្រទេសថៃ។ រដ្ឋហត្ថលេខីរបស់អង្គការនេះមាន អូស្ត្រាលី, បារាំង, នូវែលសេឡង់, ប៉ាគីស្ថាន, ហ្វីលីពីន, ថៃ, អង់គ្លេស និងសហរដ្ឋអាមេរិក។ ដោយឡែក កម្ពុជា, ឡាវ, និងវៀតណាមខាងត្បូង ត្រូវបានផ្តល់ឋានៈត្រឹមជាអ្នកសង្កេតការណ៍ប៉ុណ្ណោះដោយសារការជាប់ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវខែកក្កដា ឆ្នាំ១៩៥៤ និងការប្រកាន់ខ្ជាប់នូវគោលការណ៍អព្យាក្រឹត្យភាពរបស់រដ្ឋនីមួយៗ។ ទោះបីជាយ៉ាងណានេះក្តី កម្ពុជា ឡាវ និងវៀតណាមខាងត្បូងក៏ទទួលបាននូវការការពារស្របតាមគោលការណ៍នៃអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍មួយនេះផងដែរ។[៣]

ការអនុវត្តជាក់ស្តែងនូវសន្ធិសញ្ញានេះមិនដូចការប្តេជ្ញាចិត្តរបស់រដ្ឋហត្ថលេខីទាំងអស់ក្នុងគោលដៅការពារគ្នាទៅវិញទៅមកនោះទេ។ ផ្ទុយទៅវិញវាបានត្រឹមតែបានផ្តល់ការពិភាក្សាពិគ្រោះយោបល់ដោយពុំមានការឆ្លើយតបពីខាងយោធារួមគ្នា ក្នុងករណីមានការឈ្លានពានប្រឆាំងនឹងរដ្ឋហត្ថលេខីនោះទេ ដែលទាំងនេះជាចំណុចខ្វះខាតយ៉ាងខ្លាំងនៃកិច្ចព្រមព្រៀង និងបានធ្វើឱ្យអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍នេះមានការចុះខ្សោយជាខ្លាំងក្នុងនាមខ្លួនជាសម្ព័ន្ធយោធា។ ក្រោយមកទៀតប៉ាគីស្ថានគឺបានធ្វើការដកខ្លួនចេញពីសន្ធិសញ្ញានេះនៅក្នុងឆ្នាំ១៩៦៨ ហើយបារាំងក៏បានផ្អាកការផ្តល់ជំនួយហិរញ្ញវត្ថុរបស់ខ្លួនដល់អង្គការនេះនៅក្នុងឆ្នាំ ១៩៧៥។ អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍នេះត្រូវបានរំសាយទៅវិញនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៧៧។

**២. សមាគមអាស៊ីអាគ្នេយ៍**( Association of Southeast Asia-ASA )

សមាគមអាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៦១ ដោយអតីតសហព័ន្ធម៉ាឡាយ៉ា (បច្ចុប្បន្នជាផ្នែកនៃម៉ាឡេស៊ី) ហ្វីលីពីន និងថៃ ដែលត្រូវបានគេស្គាល់ថាជាក្រុមប្រទេសមានការលូតលាស់លឿនជាងគេនៅអំឡុងទសវត្សរ៍៦០ តាមរយៈការចុះ "សេចក្តីថ្លែងការណ៍ទីក្រុងបាងកក( Bangkok Declaration )"។ គោលបំណងនៃការបង្កើតសមាគមខាងលើនេះ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការណ៍សម្រាប់ជួយ និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកក្នុងវិស័យជាច្រើន ដូចជាសេដ្ឋកិច្ច, សង្គម-វប្បធម៌, វិទ្យាសាស្ត្រ

[៣]Leifer , M. ( 1962 ). Cambodia and SEATO. International Journal, 17( 2 ), 122-132.

ជាដើម។ ជាងនេះទៀត ការបង្កើតទីផ្សាររួមសម្រាប់ជនជាតិអាស៊ី (Asian Common Market) ដើម្បីអាចមានឥទ្ធិពលក្នុងការចរចាប្រកបដោយប្រសិទ្ធិភាព និងធានាឱ្យបាននូវស្ថិរភាពតម្លៃទំនិញពិភពលោកជាពិសេសទៀតនោះផលិតផលកៅស៊ូធម្មជាតិ និងដូងប្រេងដែលនៅពេលនោះរដ្ឋទាំងអស់នោះជាប្រទេសផលិតដ៏ធំបំផុតនៃពិភពលោក។

តាំងពីដំបូងមក មេដឹកនាំសមាគមនេះបានប្រកាសយ៉ាងមុតមាំ និងជារឿយៗថាសមាគមនេះពុំបានដឹកនាំប្រឆាំង នឹងនយោបាយទេ។ ដោយឡែក ឥណ្ឌូនេស៊ីពុំបានចង់ចូលរួមវេទិកានេះទេដោយយល់ថាខ្លួនងាយនឹងធ្លាក់ចូលកទៅក្នុងក្រុមប្រឆាំងកុម្មុយនីស្តមួយហើយដោយបំណងរបស់ឥណ្ឌូនេស៊ី និងកិច្ចសហការជាមួយចិនកុម្មុយនិស្តគឺខុសគ្នា ពីគោលនយោបាយប្រឆាំងកុម្មុយនីស្តរបស់រដ្ឋសមាជិកនៃសមាគមអាស៊ីអាគ្នេយ៍។ មតិមួយចំនួនបានលើកឡើងថា សមាគមនេះបង្កើតឡើងក្នុងគោលបំណងតភ្ជាប់ការគាំទ្រពីលោកខាងលិច។[៤]

បន្ទាប់មក នៅខែឧសភា ឆ្នាំ១៩៦២ សមាគមខាងលើនេះ បានបង្កើតមូលនិធិសមាគមមួយដែលក្នុងនោះថៃ និងសហព័ន្ធម៉ាឡាយ៉ាបានចូលរួមបរិច្ចាកថវិកា ១លាន ដុល្លាអាមេរិកព្រមទាំងបានចេញនូវសេចក្តីថ្លែងការណ៍រួមស្តីពីការអនុវត្តជាបន្ទាប់នូវសកម្មភាពមួយចំនួនសម្រាប់រដ្ឋសមាជិកនៅក្នុងនោះ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងនាវាចរណ៍ការលុបចោលតម្រូវការទិដ្ឋាការសម្រេចមន្ត្រីរាជការ, ការជំរុញវិស័យទេសចរណ៍ និងការបើកសម្ពោធអន្តររាជធានីតាមរយៈសេវាផ្លូវដែកជាដើម។

នៅឆ្នាំ១៩៦៣ សមាគមនេះបានជួបប្រទះនូវជម្លោះដែនដីក្នុងចំណោមរដ្ឋសមាជិក ដែលក្នុងនោះជម្លោះរវាងហ្វីលីពីន និងម៉ាឡេស៊ីតាមរយៈការទាមទារកោះសាបា (Sabah Island) នៅភាគខាងជើងបូណេអូ (North Borneo) ដែលមានព្រំប្រទល់នៅជាប់ប្រទេសព្រុយណេ និងកោះកាលីម៉ាន់តាន់របស់ឥណ្ឌូនេស៊ី ដោយហេតុថាអង់គ្លេសបានបញ្ចូលកោះនេះទៅក្នុងសហព័ន្ធម៉ាឡេស៊ីនៅពេលត្រៀមប្រកាសឯករាជ្យ។

ហ្វីលីពីនចង់ទាមទារផ្នែកខ្លះនៃកោះសាបាជាកម្មសិទ្ធិរបស់ខ្លួន តាមរយៈការស្វែងរកលទ្ធភាពយកករណីជម្លោះនេះទៅតុលាការអន្តរជាតិយុត្តធម៌ (ICJ) ដោយអះអាងថាវាស្ថិតនៅក្នុងដែនដីមួយនៃសមុទ្រស៊ូលូភាគខាងត្បូងហ្វីលីពីន។ ក្រៅពីនេះ ជម្លោះនៅតាមព្រំប្រទល់រវាងម៉ាឡេស៊ី និងថៃក៏បានបង្កផលប៉ះពាល់ដល់ដំណើរការរបស់សមាគមនេះដែរ។ ខុសពីអង្គការតំបន់មុនៗសមាគមនេះបានបង្កើតនូវរចនាសម្ព័ន្ធស្ថាប័នជាក់លាក់មួយចំនួនដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិរវាងរដ្ឋសមាជិកដូចជាការបង្កើតគណៈកម្មាការអចិន្ត្រៃយ៍ (Standing Committee) ដែលមានសមាសភាពរដ្ឋមន្ត្រីការបរទេសម្ចាស់ផ្ទះ និងឯកអគ្គរាជ/រដ្ឋទូតនៃរដ្ឋ

[៤]Institute of Current World Affairs. Retrieved from http://www.icwa.org/wp-content/uploads /2015 /09 / GDN-14.pdf.

សមាជិកដើម្បីមើលការអនុវត្តគម្រោងដែលអនុម័ត, ការរៀបចំកិច្ចប្រជុំរបស់ភាគីក្រុមការងាររួម ( Joint Working Party ) ជាទៀងទាត់មុនពេលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងការរៀបចំកិច្ចប្រជុំនិងសន្និសីទដែលត្រូវបានធ្វើឡើងដោយការផ្លាស់វេនគ្នានៅតាមរាជធានីរបស់រដ្ឋសមាជិកនីមួយៗ ។[៥]

នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៦៦ រដ្ឋមន្ត្រីការបរទេសរបស់រដ្ឋសមាជិកនៃអង្គការអាស៊ីអាគ្នេយ៍បានចេញឯកសាររួមគ្នាស្តីពី “ការអំពាវនាវសន្តិភាព ( Peace Appeal )” ពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីចូលរួមក្នុងការបញ្ចប់សង្គ្រាមវៀតណាម ដោយបានអំពាវនាវឱ្យមានការទទួលស្គាល់ថា សង្គ្រាមបង្កើតបានជា “ការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិភាព និងស្ថិរភាព” នៃតំបន់ព្រមទាំងបានសម្តែងការភ័យខ្លាចថាអស្ថិរភាពនយោបាយនឹងការកាត់បន្ថយលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅកម្រិតតំបន់។ រដ្ឋសមាជិកទាំងអស់ក៏បានពិចារណាបញ្ចូលឥណ្ឌូនេស៊ីទៅក្នុងអង្គការតំបន់។ រដ្ឋទាំងនោះបានទំនាក់ទំនងជាមួយឥណ្ឌូនេស៊ីនៅឯកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសរបស់អង្គការអាស៊ីអាគ្នេយ៍នៅខែសីហា ឆ្នាំ១៩៦៦។ បន្ទាប់មកផែនការថ្មីនៃការបង្កើតអង្គការថ្មីត្រូវបានធ្វើឡើងដែលមានឈ្មោះថា សមាគមអាស៊ីអាគ្នេយ៍សម្រាប់កិច្ចសហប្រតិបត្តិការតំបន់ ( Southeast Asian Association for Regional Cooperation – SEAARC ) ។ បន្ទាប់មកសេចក្តីព្រាងសេចក្តីថ្លែងការណ៍រួមដើម្បីបង្កើត SEAARC ត្រូវបានរៀបចំឡើងនៅខែធ្នូ ឆ្នាំ១៩៦៦។ អង្គការអាស៊ីអាគ្នេយ៍នេះមិនត្រូវបានរំសាយទេ លុះត្រាតែរដ្ឋសមាជិករបស់ខ្លួនជឿជាក់ថា អាស៊ានត្រូវបានចាប់បដិសន្ធិឡើង។[៦]

**៣. អង្គការម៉ាហ្វីលីនដូ** ( Maphilindo )

អង្គការម៉ាហ្វីលីនដូ( Maphilindo ) ត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ ១៩៦៣ តាមរយៈការប្រជុំនិងការឯកភាពរបស់រដ្ឋមន្ត្រីការបរទេសសហព័ន្ធម៉ាឡាយ៉ា, ហ្វីលីពីន និងឥណ្ឌូនេស៊ី។ តាមរយៈការរួមគ្នារវាងម៉ាឡេយ៉ា ហ្វីលីពីន និងឥណ្ឌូនេស៊ីការបង្កើតសហព័ន្ធនេះ គឺបានមកពីលទ្ធផលនៃកិច្ចចរចាត្រីភាគីនៅទីក្រុងម៉ានីល នាខែកក្កដា និងសីហា ឆ្នាំ១៩៦៣ គឺក្នុងគោលបំណងដើម្បីពិភាក្សាគ្នាអំពីចំណុចខុសគ្នារបស់ពួកគេលើគម្រោងបង្កើតប្រទេសម៉ាឡេស៊ី។ អង្គការនេះបានអំពាវនាវឱ្យគូបដិបក្ខក្នុងចំណោមរដ្ឋសមាជិកកុំឱ្យមានការតទល់គ្នា ដោយផ្ទុយទៅវិញអង្គការនេះបានបង្កើនឱ្យមានការពិគ្រោះយោបល់យ៉ាងជិតស្និតដើម្បីទទួលបាននូវការឯកភាព ឬ មតិឯកច្ឆន្ទ។ មិនតែប៉ុណ្ណោះ ថ្នាក់ដឹកនាំរដ្ឋសមាជិកក្នុងអង្គការនេះបានខំពាំនាំនូវយន្តការក្នុងការដោះស្រាយបញ្ហាតំបន់ ជំរុញកិច្ចសហប្រតិបត្តិការសន្តិភាពនៅក្នុងតំបន់ និងសេដ្ឋកិច្ច។ ដែលនៅពេលនោះ

[៥] Pollard, V.K. ( 1970 ). ASA and ASEAN, 1961-1967: Southeast Asian Regionalism. Asian Survey, 10( 3 ), pp.244-255. http/ www. jstor.org/stable/2642577.

[៦] សៀវភៅស្តីពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍( អាស៊ាន )ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផលលទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៥/២៨៣

បញ្ហាដែលពាក់ព័ន្ធនឹងតំបន់គឺ ជម្លោះទឹកដី (កោះសាបា) ទៅក្នុងសហព័ន្ធម៉ាឡេស៊ីដែលរួមបញ្ចូលទាំង ម៉ាឡេយ៉ា, សិង្ហបុរី, សាបា និងសារ៉ាវ៉ាក់។ ដោយហេតុនេះហើយទើបចំនួនសមាជិកវិសាលភាព និងប្រសិទ្ធភាពរបស់ម៉ាហ្វីលីនដូ "Maphilindo" ក្នុងនាមជាអង្គការតំបន់មួយនោះក៏នៅមានកម្រិត។ [៧]

ដោយសារមានការប្រឈមមុខដាក់គ្នារវាងឥណ្ឌូនេស៊ី និងម៉ាឡេស៊ីចំពោះការដាក់ចេញដោយឥណ្ឌូនេស៊ីនូវគោលការណ៍ "ការប្រឈមមុខដាក់គ្នា ( Confrontation )" នៅឆ្នាំ១៩៦៣ ដោយគោលការណ៍នេះឥណ្ឌូនេស៊ីបានប្រឆាំងនឹងសហព័ន្ធម៉ាឡេស៊ី តាមរយៈការបញ្ចូលភាគខាងជើងបូណេអូទៅក្នុងសហព័ន្ធថ្មីនេះដើម្បីទាមទារអធិតេយ្យភាពភាគខាងជើងបូណេអូ ទើបអង្គការម៉ាហ្វីលីនដូនេះត្រូវបានរំលាយទៅវិញយ៉ាងឆាប់ក្រោយពីការបង្កើតគោលការណ៍ប្រឈមមុខរបស់ឥណ្ឌូនេស៊ី។ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ីបានឈានដល់ការព្រមព្រៀងបញ្ចប់គោលការណ៍ "ការប្រឈមមុខដាក់គ្នា" នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៦៦ ហើយព្រមទាំងបានចុះហត្ថលេខានៅទីក្រុងហ្សាការតាលើកិច្ចព្រមព្រៀងសន្តិភាព ( Peace Agreement ) នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៦៦។

ទាំងសមាគមអាស៊ីអាគ្នេយ៍ ( ASA ) និងអង្គការម៉ាហ្វីលីនដូ "Maphilindo" សុទ្ធតែមានអាយុកាលខ្លី អង្គការទាំងពីរនេះចង់បាន ការចែករំលែកគុណតម្លៃ និងវប្បធម៌ ដោយផ្អែកលើមូលដ្ឋាននៃអត្តសញ្ញាណរួមនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងដើម្បីនាំមកនូវភាពចុះសម្រុងគ្នាបានល្អនៅក្នុងតំបន់។ គោលការណ៍គន្លឹះនៃម៉ាហ្វីលីនដូ "Maphilindo" ក៏បានក្លាយជាមូលដ្ឋានគ្រឹះនៃវិធីសាស្ត្ររបស់អាស៊ានឆ្ពោះទៅរកទំនាក់ទំនងល្អរួមទាំងកិច្ចសហប្រតិបត្តិការក្នុងតំបន់ គឺមិនប្រើប្រាស់ការការពាររួមដើម្បីពង្រីកអំណាចខាងផលប្រយោជន៍ និងការប្តេជ្ញាចិត្តចំពោះគោលការណ៍ពិគ្រោះយោបល់គ្នា "MUSYAWARAH" ( ពិគ្រោះយោបល់ ) យកមកធ្វើជាមូលដ្ឋាន ឬការដោះស្រាយជម្លោះ។ គោលការណ៍ទាំងនេះនៅទីបំផុតបានបញ្ចូលគ្នាធ្វើជាផ្លូវ ដែលអាស៊ានត្រូវដើរក្នុងការស្វែងរកកិច្ចព្រមព្រៀងនិងភាពសុខដុមរមនាក្នុងស្មារតីនៃការមិនប្រឈមមុខដាក់គ្នា និងការបង្កើតទំនាក់ទំនងការទូត ជាជាងបើកចំហបង្កឱ្យមានជម្លោះ។ នេះគឺជាក្រមប្រតិបត្តិដ៏សំខាន់សម្រាប់គ្រប់សមាជិកនៅពេលដែលត្រូវការគ្រប់គ្រងទំនាក់ទំនងផ្ទៃក្នុងរបស់អាស៊ាន។

## ផ្នែកទី២. ដំណើរការនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( Association of Southeast Asian Nations-ASEAN )

### ១. សេចក្តីថ្លែងការណ៍អាស៊ានទីក្រុងបាងកក១៩៦៧ ក្នុងការបង្កើតអាស៊ាន

សេចក្តីប្រកាសទីក្រុងបាងកកឆ្នាំ១៩៦៧ ឬសេចក្តីប្រកាសអាស៊ាន គឺជាឯកសារគ្រឹះក្នុងការបង្កើតអាស៊ាន។ សេចក្តីប្រកាសនេះត្រូវបានចុះហត្ថលេខានៅទីក្រុងបាងកក ( ហេតុនេះហើយទើបមានចំណងជើង

[៧] "Duterte vows to pursue Philippines claim to Sabah". 27 May 2016. *Straits Times*.

យ៉ាងដូច្នេះ (ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧) ដែលធ្វើដោយរដ្ឋមន្ត្រីការបរទេសនៃសមាជិកស្ថាបនិកទាំងប្រាំដំបូងគេរបស់អាស៊ានពោលគឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ នេះជាការសម្រេចចិត្តធ្វើឡើងបន្ទាប់ពីការពិភាក្សាជាច្រើនដង គឺជាកាយវិការមួយបង្ហាញពីសាមគ្គីភាពក្នុងចំណោមប្រជាជាតិទាំងប្រាំប្រឆាំងនឹងការពង្រីករបបកុម្មុយនីស្តនៅប្រទេសវៀតណាម។ សេចក្តីប្រកាសទីក្រុងបាងកកនេះបានដាក់ចេញនូវគោលការណ៍ជាមូលដ្ឋានរបស់អាស៊ានដែលជាកិច្ចសហប្រតិបត្តិការមិត្តភាព និងដោយគ្មានការជ្រៀតជ្រែក។ ថ្ងៃទី០៨ ខែសីហាត្រូវបានប្រារព្ធជាទិវាអាស៊ាន។[៨]

សេចក្តីប្រកាសទីក្រុងបាងកកចាប់ផ្តើមដោយបុព្វកថា ឬការណែនាំ ដែលបានបង្ហាញពីគោលគំនិតសំខាន់ៗរបស់បិតាស្ថាបនិក។ ពួកលោកជឿជាក់លើតម្រូវការឱ្យមានទំនាក់ទំនងគ្នាកាន់តែខ្លាំង ក្នុងកិច្ចសហប្រតិបត្តិការសាមគ្គីភាពក្នុងតំបន់ និងការចង់បង្កើតគ្រឹះរឹងមាំសម្រាប់សកម្មភាពរួមមួយឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការតំបន់។ កិច្ចសហប្រតិបត្តិការក្នុងតំបន់នឹងត្រូវបានអនុវត្តក្នុងស្មារតីសមភាពនិងភាពជាដៃគូ និងត្រូវបានគេមើលឃើញថាជាវិធីមួយរួមចំណែកដល់សន្តិភាពវឌ្ឍនភាព និងវិបុលភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ ពួកលោកបាន ដឹងយ៉ាងច្បាស់ថាប្រទេសរបស់ពួកលោកមានការទទួលខុសត្រូវដើម្បីធានាឱ្យមានសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់មួយដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ។ ហេតុនេះចំណុចសំខាន់បំផុតគឺកិច្ចសហប្រតិបត្តិការតំបន់ប្រកបដោយមិត្តភាព និងការយោគយល់គ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង។

❖ នៅក្នុងសេចក្តីប្រកាសទីក្រុងបាងកក គឺមានគោលបំណងចំនួនប្រាំធំៗដូចខាងក្រោម៖

- ផ្តល់ផលប្រយោជន៍ទៅវិញទៅមក និងបញ្ហារួម ក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងបានយល់ឃើញពីតម្រូវការនៃការពង្រឹងបន្ថែមទៀតនូវចំណងសាមគ្គីភាពនិងកិច្ចសហប្រតិបត្តិការក្នុងតំបន់ដែលមានស្រាប់។
- បង្កើតគ្រឹះរឹងមាំសម្រាប់សកម្មភាពទូទៅ ក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងស្មារតីសមភាព ភាពជាដៃគូដើម្បីរួមចំណែកសន្តិភាពវឌ្ឍនភាព និងវិបុលភាពក្នុងតំបន់នេះ។
- ថានៅក្នុងពិភពលោកការពឹងអាស្រ័យគ្នាកាន់តែកើនខ្លាំងឡើង ឧត្តមគតិនៃការស្រឡាញ់សន្តិភាព សេរីភាព យុត្តិធម៌សង្គម និងសុខុមាលភាពសេដ្ឋកិច្ចត្រូវបានសំរេចល្អបំផុត ដោយបង្កើនការយល់ដឹងល្អ អ្នកជិតខាងល្អ និងកិច្ចសហប្រតិបត្តិការប្រកបដោយអត្ថន័យ ក្នុងចំណោមប្រទេសក្នុងតំបន់ដែលធ្លាប់បានចងភ្ជាប់គ្នាដោយទំនាក់ទំនងខាងប្រវត្តិសាស្ត្រនិងវប្បធម៌រួចទៅហើយ។

---

[៨] ASEAN. ១៩៦៧. *The ASEAN Declaration (Bangkok Declaration)*, http://www.asean.org/the-asean-declaration-bangkok-declaration-bangkok-៨-august-១៩៦៧/. សេចក្តីថ្លែងការណ៍អាស៊ាន (សេចក្តីប្រកាសក្រុងបាងកក) ទីក្រុងបាងកក ថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៦៧

- ថាបណ្តា ប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍មានការទទួលខុសត្រូវជាចម្បងសម្រាប់ការពង្រឹងស្ថិរភាព សេដ្ឋកិច្ចសង្គមក្នុងតំបន់ និងធានាបានការអភិវឌ្ឍជាតិ និងការរីកចម្រើន សន្តិភាពនិងថាពួកគេបាន តាំងចិត្តដើម្បីធានាឱ្យបាននូវស្ថិរភាពនិងសុវត្ថិភាពរបស់ពួកគេពីការជ្រៀតជ្រែកពីខាងក្រៅ ដោយបញ្ហា ឬបំណងណាមួយក្នុងគោលបំណងដើម្បីអភិរក្សអត្តសញ្ញាណជាតិរបស់ខ្លួនស្របតាមគតិ និងសេចក្តី ប្រាថ្នារបស់ប្រជាជនរបស់ខ្លួន។
- ថារាល់មូលដ្ឋានទ័ពបរទេសទាំងអស់ស្ថិតនៅជាបណ្តោះអាសន្ន ហើយអាចនៅបានតែជាមួយនឹងការ យល់ព្រមពីប្រទេសពាក់ព័ន្ធ និងមិនត្រូវបានបម្រុងទុកដើម្បីប្រើប្រាស់ដោយផ្ទាល់ឬដោយប្រយោល ដើម្បីធ្វើវិទ្ធង្សនាដល់ឯករាជ្យភាពជាតិ និងសេរីភាពរបស់រដ្ឋជាសមាជិកទាំងអស់នៅក្នុងតំបន់នេះឬ ប៉ះពាល់ដល់ដំណើរការនៃការអភិវឌ្ឍជាតិរបស់ពួកគេ។[៩]

**២. ដំណើរការវិវត្តនៃធម្មនុញ្ញអាស៊ាន**

ធម្មនុញ្ញអាស៊ាន គឺជាឧបករណ៍ធាតុផ្សំនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ វាត្រូវបាន អនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ នៅខែវិច្ឆិកា ឆ្នាំ២០០៧។

ជាង៣០ ឆ្នាំក្រោយមកទើបអាស៊ានមានធម្មនុញ្ញរបស់ខ្លួន ដែលត្រូវបានអនុម័តនៅប្រទេសសង្ហបុរីនៅ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧។ កម្ពុជាបានតម្កល់ឯកសារច្បាប់នៅលេខាធិកាដ្ឋានអាស៊ាន ដើម្បីផ្តល់សច្ចាប័ន ធម្មនុញ្ញអាស៊ាននៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨។ បន្ទាប់ពីធម្មនុញ្ញអាស៊ានត្រូវបានផ្តល់សច្ចាប័នពេញលេញ ដោយរដ្ឋសមាជិកអាស៊ានទាំងអស់ និងចូលជាធរមាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨រួចមក។ វាបានក្លាយជា កិច្ចព្រមព្រៀងស្របច្បាប់ក្នុងចំណោមរដ្ឋសមាជិកទាំងអស់។ ចាប់ពីពេលនោះមកអាស៊ានបានដំណើរការ ការងាររបស់ខ្លួននៅក្រោមក្របខ័ណ្ឌច្បាប់ថ្មី និងបានបង្កើតឱ្យមានស្ថាប័នថ្មីៗមួយចំនួនដើម្បីជំរុញដំណើរការ កសាងសហគមន៍របស់ខ្លួនផងដែរ។ [១០]

គោលបំណង នៃសេចក្តីព្រាងធម្មនុញ្ញនេះត្រូវបានស្នើឡើងជាផ្លូវការនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន លើកទី១១ ដែលបានប្រារព្ធឡើងក្នុងខែធ្នូ ឆ្នាំ២០០៥នៅទីក្រុងគូឡាឡាំពួប្រទេសម៉ាឡេស៊ី។ មេដឹកនាំអាស៊ាន

[៩] ASEAN. ១៩៦៧. *The ASEAN Declaration (Bangkok Declaration)*, http://www.asean.org/the-asean-declaration-bangkok-declaration-bangkok-៨-august-១៩៦៧/

[១០] សៀវភៅស្តីពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)ស្ថាប័ននិងយន្តការនិងនីតិវិធីតាក់តែងឯកសារផលសម្រាប់កិច្ចប្រជុំ អាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៥/២៨៣

ទាំងដប់ដែលម្នាក់មកពីរដ្ឋសមាជិកនីមួយៗ ហៅថាក្រុមបុគ្គលលេចធ្លោអាស៊ាន (EPG) ត្រូវបានចាត់តាំងឱ្យបង្កើតអនុសាសន៍សម្រាប់ការតាក់តែងធម្មនុញ្ញ។[១១]

នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី១២ ដែលធ្វើឡើងក្នុងខែមករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ូប្រទេសហ្វីលីពីនសំណើជាមូលដ្ឋានមួយចំនួនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ មេដឹកនាំអាស៊ានបានព្រមព្រៀងគ្នាក្នុងអំឡុងកិច្ចប្រជុំកំពូលដើម្បីបង្កើត "ក្រុមការងារកម្រិតខ្ពស់លើការព្រាងធម្មនុញ្ញអាស៊ាន" ដែលមានសមាសភាពមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ចំនួនដប់រូបមកពីប្រទេសសមាជិកទាំងដប់។ បន្ទាប់មកក្រុមការងារបានបើកកិច្ចប្រជុំចំនួន១៣ ក្នុងកំឡុងឆ្នាំ២០០៧។[១២]

ធម្មនុញ្ញអាស៊ាន បានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ ដែលមានទាំងអស់ចំនួន១៣ជំពូក និង៥៥មាត្រា និងមានវិសាលភាពគ្រប់ដណ្តប់លើរដ្ឋដែលជាសមាជិករបស់អាស៊ានទាំងអស់។ អាស៊ានត្រូវបានអនុវត្តតាមក្របខណ្ឌច្បាប់ថ្មី និងបង្កើតអង្គការចាត់តាំងថ្មីដើម្បីពង្រឹងដំណើរការកសាងសហគមន៍តែមួយឱ្យកាន់តែខ្លាំងក្លា។ ជាលទ្ធផល ធម្មនុញ្ញអាស៊ានបានក្លាយទៅជាតំណភ្ជាប់ដ៏មានឥទ្ធិពលក្នុងការផ្សារភ្ជាប់រដ្ឋដែលជាសមាជិកទាំងនោះ។ ជាទូទៅ សារៈសំខាន់នៃធម្មនុញ្ញអាស៊ានបានស្តែងចេញឡើងក្នុងទិដ្ឋភាពចម្បងៗជាច្រើនដូចជា៖ [១៣]

- ការប្តេជ្ញាអនុវត្តនយោបាយថ្មីកម្រិតកំពូល
- ការប្តេជ្ញាចិត្តថ្មីៗ និងការប្តេជ្ញាចិត្តដែលត្រូវបានកែលម្អឡើងវិញ
- ក្របខណ្ឌច្បាប់ថ្មី និងសិទ្ធិបុគ្គលស្របតាមផ្លូវច្បាប់
- ការបង្កើតអង្គភាពថ្មីរបស់អាស៊ាន
- ការជ្រើសតាំងអគ្គលេខាធិការរងអាស៊ានថ្មីចំនួន២រូប
- ការរៀបចំកិច្ចប្រជុំអាស៊ានបន្ថែម
- ការរៀបចំមុខងារបន្ថែមរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន
- ការរៀបចំ និងពង្រឹងបន្ថែមលើតួនាទីរបស់អគ្គលេខាធិការអាស៊ាន
- ការបង្កើតគំនិតផ្តួចផ្តើមថ្មីបន្ថែម និងការផ្លាស់ប្តូរ
- កិច្ចការផ្សេងៗទៀត ដែលនៅមិនទាន់បានផ្លាស់ប្តូរឱ្យប្រសើរឡើង។

[១១]ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើធម្មនុញ្ញប្រជាជាតិអាស៊ីអាគ្នេយ៍

[១២]https://km.wikipedia.org/wiki ធម្មនុញ្ញអាស៊ាន

[១៣]List of Members of the Eminent Persons Group (EPG) on the ASEAN charter. Retrieved from https: /asean .org /wp-content/uploads/images/archive/ACP-EPGMember.pdf.

គោលការណ៍គ្រឹះមួយ ក្នុងចំណោមគោលការណ៍សំខាន់ៗផ្សេងៗទៀតក្នុងធម្មនុញ្ញអាស៊ាន គឺរាល់ការសម្រេចរបស់អាស៊ាន ត្រូវឈរលើមូលដ្ឋានប្រឹក្សាយោបល់ និងមតិឯកច្ឆន្ទរបស់អាស៊ាន។ ក្នុងករណីពុំអាចឈានដល់បតិឯកច្ឆន្ទ កិច្ចប្រជុំកំពូលអាស៊ានអាចធ្វើការសម្រេចអំពីរបៀបធ្វើសេចក្តីសម្រេចជាក់លាក់មួយ។ បន្ថែមពីនេះទៀតរដ្ឋសមាជិកអាស៊ានទាំងអស់មានសិទ្ធិ និងកាតព្វកិច្ចស្មើៗគ្នានៅក្រោមធម្មនុញ្ញនេះ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះតាមការឯកភាព និងចែកនៅក្នុងធម្មនុញ្ញអាស៊ានគ្រឹះស្ថានអាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ ក្នុងគោលបំណងគាំទ្រសកម្មភាពអាស៊ាន ក្នុងការបង្កើនការយល់ដឹងអំពីអត្តសញ្ញាណអន្តរកម្ម និងការអភិវឌ្ឍរបស់ប្រជាជនក្នុងតំបន់អាស៊ាន។ រីឯគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សហៅកាត់ថា "អាយឆា" ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ក្នុងគោលបំណងដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលនៅក្នុងតំបន់អាស៊ាន។

បច្ចុប្បន្នភាពនៃធម្មនុញ្ញអាស៊ាន រហូតមកដល់ឆ្នាំ២០១៦ រដ្ឋសមាជិកអាស៊ានមួយចំនួនបានស្នើធ្វើបច្ចុប្បន្នភាពផ្នែកខ្លះនៃធម្មនុញ្ញអាស៊ាន ដោយបានលើកហេតុផលថាធម្មនុញ្ញអាស៊ានបានអនុម័តជាង១០ឆ្នាំមកហើយដូច្នេះឯកសារនេះត្រូវចាំបាច់ធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របទៅ នឹងគោលបំណងនិងគោលដៅនៃចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងឯកសារសំខាន់ៗរបស់អាស៊ានផ្សេងៗទៀត ព្រមទាំងឆ្លើយតបទៅនឹងស្ថានភាពរីកចម្រើនរបស់អាស៊ានក្នុងតំបន់អាស៊ាន និងសកលលោកក៏ដូចជាពង្រឹងរចនាសម្ព័ន្ធយន្តការ និងស្ថាប័នតាមវិស័យរបស់អាស៊ាន។ [១៤]

រហូតមកដល់ឆ្នាំ២០២២ អាស៊ានពុំទាន់មានមតិឯកច្ឆន្ទធ្វើបច្ចុប្បន្នភាពផ្នែកណាមួយនៃធម្មនុញ្ញអាស៊ាននៅឡើយទេដោយគ្រាន់តែកត់សម្គាល់លើការពិនិត្យឡើងវិញលើផ្នែកខ្លះក្នុងឯកសារនេះ ក្នុងគោលបំណងអាចកំណត់បញ្ហាមួយចំនួននៃការអនុវត្តធម្មនុញ្ញអាស៊ានដើម្បីធានាឱ្យមានដំណើរការរលូននិងប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ព្រមទាំងបានប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ានប្រចាំនៅហ្សាការតា (CPR) ដែលមានសមាសភាពជាឯកអគ្គរាជ/រដ្ឋទូតនៃរដ្ឋសមាជិកទាំងអស់ធ្វើការពិភាក្សាឱ្យបានឆាប់លើរបាយការវិសាលភាពស្តីពីការពិនិត្យឡើងវិញលើការអនុវត្តធម្មនុញ្ញអាស៊ាន និងដាក់ចេញអនុសាសន៍ជូនក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលមានសមាសភាពជារដ្ឋមន្ត្រីការបរទេសអាស៊ានដើម្បីផ្តល់ការណែនាំបន្ថែម។

[១៤] Joint Communique of the 54th ASEAN Foreign Ministers Meeting, 2 August 2021. Retrieved from https:/ asean.org/wp-content/uploads/2021/08/Joint-Communique-of-54th-ASEAN-Foreign-Ministers-Meeting-FINAl.pdf.

### ៣. ដំណើរការនៃការពង្រីកខ្លួនរបស់អាស៊ាន

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះ បានចាប់ផ្តើមទទួលវត្តមានរបស់សមាជិកថ្មីៗបន្ថែមទៀតពីលើសមាជិកទាំង៥ ដែលមានស្រាប់។ មកទល់ពេល នឹងបច្ចុប្បន្ននេះអាស៊ានមានសមាជិកចំនួន១០ ប្រទេសដូចជា៖ [១៥]

- ប្រទេសថៃ ឥណ្ឌូណេស៊ី ហ្វីលីពីន ម៉ាឡេស៊ី សិង្ហបុរី ដែលជាប្រទេសបិតាស្ថាបនិកអាស៊ានទាំង៥ ដំបូងគេ
- ប្រទេសព្រុយណេ ដែលបានចូលជាសមាជិកអាស៊ាននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៨៤ ដែលជាសមាជិកទី៦
- ប្រទេសវៀតណាម ដែលបានចូលជាសមាជិកអាស៊ាននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥ ដែលជាសមាជិកទី៧
- ប្រទេសឡាវនិងមីយ៉ាន់ម៉ា ដែលបានចូលជាសមាជិកអាស៊ានដំណាលគ្នានៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧ ដែលជាសមាជិកទី៨ និងទី៩
- ប្រទេសកម្ពុជា ដែលបានចូលជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ដែលជាសមាជិកទី១០។

ជាទូទៅ បញ្ជីរាយនាមសមាជិករបស់អាស៊ាន គឺត្រូវតម្រៀបតាមលំដាប់អក្ខរក្រមភាសាអង់គ្លេសដូចជា ប្រទេសព្រុយណេ (Brunei) កម្ពុជា (Cambodia) ឥណ្ឌូណេស៊ី (Indonesia) ឡាវ (Laos) ម៉ាឡេស៊ី (Malaysia) មីយ៉ាន់ម៉ា (Myanmar) ហ្វីលីពីន (Philippines) សិង្ហបុរី (Singapore) ថៃ (Thailand) និងវៀតណាម (Vietnam)។ បន្ថែមពីនេះទៀត ប្រទេសដែលត្រូវធ្វើជាប្រធានប្តូរវេនអាស៊ាន ត្រូវកំណត់ដោយផ្អែកលើការផ្លាស់ប្តូរវង្វិលជុំតាមលំដាប់អក្ខរក្រមនេះរៀងរាល់ឆ្នាំម្តង។ ក្នុងនោះ ប្រទេសកម្ពុជាបានធ្វើជាប្រធានប្តូរវេនអាស៊ានចំនួន៣ដងផងដែរ គឺក្នុងឆ្នាំ២០០២, ២០១២, និង២០២២។

អ្វីដែលគួរឱ្យកត់សម្គាល់កាលពីដើមខែកុម្ភៈ ឆ្នាំ២០២២ ស្របពេលដែលប្រទេសកម្ពុជាធ្វើជាប្រធានប្តូរវេនអាស៊ានប្រមុខការទូតកម្ពុជានិងអគ្គលេខាធិការអាស៊ាន នឹងព្យាយាមជំរុញប្រទេសទីម័រខាងកើតឱ្យបានចូលជាសមាជិកទី១១របស់អាស៊ាននៅក្នុង ត្រីមាសទី១នៃឆ្នាំ២០២២។ ថ្វីដ្បិតតែបេសកកម្មស្វែងរកការណ៍ពិតនៅក្នុងប្រទេសនេះត្រូវបានបិទបញ្ចប់រួចទៅហើយក្តីថ្នាក់ដឹកនាំអាស៊ានក៏បានលើកឡើងនូវបញ្ហាប្រឈមដែលស្តែងចេញពីវិបត្តិរាតត្បាតនៃជំងឺកូវីដ-១៩ លើការស្នើសុំបញ្ចូលនូវសមាជិកភាពថ្មីនេះផងដែរ។ សូមបញ្ជាក់ថាប្រទេសទីម័រខាងកើតធ្លាប់បានប្រកាសអំពីការចូលជាសមាជិកទី១១របស់អាស៊ានកាលពីឆ្នាំ២០១១ បន្ទាប់ពី

---

[១៥] ASEAN, “ASEAN Member States”, http://asean.org/asean/asean-member-states/

ប្រទេសនេះបានក្លាយជារដ្ឋដែលមានអធិបតេយ្យនិងឯករាជ្យ ពេញលេញដំបូងបង្អស់នៅក្នុងពិភពលោកនាដើម សតវត្សរ៍ទី២១ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២។

ទាក់ទិននឹងការចូលជាសមាជិករបស់អាស៊ាន មាត្រា៦ស្តីពីការទទួលយកសមាជិកថ្មីនៃធម្មនុញ្ញអាស៊ានបានចែងថា៖

១.នីតិវិធីនៃការដាក់ពាក្យ និងការទទួលចូលជាសមាជិកអាស៊ានត្រូវបញ្ញត្ត ដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

២.ការទទួលយកសមាជិកថ្មីត្រូវផ្អែកលើលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- មានទីតាំងភូមិសាស្ត្រ ដែលត្រូវបានគេទទួលស្គាល់ថារដ្ឋនោះស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- មានការទទួលស្គាល់ពីរដ្ឋដែលជាសមាជិកអាស៊ានទាំងអស់
- យល់ព្រមគោរព និងប្រតិបត្តតាមធម្មនុញ្ញអាស៊ាន
- មានលទ្ធភាព និងឆន្ទៈក្នុងការអនុវត្តនូវកាតព្វកិច្ចទាំងអស់ក្នុងនាមជាសមាជិកអាស៊ាន

៣.ការទទួលយកសមាជិកត្រូវសម្រេចដោយគោលការណ៍កុងសង់ស៊ីនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន បន្ទាប់ពីទទួលបានអនុសាសន៍ពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

៤.រដ្ឋដែលស្នើសុំនឹងទទួលបានសមាជិកភាពបន្ទាប់ពីការចុះហត្ថលេខាលើលិខិតបករ (Instrument of Accession) នៃការយល់ព្រមចំពោះធម្មនុញ្ញអាស៊ាន។[១៦]

គោលបំណងនៃការបង្កើតសមាគមអាស៊ានឡើង គឺដើម្បីបង្កើនល្បឿនសេដ្ឋកិច្ចវឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់។ លើកកម្ពស់សន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ជំរុញកិច្ចសហប្រតិបត្តិការនិងការឧបត្ថម្ភជួយគ្នាទៅវិញទៅមកដោយមិនរំពឹងផលប្រយោជន៍តបស្នង។ ផ្តល់ជំនួយដល់គ្នាទៅវិញទៅមកក្នុងទម្រង់ជាការបណ្តុះបណ្តាលនិងការស្រាវជ្រាវកិច្ចសហប្រតិបត្តិការដើម្បីធ្វើឲ្យមានភាពល្អប្រសើរខាងវិស័យកសិកម្មនិងឧស្សាហកម្មដើម្បីលើកកម្ពស់ជីវភាពប្រជាជនលើកកម្ពស់ការសិក្សានៅអាស៊ីអាគ្នេយ៍ រក្សាមិត្តភាពដើម្បីប្រយោជន៍កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដែលមានគោលបំណងដូចគ្នាឬស្រដៀងគ្នា។[១៧]

អំពីគោលការណ៍អាស៊ាន រដ្ឋជាសមាជិកត្រូវប្រកាន់ខ្ជាប់គោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា កិច្ចស្រុះស្រួល និងលិខិតតូបករណ៍ដទៃទៀតរបស់

---

[១៦] សៀវភៅឈ្វេងយល់ សិក្សាអំពីអាស៊ាន បោះពុម្ពលើកទី២ (របស់ក្រុមអ្នកសរសេរហោតប៊ុក) ទំព័រ១៣

[១៧]ASEAN, *The Foundation of ASEAN*. http://www.asean.org/asean/about-asean/history/ Founding fathers of Asean'. 9 August 2011. *The Brunei Times*. http://news.asiaone. com/News/ Latest+ News/Asia /Story/ A1Story 20110809-293603.html.

អាស៊ាន។ អាស៊ាននិងរដ្ឋសមាជិកត្រូវអនុវត្តឲ្យស្របតាមគោលការណ៍ដូចជា៖ គោរពឯករាជភាព អធិបតេយ្យភាសមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់។ ត្រូវចូលរួមការប្តេជ្ញាចិត្តនិងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាពសន្តិសុខ និងវិបុលភាពក្នុងតំបន់ បដិសេធនូវអំពើឈ្លានពាននិងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងឬសកម្មភាពទាំងឡាយណាក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ។ ក្រៅពីនេះត្រូវប្រកាន់យកដំណោះស្រាយជម្លោះដោយសន្តិវិធី មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃរដ្ឋសមាជិកអាស៊ានគោរពសិទ្ធិរបស់រដ្ឋសមាជិកនីមួយៗក្នុងការដឹកនាំអត្ថិភាពជាតិរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីខាងក្រៅ ការធ្វើវិទ្ធង្សនា និងការបង្ខិតបង្ខំ លើកកម្ពស់ការពិគ្រោះយោបល់លើបញ្ហាធ្ងន់ធ្ងរទាំងឡាយ ដែលមានឥទ្ធិពលប៉ះពាល់ដល់ផលប្រយោជន៍រួមរបស់អាស៊ាន។ ប្រកាន់ខ្ជាប់នូវនីតិរដ្ឋ អភិបាលកិច្ចល្អគោលការណ៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាលអាស្រ័យរដ្ឋធម្មនុញ្ញ គោរពសេរីភាពជាមូលដ្ឋានលើកស្ទួយនិងការពារសិទ្ធិមនុស្ស និងលើកកម្ពស់យុត្តិធម៌សង្គម។ [១៨]

នៅក្នុងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ ( Treaty of Amity and Cooperation in Southeast Asia – TAC) ឆ្នាំ១៩៧៦ ត្រង់ជំពូកទី១ មាត្រា២ បានចែងអំពីគោលការណ៍គ្រឹះដែលរដ្ឋសមាជិករបស់អាស៊ានបានអនុម័ត។ គោលការណ៍គ្រឹះទាំង៦ មានជាអាទិ៍៖

- គោរពឯករាជ្យ អធិបតេយ្យ សមភាព បូរណភាពដែនដី និងអត្តសញ្ញាណនៃរដ្ឋជាសមាជិកអាស៊ានទាំងអស់
- រដ្ឋនីមួយៗមានសិទ្ធិគ្រប់គ្រងអត្ថិភាពជាតិដោយគ្មានការជ្រៀតជ្រែក វិទ្ធង្សនានិង ការបង្ខិតបង្ខំពីខាងក្រៅឡើយ
- មិនជ្រៀតជ្រែកកិច្ចការកិច្ចការផ្ទៃក្នុងរបស់រដ្ឋណាឡើយ
- ដោះស្រាយវិវាទឬ ជម្លោះដោយសន្តិវិធី
- ជៀសវាងនូវការគំរាមកំហែងឬការប្រើកម្លាំង
- សហប្រតិបត្តិយ៉ាងមានប្រសិទ្ធភាពជាមួយគ្នាទៅវិញទៅមក។[១៩]

[១៨]https://www.vayofm.com/news/detail/107438-657210126.html

[១៩]សៀវភៅឈ្វេងយល់ សិក្សាអំពីអាស៊ាន បោះពុម្ពលើកទី២ (របស់ក្រុមអ្នកសរសេរហោតប៊ុក) ទំព័រ៩

# ជំពូកទី២
# ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អាស៊ាន

ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អាស៊ានត្រូវបានបែងចែកជាប្រាំមួយធំៗផ្នែក។ ដោយផ្នែកនីមួយៗ មានដូចតទៅ៖ កិច្ចប្រជុំកំពូលអាស៊ាន ASEAN Summit(ផ្នែកទី១),កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសASEAN Foreign Ministers Meeting-AMM(ផ្នែកទី២),ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានASEAN Coordinating Council-ACC(ផ្នែកទី៣),ក្រុមប្រឹក្សាសម្របសម្រួលសហគមន៍អាស៊ានASEAN Community Councils-ACC(ផ្នែកទី៤),ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ានASEAN Sectoral Ministerial Bodies-ASMB(ផ្នែកទី៥),និងលេខាធិការដ្ឋានអាស៊ាន(ផ្នែកទី៦)។

**ផ្នែកទី១. កិច្ចប្រជុំកំពូលអាស៊ាន**(ASEAN Summit)

**១. សមាសភាពរបស់កិច្ចប្រជុំកំពូលអាស៊ាន**

កិច្ចប្រជុំកំពូលអាស៊ាន គឺជាស្ថាប័នរៀបចំគោលនយោបាយខ្ពស់បំផុតក្នុងអាស៊ាន ដែលមានសមាសភាពចូលរួមដោយប្រមុខរដ្ឋ/រដ្ឋាភិបាលនៃរដ្ឋសមាជិកអាស៊ាន។ តាមការអនុវត្តជាក់ស្តែង កិច្ចប្រជុំកំពូលអាស៊ានត្រូវធ្វើឡើងពីរដងក្នុងមួយឆ្នាំ ដែលកំណត់ដោយប្រធានកិច្ចប្រជុំកំពូលអាស៊ានតាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋសមាជិកដទៃទៀតហើយត្រូវធ្វើជាម្ចាស់ផ្ទះដោយរដ្ឋសមាជិក ដែលជាប្រធានអាស៊ាន។ ជាធម្មតា កិច្ចប្រជុំកំពូលអាស៊ានទី១នៃឆ្នាំនីមួយៗត្រូវបានរៀបចំធ្វើក្នុងខែមេសា ឬខែឧសភាដោយចូលរួមតែពីសំណាក់ប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ានតែប៉ុណ្ណោះ។ រីឯកិច្ចប្រជុំកំពូលអាស៊ានទី២នៃឆ្នាំនីមួយៗ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធត្រូវរៀបចំឡើងក្នុងខែតុលា ឬខែវិច្ឆិកាដោយចូលរួមពីប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ាន និងប្រមុខរដ្ឋ/រដ្ឋាភិបាលប្រទេសដៃគូខាងក្រៅអាស៊ាន។[២០]

- អាចត្រូវបានកោះប្រជុំនៅពេលណាចាំបាច់ហើយត្រូវធ្វើជាប្រធានដោយ រដ្ឋសមាជិកដែលជាប្រធានអាស៊ាន និងនៅទីកន្លែងណាមួយដែលឯកភាពគ្នា។
- មានគោលបំណងពិភាក្សាអំពីបញ្ហា/ប្រធានបទជាក់លាក់ ដែលបានឯកភាពគ្នាជាមុនក្រោមការសម្របសម្រួលរបស់ប្រធានអាស៊ានដូចជាការកសាងសហគមន៍អាស៊ាន, ទំនាក់ទំនងជាមួយដៃគូខាងក្រៅ និងលើកទិសដៅអនាគតព្រមទាំងផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់និងអន្តរជាតិ។

---

[២០] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)ស្ថាប័ន និងយន្តការនិងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ២៥/២៨៣

- ផ្តល់ការណែនាំអំពីគោលនយោបាយ និងធ្វើសេចក្តីសម្រេចលើបញ្ហាសំខាន់ៗដែលទាក់ទងនឹងការសម្រេចឱ្យបាននូវគោលបំណងរបស់អាស៊ាន បញ្ហាសំខាន់ៗដែលជាកង្វល់រួមរបស់រដ្ឋសមាជិកនិងបញ្ហាដែលស្នើឡើងដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន, ក្រុមប្រឹក្សាសហគមន៍អាស៊ាននិងស្ថាប័នរដ្ឋមន្ត្រីតាមវិស័យអាស៊ាន។
- ផ្តល់ការណែនាំដល់រដ្ឋមន្ត្រីពាក់ព័ន្ធក្នុងក្រុមប្រឹក្សានីមួយៗ។
- សម្រេចឱ្យបង្កើត និងរំលាយចោលនូវអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែក និងអង្គភាពពាក់ព័ន្ធអាស៊ានដទៃទៀត។
- សម្រេចតែងតាំងអគ្គលេខាធិការអាស៊ាន តាមការស្នើឡើងដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសរបស់អាស៊ាន។[២១]

**២. តួនាទីភារកិច្ចរបស់កិច្ចប្រជុំកំពូលអាស៊ាន**

- ប្រធានអាស៊ានត្រូវប្តូរវេនជារៀងរាល់ឆ្នាំតាមលំដាប់អក្ខរក្រមនៃឈ្មោះរដ្ឋសមាជិកអាស៊ាននីមួយៗជាភាសាអង់គ្លេស។[២២]
- ប្រធានអាស៊ានរយៈពេលមួយឆ្នាំ ត្រូវធ្វើជាប្រធានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖
  - កិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ
  - ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន
  - ក្រុមប្រឹក្សាសហគមន៍អាស៊ានទាំងបី
  - ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកពាក់ព័ន្ធរបស់អាស៊ាន និងឧត្តមមន្ត្រីតាមវិស័យអាស៊ាននីមួយៗ, គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាននៅហ្សាការតា, ក្រុមការងារគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ និងកិច្ចប្រជុំអនុគណៈកម្មាធិការផ្សេងៗទៀត។
- លើកកម្ពស់យ៉ាងសកម្មធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍ និងសុខុមាលភាពរបស់អាស៊ានរួមទាំងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ានតាមរយៈការបង្កើតគំនិតផ្តួចផ្តើម, គោលនយោបាយ, ការសម្របសម្រួល, មតិឯកច្ឆន្ទរបស់អាស៊ាន និងសហប្រតិបត្តិការ។
- ធានាមជ្ឈភាពអាស៊ាន (ASEAN Centrality)។

---

[២១] សៀវភៅស្តី ពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)ស្ថាប័ន និងយន្តការនិងនីតិវិធីតាក់តែងឯកសារផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ជា ទំព័រ២៦/២៨៣

[២២] ASEAN Summit. Retrieved from https://asean.org/about-us/asean-summit/

- ធានាឱ្យបានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាចំពោះបញ្ហាបន្ទាន់ ឬស្ថានភាពវិបត្តិដែលអាចប៉ះពាល់ដល់អាស៊ាន។
- តំណាងអាស៊ានក្នុងការពង្រឹង និងលើកកម្ពស់ទំនាក់ទំនងជិតស្និទ្ធជាមួយដៃគូខាងក្រៅ។
- ប្រធានអាស៊ាន គឺជាអ្នកកំណត់មូលបទនិងគំនិតផ្តួចផ្តើម/អាទិភាពគន្លឹះ និងឯកសារលទ្ធផលនៃកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗ សម្រាប់ចេញផ្សាយ, អនុម័ត និងកត់សម្គាល់នៅក្នុងឆ្នាំជាប្រធានអាស៊ាន។
- មកដល់ពេលនេះ អាស៊ានបានរៀបចំកិច្ចប្រជុំកំពូលរបស់ខ្លួនបានចំនួន៤១លើក។ កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធបានរៀបចំ និងធ្វើជាម្ចាស់ផ្ទះដោយកម្ពុជាក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២។

**តារាងស្តីពីកិច្ចប្រជុំកំពូលអាស៊ានចាប់តាំងពីលើក១ដល់លើកទី៤១**[២៣]

| | |
|---|---|
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១ ដែលធ្វើនៅថ្ងៃទី ២៣-២៤ ខែកុម្ភៈ ឆ្នាំ១៩៦៧ | - ប្រទេសឥណ្ឌូនេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២ ដែលធ្វើនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៧៧ | - ប្រទេសម៉ាឡេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣ ដែលធ្វើនៅថ្ងៃទី ១៤-១៥ ខែធ្នូ ឆ្នាំ១៩៨៧ | - ប្រទេសហ្វីលីពីន គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៤ ដែលធ្វើនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩២ | - ប្រទេសសិង្ហបុរី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៥ ដែលធ្វើនៅថ្ងៃទី ១៤-១៥ ខែធ្នូ ឆ្នាំ១៩៩៥ | - ប្រទេសថៃ គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានក្រៅផ្លូវការលើកទី១ ដែលធ្វើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ | - ប្រទេសឥណ្ឌូនេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានក្រៅផ្លូវការលើកទី២ ដែលធ្វើនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ | - ប្រទេសម៉ាឡេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៦ ដែលធ្វើនៅថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ១៩៩៨ | - ប្រទេសវៀតណាម គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |

[២៣] ASEAN Summit. Retrieved from https:/asean.org/about-us/asean-summit/

| | |
|---|---|
| - កិច្ចប្រជុំកំពូលអាស៊ានក្រៅផ្លូវការលើកទី៣ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ | - ប្រទេសហ្វីលីពីន គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានក្រៅផ្លូវការលើកទី៤ ដែលធ្វើនៅថ្ងៃទី២២-២៥ ខែវិច្ឆិកា ឆ្នាំ២០០០ | - ប្រទេសសិង្ហបុរី គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០០១ | - ប្រទេសព្រុយណេ គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៨ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៤-៥ ខែវិច្ឆិកា ឆ្នាំ២០០២ | - ប្រទេសកម្ពុជា គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៧-៨ ខែតុលា ឆ្នាំ២០០៣ | - ប្រទេសឥណ្ឌូនេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១០ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ | - ប្រទេសឡាវ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១២-១៤ ខែធ្នូ ឆ្នាំ២០០៥ | - ប្រទេសម៉ាឡេស៊ី គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១៣-១៥ ខែមករា ឆ្នាំ២០០៧ | - ប្រទេសហ្វីលីពីន គឺជាម្ចាស់ផ្ទះ និង ជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០០៧ | - ប្រទេសសិង្ហបុរី គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១៤ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៣ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៩<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី១៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៣-២៥ ខែតុលា ឆ្នាំ២០០៩ | - ប្រទេសថៃ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |

| | |
|---|---|
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៨-៩ ខែមេសា ឆ្នាំ ២០១០<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី១៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១០ | - ប្រទេសវៀតណាម គឺជាម្ចាស់ផ្ទះ និងជាប្រធាន អាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី១៨ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ ២០១១<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី១៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១១ | - ប្រទេសឥណ្ឌូនេស៊ី គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២០ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៣-៤ ខែមេសា ឆ្នាំ ២០១២<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១៥-២០ ខែតុលា ឆ្នាំ ២០១១ | - ប្រទេសកម្ពុជា គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៣<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី២៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០១៣ | - ប្រទេសព្រុយណេ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២៤ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៤ | - ប្រទេសមីយ៉ាន់ម៉ា គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |

| | |
|---|---|
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១៤ | |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០១៥<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៥ | - ប្រទេសម៉ាឡេស៊ី គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី២៨ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៦-៧ ខែកញ្ញា ឆ្នាំ ២០១៦<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី២៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៦-៧ ខែកញ្ញា ឆ្នាំ ២០១៦ | - ប្រទេសឡាវ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៧<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៧ | - ប្រទេសហ្វីលីពីន គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៨<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៨ | - ប្រទេសសិង្ហបុរី គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |

| | |
|---|---|
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៤ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១៩<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២-៣ ខែវិច្ឆិកា ឆ្នាំ ២០១៩ | - ប្រទេសថៃ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២០<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២០ | - ប្រទេសវៀតណាម គឺជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២១<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២១ | - ប្រទេសព្រុយណេ គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |
| - កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៨-១៣ ខែវិច្ឆិកា ឆ្នាំ ២០២២<br>- កិច្ចប្រជុំកំពូលអាស៊ានលើកទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលធ្វើនៅថ្ងៃទី៨-១៣ ខែវិច្ឆិកា ឆ្នាំ ២០២២ | - ប្រទេសកម្ពុជា គឺជាម្ចាស់ផ្ទះនិងជាប្រធានអាស៊ាន |

## ផ្នែកទី២. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន( ASEAN Foreign Ministers Meeting-AMM)

### ១. សមាសភាពរបស់កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន

សមាសភាពរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM) គឺមានសមាសភាពចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន។[២៤]

### ២. តួនាទីភារកិច្ចរបស់កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន

- មានតួនាទីទទួលខុសត្រូវកិច្ចសហប្រតិបត្តិការនយោបាយ-សន្តិសុខអាស៊ាន។[២៥]
- បានបង្កើតឡើងដោយសេចក្តីថ្លែងការណ៍ទីក្រុងបាងកក ក្នុងឆ្នាំ១៩៦៧ មកម្ល៉េះ។
- ត្រូវបានរៀបចំឡើងចំនួន ៤ដងក្នុងមួយឆ្នាំយ៉ាងតិច និង ទៀងទាត់ដើម្បីពិនិត្យ និងពិភាក្សាអំពីការកសាងសហគមន៍អាស៊ាន, លើកទិសដៅយុទ្ធសាស្ត្រសម្រាប់ពេលអនាគត និងទំនាក់ទំនងដៃគូខាងក្រៅរបស់អាស៊ាន។
- ត្រូវបានគាំទ្រដោយកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន។
- ចេញផ្សាយសេចក្តីថ្លែងការណ៍រួម (Joint Communiqué) នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានប្រចាំឆ្នាំរបស់ខ្លួន (ជាធម្មតារៀបចំធ្វើ នៅអំឡុងខែសីហា) ដែលរំលេចពីការពិភាក្សាស្តីពីការកសាងសហគមន៍ដោយអាស៊ានក្នុងសសរស្តម្ភទាំងបី, ទំនាក់ទំនងដៃគូខាងក្រៅរបស់អាស៊ាន និងបញ្ហាតំបន់និងអន្តរជាតិ។
- ចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីការអភិវឌ្ឍន៍សំខាន់ៗនៅក្នុងតំបន់ និងពិភពលោកផងដែរ ដែលអាចជះឥទ្ធិពលដល់អាស៊ាន។
- អាចរៀបចំកិច្ចប្រជុំពិសេស ក្នុងករណីចាំបាច់ដើម្បីពិភាក្សាបញ្ហាដែលតម្រូវឱ្យអាស៊ានមានការដោះស្រាយជាបន្ទាន់ ដូចជាការស្នើរបស់ឥណ្ឌូនេស៊ីរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានពិសេសនៅខែកុម្ភៈ ឆ្នាំ២០១១ ដើម្បីពិភាក្សាបញ្ហាព្រំដែនរវាងកម្ពុជា និងថៃ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបន្ទាន់នៅខែធ្នូ ឆ្នាំ២០១៦ ពិភាក្សាស្តីពីស្ថានភាពនៅរដ្ឋរ៉ាខាញ់នៃប្រទេសមីយ៉ាន់ម៉ានិងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបន្ទាន់កន្លងមកនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូដើម្បីពិភាក្សាបញ្ហាតំណាងរបស់មីយ៉ាន់ម៉ាចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៨ និងទី៣៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ។

---

[២៤]យោងតាម ឧបសម្ពន្ធទី១ នៃធម្មនុញ្ញអាស៊ាន

[២៥]Overview. Retrieved from https://asean.org/asean-foreign-ministerial-meeting/

### ៣. កិច្ចប្រជុំពិសេសនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន ( ASEAN Foreign Ministers Retreat-AMR )

- មានសមាសភាពចូលរួមជារដ្ឋមន្ត្រីការបរទេសអាស៊ានដែរ នឹងត្រូវបានរៀបចំធ្វើលើកដំបូងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៣២ នៅក្នុងឆ្នាំ១៩៩៩ នៅប្រទេសសិង្ហបុរី។ បន្ទាប់មកនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានចង្អៀតលើកទី១ ត្រូវធ្វើឡើងដាច់ដោយឡែកពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានដែលធ្លាប់ធ្វើជាទៀងទាត់។[២៦]
- កិច្ចប្រជុំបែបនេះត្រូវបានរៀបចំធ្វើជាទៀងទាត់នៅក្នុងខែមករា ឬខែកុម្ភៈ។
- ផ្តល់វេទិកាដ៏សំខាន់សម្រាប់រដ្ឋមន្ត្រីការបរទេសពិនិត្យឡើងវិញ និងវាយតម្លៃយ៉ាងយកចិត្តទុកដាក់លើសភាពការណ៍តំបន់ពិភាក្សាអំពីបញ្ហាជាយុទ្ធសាស្ត្រ និងឧបសគ្គសម្រាប់អាស៊ាន និងទិសដៅអនាគត។ ទន្ទឹមនឹងនេះ ក៏ជាវេទិកាសម្រាប់រដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកលើកឡើងអំពីស្ថានភាពក្នុងប្រទេសរបស់ខ្លួន។ ក្នុងឱកាសនោះដែលប្រធានអាស៊ានក៏អាចបង្ហាញអំពីបញ្ជីអាទិភាព/គំនិតផ្តួចផ្តើម និងឯកសារលទ្ធផលសំខាន់ៗដែលគ្រោងដាក់ចេញ ឬសម្រេចឱ្យបានជូនដល់រដ្ឋសមាជិកដើម្បីផ្តល់មតិ និងគាំទ្រផងដែរ។
- ជានិច្ចកាលត្រូវរៀបចំនៅកន្លែងដែលមានបរិយាកាសជាលក្ខណៈបន្ធូរអារម្មណ៍, កន្លែងស្ងប់ស្ងាត់ដាច់ឆ្ងាយពីទីប្រជុំជន និងមិនមានអ្នកសារព័ត៌មានចូលរួមច្រើនកុះករទេ។
- រដ្ឋមន្ត្រីការបរទេសអាចផ្លាស់ប្តូរទស្សនៈ ដែលមានលក្ខណៈ“លំហូរសេរី ( free-flowing )”ផ្អែកលើប្រធានបទពិភាក្សា ( Indicative List of Topics ) ជាសជាងការកំណត់របៀបវារៈជាក់លាក់ ឬផ្លូវការសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំ។
- ចូលរួមដោយរដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកនីមួយៗ និងអគ្គលេខាធិការអាស៊ាន ( ចូលរួមតែម្នាក់ឯង ឬរដ្ឋមន្ត្រីការបរទេស/អគ្គលេខាធិការរាប់អាស៊ានបូកមន្ត្រី០១រូប ឬបូកមន្ត្រី ០២រូបតាមការឯកភាពគ្នាប៉ុណ្ណោះ )។ ការរៀបចំបែបនេះមានបំណងបញ្ចៀសការចូលរួមពីសមាជិកគណប្រតិភូមកដល់ដែលមានគ្នាច្រើន ដើម្បីអាចឱ្យរដ្ឋមន្ត្រីការបរទេសអាស៊ានមានអារម្មណ៍ទស្សនា-សុខស្រួលនិងអាចបញ្ចេញទស្សនៈដោយស្មោះត្រង់។

[២៦]Thuzer, M.and Thi Ha. H. ( 1998 ). ASEAN Retreat: Origins and Functions. The ASEAN Studies Centre, ISEAS-Yusof Ishak Institute. Issue on 01/2018. Retrieved from https:/www.issue.edu.sg/images /pdf/ASEANM atterslssue1.pdf

- ពុំមានការរៀបចំរបាយការណ៍កិច្ចប្រជុំជាផ្លូវការទេ ប៉ុន្តែប្រធានអាស៊ានអាចរៀបចំជាចំណុចសំខាន់នៃកិច្ចប្រជុំ (summary of points) ដោយមានការគាំទ្រពីលេខាធិការដ្ឋានអាស៊ាន ក្នុងគោលបំណងទុកតាមដានការជាវបន្តការពិភាក្សាក្នុងករណីចាំបាច់។

**ផ្នែកទី៣. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន** (ASEAN Coordinating Council-ACC)

**១. សមាសភាពរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន**

ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានរួមមានសមាសភាពរដ្ឋមន្ត្រីការបរទេសអាស៊ាន និងត្រូវជួបប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំ ។ [២៧]

**២. តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន**

តួនាទីរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានមានដូចតទៅ៖[២៨]

- រៀបចំកិច្ចប្រជុំកំពូលអាស៊ាន
- សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង និងសេចក្ដីសម្រេចរបស់កិច្ចប្រជុំកំពូលអាស៊ាន
- សម្របសម្រួលជាមួយក្រុមប្រឹក្សាសហគមន៍អាស៊ានដើម្បីលើកកម្ពស់ភាពប្រសើរនៃគោលនយោបាយប្រសិទ្ធភាព និងសហប្រតិបត្តិការក្នុងចំណោមគ្នានឹងគ្នា
- សម្របសម្រួលរបាយការណ៍ របស់ក្រុមប្រឹក្សាសហគមន៍អាស៊ានជូនកិច្ចប្រជុំកំពូលអាស៊ាន
- ពិនិត្យពិចារណាលើរបាយការណ៍ប្រចាំឆ្នាំ របស់អគ្គលេខាធិការស្ដីពីការងារអាស៊ាន
- ពិនិត្យពិចារណាលើរបាយការណ៍របស់អគ្គលេខាធិការស្ដីពីមុខងារ និងប្រតិបត្តិការនៃអគ្គលេខាធិការដ្ឋានអាស៊ាន និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត
- ឯកភាពចំពោះការតែងតាំង និងបញ្ចប់អាណត្តិអគ្គលេខាធិការរងបន្ទាប់ពីបានទទួលអនុសាសន៍របស់អគ្គលេខាធិការ
- អនុវត្តការងារផ្សេងៗទៀតដែលកំណត់ឡើងក្នុងធម្មនុញ្ញនេះឬមុខនាទីផ្សេងៗទៀត ដែលអាចកំណត់ឡើងដោយកិច្ចប្រជុំកំពូលអាស៊ាន ។

[២៧] https://asean.org/about-asean/asean-coordinating-council/

[២៨] សៀវភៅស្ដីពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៤០/២៨៣

## ផ្នែកទី៤. ក្រុមប្រឹក្សាសម្របសម្រួលសហគមន៍អាស៊ាន ( ASEAN Community Councils-ACC )

### ១. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាន

ក្រុមប្រឹក្សាសហគមន៍អាស៊ាន មានសមាសភាពចូលរួមមានក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន, ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន, ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន។ ក្រុមប្រឹក្សាសហគមន៍នីមួយៗត្រូវប្រជុំយ៉ាងតិច២ដងនៅក្នុងមួយឆ្នាំដែលដឹកនាំដោយរដ្ឋសមាជិក ដែលជាប្រធានអាស៊ាន។ ក្រុមប្រឹក្សាសហគមន៍នីមួយៗ ត្រូវបានគាំទ្រដោយឧត្តមមន្ត្រីពាក់ព័ន្ធនិងសហគមន៍នីមួយៗ។ ក្រុមប្រឹក្សាសហគមន៍នីមួយៗមានអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែកនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋសមាជិកអាស៊ាននីមួយៗត្រូវតែងតាំងតំណាងជាតិរបស់ខ្លួនសម្រាប់ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នីមួយៗ ដើម្បីសម្រេចគោលដៅនីមួយៗ សម្រាប់សសរស្តម្ភរបស់សហគមន៍អាស៊ានក្រុមប្រឹក្សានីមួយៗចាំបាច់ត្រូវ៖ [២៩]

- ធានាអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់កិច្ចប្រជុំអាស៊ាន
- សម្របសម្រួលការងារផ្នែកផ្សេងៗក្រោមសមត្ថកិច្ចរបស់ខ្លួន និងលើបញ្ហាដែលកើតឡើងក្នុងក្រុមប្រឹក្សាសហគមន៍ដទៃទៀត
- ដាក់របាយការណ៍ និងអនុសាសន៍ផ្សេងៗលើបញ្ហាស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនជូនកិច្ចប្រជុំកំពូលអាស៊ាន។

**ក. សសរស្តម្ភសហគមន៍នយោបាយ-សន្តិសុខអាស៊ាន** ( ASEAN aSecurity Community-ASC )

ដើម្បីបន្តលើកស្ទួយកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ និងនយោបាយដែលបានកសាងមកជាច្រើនឆ្នាំ អាស៊ានបានបង្កើតសហគមន៍សន្តិសុខ-នយោបាយដើម្បីធានាថាប្រទេសក្នុងតំបន់រស់នៅជាមួយគ្នាប្រកបដោយសន្តិភាពហើយក្នុងបរិយាកាសមួយប្រកបដោយយុត្តិធម៌ប្រជាធិបតេយ្យ និងសុខដុមរមនា។ ផែនការមេរបស់សហគមន៍សន្តិសុខ-នយោបាយសំដៅប្រែក្លាយអាស៊ានឱ្យក្លាយជា សហគមន៍ដែលផ្អែកលើច្បាប់យកចិត្តទុកដាក់ចំពោះប្រជាជននិងយកប្រជាជនជាធំ ដែលប្រជាជនក្នុងតំបន់ទទួលបានសិទ្ធិមនុស្សសេរីភាពជាមូលដ្ឋាន និងយុត្តិធម៌សង្គមរស់នៅប្រកបដោយការអត់ឱននិងសម្របសម្រួលគ្នាទៅវិញទៅមក ព្រមទាំងយកចិត្តទុកដាក់លើភាពរួមគ្នាអត្តសញ្ញាណរួម និងជោគវាសនារួម។ មិនតែប៉ុណ្ណោះ វាធ្វើឱ្យអាស៊ានក្លាយជាសហគមន៍ដែលមានស្ថិរភាព សន្តិសុខ និងសន្តិភាព ជាមួយនឹងការពង្រឹងសមត្ថភាពឆ្លើយតបបញ្ហាប្រឈមនានាដែលជាប្រយោជន៍រួមក្នុងតំបន់ប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលាស្របតាមគោលការណ៍សន្តិសុខគ្រប់ជ្រុងជ្រោយ។

---

[២៩] https://asean.org/about-asean/asean-community-council/

ផែនការមេមានគោលដៅធ្វើឱ្យអាស៊ានជាសហគមន៍ដែលសម្លឹងមើលការពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅទាំងក្នុងអង្គការតំបន់និងអន្តរជាតិពង្រឹងមជ្ឈភាព និងតួនាទីស្នូលរបស់អាស៊ាននៅក្នុងនិម្មាបនកម្មតំបន់ ( Regional Architecture ) ក៏ដូចជាដើរតួនាទីដោះស្រាយបញ្ហាអន្តរជាតិប្រកបដោយទទួលខុសត្រូវនិងក្នុងន័យស្ថាបនាជាសាកល។

ឧក្រិដ្ឋកម្មឆ្លងដែន, សិទ្ធិមនុស្ស, ស្ត្រី សន្តិភាព និងសន្តិសុខ, ការជួញដូរអាវុធ និងការជួញដូរមនុស្ស, ប្រឆាំងភេរវកម្ម, ការសម្អាតលុយ, ការគ្រប់គ្រងព្រំដែន, សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត, គ្រឿងញៀនខុសច្បាប់, កិច្ចសហប្រតិបត្តិការការពារជាតិ, ការទូតបង្ការការពារ, ការមិនរីកសាយភាយ និងការរំលាយអាវុធ, តំបន់គ្មានអាវុធនុយក្លេអ៊ែរអាស៊ីអាគ្នេយ៍, សុវត្ថិភាពនុយក្លេអ៊ែរ សន្តិសុខ និងការការពារ, កិច្ចសហប្រតិបត្តិការនិងសន្តិសុខលំហសមុទ្រ, ស្ថានការណ៍នៅសមុទ្រចិនខាងត្បូងជាដើម។ [៣០]

**ខ. សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន** ( ASEAN Economic Community-AEC )

ជាមួយទីផ្សារទំហំ ២,៣ លានដុល្លារ និងប្រជាជនប្រមាណ ៦០០លាននាក់ សហគមន៍សេដ្ឋកិច្ចអាស៊ានមានគោលដៅសំខាន់បំផុតគឺក្តោបប្រទេសជាសមាជិកទាំង១០ ឱ្យក្លាយទៅជាទីផ្សាររួមមួយតាមរយៈសមាហរណកម្មសេដ្ឋកិច្ច។ ផែនការមេរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានមានទិសដៅសំខាន់បួន ដើម្បីប្រែក្លាយតំបន់អាស៊ានឱ្យទៅជាទីផ្សារតែមួយ និងមូលដ្ឋានផលិតកម្មរួមតែមួយ សំដៅធានាលំហូរទំនិញសេវាកម្មការវិនិយោគពលកម្មជំនាញនិងមូលធនដោយសេរីក្នុងតំបន់, ជាតំបន់មួយដែលមានការប្រកួតប្រជែងសេដ្ឋកិច្ចខ្ពស់, ជាតំបន់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមភាពនិងជាតំបន់ដែលបានធ្វើសមាហរណកម្មពេញលេញទៅក្នុងសេដ្ឋកិច្ចពិភពលោក។

សមាហរណកម្មពាណិជ្ជកម្ម និងទីផ្សារការសម្របសម្រួលពាណិជ្ជកម្ម, ពាណិជ្ជកម្មក្នុងទំនិញ, គយ, ច្បាប់នៃប្រភពដើម, ច្រកចេញចូលតែមួយរបស់អាស៊ាន, ពាណិជ្ជកម្មក្នុងសេវាកម្ម, សមាហរណកម្មហិរញ្ញវត្ថុ, ការវិនិយោគ, ស្តង់ដារ និងការអនុលោមភាព, គោលនយោបាយប្រកួតប្រជែង, ការពារអតិថិជន, កម្មសិទ្ធិបញ្ញា, ថាមពល, រ៉ែ, ស្បៀង, កសិកម្ម និងព្រៃឈើ, បរិស្ថាន, បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង, ពាណិជ្ជកម្មអេឡិចត្រូនិច, ទេសចរណ៍, វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ដឹកជញ្ជូន, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, ភាពជាដៃគូសេដ្ឋកិច្ចតំបន់គ្រប់ជ្រុងជ្រោយជាដើម។[៣១]

---

[៣០] សៀវភៅស្តីពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៤៣/២៨៣

[៣១] សៀវភៅស្តីពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៤៤/២៨៣

**គ. សសរស្តម្ភសហគមន៍សង្គម-វប្បធម៌អាស៊ាន** ( ASEAN Socio-Cultural Community-ASCC )

សហគមន៍សង្គម-វប្បធម៌ ជាសសរស្តម្ភទី៣ របស់សហគមន៍អាស៊ាន ដែលមានគោលដៅសម្រេចនូវសក្តានុពលពេលលេញរបស់ប្រជាជាតិអាស៊ានតាមរយៈការអភិវឌ្ឍធនធានមនុស្សការលើកកម្ពស់ការអប់រំ ការការពារសុខុមាលភាពសង្គមលើកកម្ពស់យុត្តិធម៌សង្គម និងសិទ្ធិប្រជាជន ធានាជីវភាព បរិស្ថាន កសាងអត្តសញ្ញាណអាស៊ាន និងបំព្រួញគន្លាតអភិវឌ្ឍន៍។

សសរស្តម្ភសហគមន៍សង្គម-វប្បធម៌មានបំណងធ្វើឱ្យអាស៊ានក្លាយជា សហគមន៍ដែលមានការប្តេជ្ញាការចូលរួម និងទំនួលខុសត្រូវក្នុងសង្គមដើម្បីផលប្រយោជន៍ប្រជាជនអាស៊ាន, សហគមន៍ប្រកបដោយបរិយាប័ន្នដែលលើកកម្ពស់របៀបរបបរស់នៅ ទទួលបានឱកាសប្រកបដោយសមភាព ក៏ដូចជាលើកកម្ពស់ និងការពារសិទ្ធិមនុស្ស, សហគមន៍ប្រកបដោយចីរភាពដែលលើកកម្ពស់ការអភិវឌ្ឍសង្គម និងការការពារបរិស្ថាន, សហគមន៍ដែលមានភាពធន់រួមជាមួយការពង្រឹងសមត្ថភាព លទ្ធភាពដើម្បីសម្របខ្លួន និងឆ្លើយតបទៅនឹងភាពងាយរងគ្រោះនៃសង្គមនិងសេដ្ឋកិច្ច គ្រោះមហន្តរាយ បម្រែបម្រួលអាកាសធាតុ និងបញ្ហាប្រឈមថ្មីផ្សេងៗទៀត, សហគមន៍ប្រកបដោយភាពស្វាហាប់និងសុខដុមរមនាដែលមានការយល់ដឹង និងមានមោទនភាពចំពោះអត្តសញ្ញាណវប្បធម៌ និងបេតិកភណ្ឌរបស់ខ្លួន។

**ផ្នែកទី៥. ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន**( ASEAN Sectoral Ministerial Bodies-ASMB )

**១. សមាសភាពរបស់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន**

ស្ថាប័នថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ានគឺស្ថិតនៅក្រោមសសរស្តម្ភអាស៊ានទាំងបី ដែលក្នុងនោះក្រោមសហគមន៍នយោបាយ-សន្តិសុខអាស៊ានមានរដ្ឋមន្ត្រីជំនាញតាមវិស័យដូចជា៖ រដ្ឋមន្ត្រីការបរទេសអាស៊ាន, រដ្ឋមន្ត្រីការពារជាតិអាស៊ាន រដ្ឋមន្ត្រីច្បាប់អាស៊ាន រដ្ឋមន្ត្រីឧក្រិដ្ឋកម្មឆ្លងដែនជាដើម។

ក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ានមានរដ្ឋមន្ត្រីជំនាញ តាមវិស័យដូចជា៖ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន, រដ្ឋមន្ត្រីអាស៊ានស្តីពីកសិកម្ម និងរុក្ខាប្រមាញ់, រដ្ឋមន្ត្រីអាស៊ានស្តីពីថាមពល, រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន, រដ្ឋមន្ត្រីទេសចរណ៍អាស៊ានជាដើម។

ក្រោមសហគមន៍សង្គម-វប្បធម៌អាស៊ានមានរដ្ឋមន្ត្រីជំនាញតាមវិស័យដូចជា៖ រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកព័ត៌មាន, រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវប្បធម៌និងសិល្បៈ, រដ្ឋមន្ត្រីអប់រំអាស៊ាន, រដ្ឋមន្ត្រីបរិស្ថានអាស៊ាន រដ្ឋមន្ត្រីស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ, រដ្ឋមន្ត្រីសុខាភិបាលអាស៊ានជាដើម។[៣២]

---

[៣២] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៤៥/២៨៣

### ២. តួនាទីភារកិច្ចរបស់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន

ស្រដៀងគ្នានឹងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានចង្អៀតនៅក្រោមសសរស្តម្ភសហគមន៍នយោបាយ-សន្តិសុខអាស៊ានដែលក្រោមសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ានក៏មានការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានចង្អៀត និងកិច្ចប្រជុំរដ្ឋមន្ត្រីសង្គម-វប្បធម៌អាស៊ានចង្អៀតរៀងៗខ្លួនផងដែរ។

- អនុវត្តកិច្ចព្រមព្រៀង និងសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូលអាស៊ានដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចខ្លួន។
- ពង្រឹងកិច្ចសហប្រតិបត្តិការតាមវិស័យនីមួយៗដើម្បីគាំទ្រសមាហរណកម្ម និងការកសាងសហគមន៍អាស៊ាន។
- ដាក់របាយការណ៍ និងអនុសាសន៍ជូនក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ។
- អាចមានឧត្តមមន្ត្រី និងអង្គការចំណុះតាមវិស័យនីមួយៗ។

## ផ្នែកទី៦. លេខាធិការដ្ឋានអាស៊ាន

### ១. អគ្គលេខាធិការ

អគ្គលេខាធិការអាស៊ាន ជាប្រធានរដ្ឋបាលនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ឬហៅកាត់ថាអាស៊ាន។ អាណត្តិរបស់អគ្គលេខាធិការអាស៊ានមានរយៈពេល៥ ឆ្នាំ និងមិនមានការបន្តអាណត្តិទី២ទេ។ អគ្គលេខាធិការអាស៊ានត្រូវតែជាជាតិសាសន៍របស់រដ្ឋមួយក្នុងចំណោមរដ្ឋសមាជិកអាស៊ានទាំង១០ ហើយការតែងតាំងត្រូវធ្វើឡើងក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ានដោយផ្អែកលើលំដាប់អក្សរក្រមនៃប្រទេសសមាជិក។ មាត្រា១១ នៃធម្មនុញ្ញអាស៊ានចែងពីលក្ខណៈវិនិច្ឆ័យនៃអគ្គលេខាធិការអាស៊ាន ដោយគិតលើសុចរិតភាពសមត្ថភាពបទពិសោធវិជ្ជាជីវៈ និងសមភាពយេនឌ័រ។ កិច្ចការប្រចាំថ្ងៃរបស់អគ្គលេខាធិការអាស៊ានត្រូវបានជួយដោយអគ្គលេខាធិការរងចំនួនបួននាក់ ដែលជួយការងារតាមសសរស្តម្ភរបស់អាស៊ាន។ អគ្គលេខាធិការរងទាំងបួនត្រូវមានសញ្ជាតិខុសគ្នាពីអគ្គលេខាធិការ និងមកពីរដ្ឋសមាជិកអាស៊ានចំនួនបួនផ្សេងៗគ្នា។

តាមធម្មនុញ្ញអាស៊ាន តួនាទីរបស់អគ្គលេខាធិការអាស៊ានមានដូចជាអនុវត្តភារកិច្ច និងទំនួលខុសត្រូវរបស់ការិយាល័យជាន់ខ្ពស់នេះ ស្របតាមបទប្បញ្ញត្តិនៃធម្មនុញ្ញ និងច្បាប់ផ្សេងៗរបស់អាស៊ាន និងការអនុវត្តផ្សេងទៀតដែលបានបង្កើតឡើងដោយអាស៊ាន, សម្របសម្រួល និងតាមដានដំណើរការក្នុងការអនុវត្តការសម្រេចចិត្តកិច្ចព្រមព្រៀងផ្សេងៗ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន។

លើសពីនោះ អគ្គលេខាធិការអាស៊ានក៏ចូលរួមក្នុងកិច្ចប្រជុំដូចជា កិច្ចប្រជុំកំពូលអាស៊ានក្រុមប្រឹក្សាសហគមន៍អាស៊ានក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន និងគណៈរដ្ឋមន្ត្រីតាមវិស័យអាស៊ាន និងកិច្ចប្រជុំ

ពាក់ព័ន្ធផ្សេងទៀតរបស់អាស៊ាន, បង្ហាញទស្សនៈរបស់អាស៊ាន និងចូលរួមក្នុងកិច្ចប្រជុំជាមួយភាគីខាងក្រៅ ដោយអនុលោមតាមគោលការណ៍ណែនាំដែលបានអនុម័ត និងអាណត្តិដែលផ្តល់ឱ្យអគ្គលេខាធិការ និងផ្តល់ការណែនាំក្នុងការតែងតាំង និងបញ្ចប់តំណែងអគ្គលេខាធិការរងទៅកាន់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានសម្រាប់អនុម័តបន្ត។ [៣៣]

ចាប់តាំងពីមានវត្តមានរបស់លេខាធិការដ្ឋានអាស៊ានមក មានមន្ត្រីចំនួន១៣រូបដែលបានកាន់តំណែង និង១រូបកំពុងកាន់តំណែងជាអគ្គលេខាធិការអាស៊ាន។ អគ្គលេខាធិការអាស៊ាន និងអតីតអគ្គលេខាធិការអាស៊ានទាំងនោះរួមមាន៖[៣៤]

១- ឧត្តមសេនីយ៍ ហាតូណូ រ៉េកសូ ដាសូណូ (Hartono Rekso Dharsono) ជនជាតិឥណ្ឌូនេស៊ី កាន់តំណែង ឆ្នាំ១៩៧៦-១៩៧៨

២- លោក អ៊ូម៉ាចាឌី ណូតូវីចូណូ (Umarjadi Notowijono) ជនជាតិឥណ្ឌូនេស៊ី កាន់តំណែង ១៩ កុម្ភៈ ១៩៧៨ ដល់ ៣០ មិថុនា ១៩៧៨

៣- ឯកឧត្តម ដាទុក អាលី ប៊ីន អាប់ឌុលឡះ (H.E. Datuk Ali Bin Abdullah) ជនជាតិម៉ាឡេស៊ី កាន់តំណែង ឆ្នាំ១៩៧៨-១៩៨០

៤- លោក ណាស៊ីសូ ជី. រីយ៉េស (Narciso G. Reyes) ជនជាតិហ្វីលីពីន កាន់តំណែងឆ្នាំ១៩៨០-១៩៨២

៥- លោក ចាន់ កយ៉ូ (Chan Kai Yau) ជនជាតិសិង្ហបុរី កាន់តំណែងឆ្នាំ១៩៨២-១៩៨៤

៦- លោក ផែន វណ្ណមេធី (Phan Wannamethee) ជនជាតិ ថៃ កាន់តំណែងឆ្នាំ១៩៨៤-១៩៨៦

៧- លោក ដាតូ រ៉ូដរីក យ៉ាំង (Dato Roderick Young) ជនជាតិព្រុយណេ កាន់តំណែងឆ្នាំ១៩៨៦-១៩៨៩

៨- លោក រ៉ូអេសស៊ី ណូ (Roesli Noor) ជនជាតិឥណ្ឌូនេស៊ី កាន់តំណែងឆ្នាំ១៩៨៩-១៩៩៣

៩- ឯកឧត្តម ដាតូ អាជីត សិង្ហ (H.E. Dato Ajit Singh) ជនជាតិម៉ាឡេស៊ី កាន់តំណែងឆ្នាំ១៩៩៣-១៩៩៧

១០- លោក រ៉ូដូលហ្វូ ស៊ីតហ្សា សេវើរីណូ (Rodolfo Certeza Severino) ជនជាតិហ្វីលីពីន កាន់តំណែងឆ្នាំ១៩៩៨-២០០២

១១- ឯកឧត្តម អុង កេងយ៉ុង (Ong Keng Yong) ជនជាតិសិង្ហបុរី កាន់តំណែងឆ្នាំ២០០៣-២០០៧

១២- បណ្ឌិត សុរិន្ទ្រ ពិសសុវណ្ណ (Surin Pitsuwan) ជនជាតិថៃ កាន់តំណែងឆ្នាំ២០០៨-២០១២

[៣៣] https://thmeythmey.com/?page=detail&id=120376

[៣៤] កិច្ចព្រមព្រៀងស្តីពីការបង្កើតស្ថាប័នរដ្ឋលេខាធិការអាស៊ាន

១៣- ឯកឧត្តម ឡេ លួងមិញ ( Le Luong Minh ) ជនជាតិវៀតណាម កាន់តំណែងឆ្នាំ២០១៣-២០១៧

១៤- ឯកឧត្តម ដាតូ លីម ចុក ហូយ ( Dato Lim Jock Hoi ) ជនជាតិព្រុយណេ កាន់តំណែងឆ្នាំ២០១៨-២០២២

រាប់ចាប់ពីឆ្នាំ១៩៩៩ មកស្របពេលដែលអាស៊ានមានសមាជិកចំនួន១០ប្រទេស ប្រទេសដែលមិនទាន់មានមន្ត្រីទទួលបានតំណែងជាអគ្គលេខាធិការអាស៊ានមានដូចជា ឡាវ មីយ៉ាន់ម៉ា និងកម្ពុជា។

សរុបមក អគ្គលេខាធិការអាស៊ាននិងលេខាធិការដ្ឋាន អាស៊ានមានមុខងារជួយសម្របសម្រួលសេចក្តីសម្រេចឱ្យមានប្រសិទ្ធភាពនៅក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។ បន្ថែមពីលើនេះរដ្ឋសមាជិកទាំងអស់ត្រូវចាត់តាំងតំណាងអចិន្ត្រៃយ៍ដើម្បីប្រាស្រ័យទាក់ទងជាមួយនឹងអគ្គលេខធិការអាស៊ាននិងលេខាធិការដ្ឋាន។[៣៥]

**២. អគ្គលេខាធិការរង និងមន្ត្រីបុគ្គលិក**

អគ្គលេខាធិការរង គឺមានឋានៈជាអនុរដ្ឋមន្ត្រីហើយអគ្គលេខាធិការរង ត្រូវមានសញ្ជាតិខុសពីអគ្គលេខាធិការអាស៊ាន និងមកពីរដ្ឋសមាជិកអាស៊ានផ្សេងៗគ្នា។ អគ្គលេខាធិការរងទាំងនេះ មានមុខងារដូចខាងក្រោម៖

- អគ្គលេខាធិការរងអាស៊ានទទួលបន្ទុកកិច្ចការសហគមន៍សន្តិសុខ-នយោបាយអាស៊ាន ដែលត្រូវតែងតាំងចេញពីការសម្រេចរបស់រដ្ឋសមាជិកអាស៊ាន
- អគ្គលេខាធិការរងអាស៊ានទទួលបន្ទុកកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ានដែលត្រូវជ្រើសរើសតាមរយៈការដាក់ពាក្យស្នើសុំប្រឡងប្រជែងនៅលេខាធិការដ្ឋានអាស៊ាន
- អគ្គលេខាធិការរងអាស៊ានទទួលបន្ទុកកិច្ចការសហគមន៍សង្គម-វប្បធម៌អាស៊ានដែលត្រូវតែងតាំងចេញពីការសម្រេចរបស់រដ្ឋសមាជិកអាស៊ាន
- អគ្គលេខាធិការរងអាស៊ានទទួលបន្ទុកកិច្ចការសហគមន៍ និងកិច្ចការទូទៅដែលត្រូវជ្រើសរើសតាមរយៈការដាក់ពាក្យស្នើសុំប្រឡងប្រជែងនៅលេខាធិការដ្ឋានអាស៊ាន។

**អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីលេខាធិការដ្ឋានអាស៊ានត្រូវ៖**

- ប្រកាន់ខ្ជាប់នូវសុចរិតភាពខ្ពស់បំផុត, ប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន
- មិនស្វែងរកឬទទួលការណែនាំពីរដ្ឋាភិបាលនៃរដ្ឋសមាជិកអាស៊ាន ឬភាគីខាងក្រៅណាមួយក្រៅពីអាស៊ានឡើយ

[៣៥] Organization. Retrieved from https://www.mfaic.gov.kh/Ogranization.

- ជៀសវាងនូវរាល់សកម្មភាព ដែលអាចឆ្លុះបញ្ចាំងពីជំហររបស់ខ្លួនក្នុងនាមជាមន្ត្រីលេខាធិការដ្ឋានអាស៊ាន។[៣៦]

❖ **ការបម្រើការងាររបស់បុគ្គលិក និងការជ្រើសរើសបុគ្គលិក នៅលេខាធិការដ្ឋានអាស៊ាន**

នៅពេលដែលបង្កើតលេខាធិការអាស៊ានដំបូងឡើង គឺមានបុគ្គលិកចំនួនតែ ៨នាក់ប៉ុណ្ណោះ ត្រូវបានជ្រើសរើសឱ្យបម្រើការងារនៅទីនោះជាអាទិ៍អគ្គលេខាធិការអាស៊ាន, ប្រធានការិយាល័យចំនួន ៣រូប, បុគ្គលិកទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មបរទេស, បុគ្គលិករដ្ឋបាលទំនាក់ទំនងព័ត៌មានសាធារណៈ និងជំនួយការអគ្គលេខាធិការដ្ឋានអាស៊ាន។ គិតត្រឹមខែសីហា ឆ្នាំ២០២១ កន្លងមកលេខាធិការដ្ឋានអាស៊ានមានបុគ្គលិកសរុបចំនួន ៤០២នាក់ ក្នុងនោះមានបុគ្គលិកជ្រើសរើសដោយបើកចំហ( ORS) ចំនួន ១៤៥នាក់ និងបុគ្គលិកជ្រើសរើសក្នុងស្រុក( LRS) មានចំនួន២៥៧នាក់។ តាមការរំពឹងទុកនៅត្រឹមឆ្នាំ២០២៥ បុគ្គលិកលេខាធិការអាស៊ានអាចកើនឡើងរហូតដល់ចំនួន៤៦៩រូបក្នុងគោលដៅ ផ្តល់សេវាគាំទ្រដល់ការអនុវត្តសកម្មភាពការសាងសហគមន៍អាស៊ានប្រកបដោយប្រសិទ្ធភាព និងឱ្យកាន់តែស៊ីជម្រៅ។ ការជ្រើសរើសបុគ្គលិកសម្រាប់បម្រើការនៅលេខាធិការដ្ឋានអាស៊ានត្រូវបានធ្វើឡើងតាមរបៀប ២យ៉ាងដូចខាងក្រោម៖[៣៧]

➢ <u>ការជ្រើសរើសបុគ្គលិកដោយបើកចំហ</u>៖ ដោយធ្វើឡើងតាមរយៈការប្រកាសជាសាធារណៈក្នុងរដ្ឋសមាជិកទាំងអស់ និងបើកចំហសម្រាប់ជនជាតិនៃរដ្ឋសមាជិកទាំងអស់ ដែលមានសមត្ថភាពសមស្រប។ ឋានៈបុគ្គលិកដែលត្រូវជ្រើសរើសដោយបើកចំហមានជាអាទិ៍៖ អគ្គលេខាធិការរងអាស៊ាន, អគ្គលេខាធិការរងអាស៊ានទទួលបន្ទុកកិច្ចការសហគមន៍ និងកិច្ចការទូទៅ, នាយក, ជំនួយការនាយក, និងមន្ត្រីជាន់ខ្ពស់។

➢ <u>ការជ្រើសរើសបុគ្គលិកក្នុងស្រុក</u>៖ ត្រូវធ្វើការជ្រើសរើសបុគ្គលិកជាជនជាតិឥណ្ឌូនេស៊ី ឬជនជាតិនៃរដ្ឋសមាជិក ដែលកំពុងរស់នៅក្នុងប្រទេសឥណ្ឌូនេស៊ីប៉ុណ្ណោះ។ ឋានៈ និងតួនាទីបុគ្គលិក ដែលត្រូវជ្រើសរើសក្នុងស្រុក មានជាអាទិ៍៖

  - បុគ្គលិកវិជ្ជាជីវៈ៖ មន្ត្រីបច្ចេកទេស និងជំនួយការបច្ចេកទេស។
  - បុគ្គលិកឯកទេស៖ ជំនួយការហិរញ្ញវត្ថុ, លេខាប្រតិបត្តិ និងលេខា។

---

[៣៦] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផេទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៤៧/២៨៣

[៣៧]សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផេទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ៦១/២៨៣

- បុគ្គលិកការងារទូទៅ៖ ជំនួយការ, អ្នកទទួលទូរស័ព្ទ, អ្នកទទួលភ្ញៀវ, ស្មៀន, អ្នករត់សំបុត្រ, អ្នកបើកបរ និងសន្តិសុខ ជាដើម។

**៣. ទីតាំងរបស់លេខាធិការដ្ឋានអាស៊ាន**

ទីតាំងលេខាធិការដ្ឋាននេះត្រូវបានបង្កើតឡើងដំបូងគេនៅឆ្នាំ១៩៦៧ ដោយរដ្ឋសមាជិកអាស៊ានដំបូង ៥ រួមមាន  ឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីន, សិង្ហបុរី និងថៃ នៅក្នុងទីក្រុងបាងកកនៃប្រទេសថៃ។ មកដល់ពេលនេះលេខាធិការដ្ឋានអាស៊ានបច្ចុប្បន្ន មានមូលដ្ឋាននៅរដ្ឋធានីហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ដែលមានអគ្គលេខាធិការទទួលបន្ទុកសម្របសម្រួល និងអនុវត្តសកម្មភាពនានារបស់អាស៊ានលេខាធិការដ្ឋានអាស៊ានត្រូវបានប្តូរមកទីតាំងអចិន្ត្រៃយ៍បច្ចុប្បន្ននេះ ដោយផ្អែកតាមការឯកភាពរវាងរដ្ឋាភិបាលឥណ្ឌូនេស៊ី និងរដ្ឋសមាជិកអាស៊ាន ហើយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ក្រោមអធិបតីរបស់អតីតប្រធានាធិបតីឥណ្ឌូនេស៊ី ស៊ូហាតូ ដែលមានកម្ពស់៩ជាន់ និងមានផ្ទៃក្រឡាសរុប ១០.០០០ម$^{២}$។ ដោយអគារមានលក្ខណៈតូចចង្អៀត សម្រាប់រៀបចំកិច្ចប្រជុំឱ្យស្របតាមតម្រូវការនាពេលបច្ចុប្បន្ន និងកង្វះខាតបរិក្ខារប្រើប្រាស់ផងនោះ រដ្ឋាភិបាលឥណ្ឌូនេស៊ីបានចំណាយថវិកា ៣៨លានដុល្លាអាមេរិកសម្រាប់សាង់សង់អគារលេខាធិការដ្ឋានអាស៊ានថ្មីដែលមានរូបរាង្គជាអគារភ្លោះ និងមានកម្ពស់១៦ជាន់ និងមានផ្ទៃក្រឡាសរុប ៤០.០៤ម$^{២}$។ ដើម្បីចូលរួមរំលឹកខួបទី៥២ឆ្នាំនៃថ្ងៃបដិសន្ធិអាស៊ាននៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ឯកឧត្តមប្រធានាធិបតីរបស់ឥណ្ឌូនេស៊ី ចូកូវីដូដូ បានចូលរួមសម្ពោធអគារលេខាធិការដ្ឋានអាស៊ានថ្មីនេះ។

# ជំពូកទី៣
# ទំនាក់ទំនងរវាងអាស៊ានជាមួយ និងមជ្ឈដ្ឋានខាងក្រៅ

ទំនាក់ទំនងរវាងអាស៊ានជាមួយ និងមជ្ឈដ្ឋានខាងក្រៅ ត្រូវបានបែងចែកជាប្រាំផ្នែកធំៗ។ ដោយផ្នែកនីមួយៗ មានដូចតទៅ៖សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ Treaty of Amity and Cooperation in Southeast Asia-TAC(ផ្នែកទី១), ប្រតិបត្តិការដឹកនាំកិច្ចប្រជុំអាស៊ាន និងប្រទេសជាដៃគូអន្តរជាតិ(ផ្នែកទី២), វេទិកានៅក្នុងតំបន់អាស៊ាន(ផ្នែកទី៣), កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក ASEAN Defence Minister's Meeting- ADMM-Plus(ផ្នែកទី៤), និងកិច្ចប្រជុំរវាងអាស៊ាន និងក្រុមតំបន់ផ្សេងៗ (ផ្នែកទី៥)។

**ផ្នែកទី១. សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍**(Treaty of Amity and Cooperation in Southeast Asia-TAC)

សន្ធិសញ្ញាមិត្តភាពនេះ គឺជាសន្ធិសញ្ញាមិត្តសន្តិភាព ដែលត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ១៩៧៦ ដោយរដ្ឋសមាជិកអាស៊ាន(ឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីន, សិង្ហបុរី និងថៃ) ដើម្បីបង្កើតទំនាក់ទំនងអន្តររដ្ឋនៅក្នុងតំបន់លើកកម្ពស់សន្តិភាព និងសហប្រតិបត្តិការយូរអង្វែងក្នុងចំណោមរដ្ឋហត្ថលេខី។

ក្នុងសន្ធិសញ្ញានេះដែល គឺមានគោលបំណងដើម្បីលើកម្ពស់សន្តិភាព មិត្តភាព និងសហប្រតិបត្តិការយូរអង្វែងក្នុងចំណោមប្រជាជនដែលអាចចូលរួមដល់ភាពរឹងមាំសាមគ្គីភាព និងទំនាក់ទំនងកាន់តែជិតស្និទ្ធ។ ចំណែកឯគោលបំណងសំខាន់ៗ នៃសន្ធិសញ្ញានេះ មានដូចជា៖[៣៨]

- គោរពគ្នាទៅវិញទៅមក ចំពោះឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋទាំងអស់
- សិទ្ធិរដ្ឋនីមួយៗក្នុងការដឹកនាំជាតិរបស់ខ្លួន ដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅវិទ្ធង្សនា ឬការបង្ខិតបង្ខំ។
- មិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋណាមួយ
- ដោះស្រាយការខ្វែងគំនិតគ្នា ឬវិវាទដោយសន្តិវិធី
- បដិសេដការគំរាមគំហែង ឬការប្រើប្រាស់កម្លាំង
- ធ្វើកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព ក្នុងចំណោមរដ្ឋទាំងនោះ។

[៣៨] Priority of Cooperation. Retrieved from https:/asean.org/our-communities/asean-political security-community/outward-looking-community/treaty-of-amity-and-cooperation-in-southeast-asia-tac/

### ១. ទំនាក់ទំនងរវាងអាស៊ាន និងអន្តរជាតិ

ក្រៅពីការរឹតបន្តឹងទំនាក់ទំនងរវាងប្រទេសដែលជាសមាជិកទាំងអស់សមាគមអាស៊ានក៏បានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងសហគមន៍អន្តរជាតិផងដែរជាពិសេស គឺបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនឬស្ថិតនៅត្រង់ភូមិសាស្ត្រនយោបាយសំខាន់ៗ ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍនៅក្នុងតំបន់ពង្រឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ អាស៊ានបាន និងកំពុងភ្ជាប់ទំនាក់ទំនងជាមួយដៃគូខាងក្រៅក្នុងទំរង់ជាសហប្រតិបត្តិការនិងភាពជាដៃគូតាមរយៈដំណើរការ និងយន្តការជាច្រើនដែល ដឹកនាំដោយអាស៊ាន។ នៅក្នុងការសហការប្រតិបត្តិនោះដែលមានអាស៊ានបូក និងអាស៊ានដក ដែលសហការប្រតិបត្តិជាមួយនិងប្រទេសដទៃទៀតដូចជា៖ អត្ថន័យអាស៊ាន(បូក និងដក)[៣៩]

- អាស៊ានបូក៖
  - អាស៊ាន+១ មានន័យថា៖ សមាជិកអាស៊ានទាំង១០+១ (ប្រទេសឥណ្ឌា) India
  - អាស៊ាន+២: សមាជិកអាស៊ាន១០+ ២ (ញូហ្សេឡែន និងអូស្ត្រាលី) Newzealand, Australia
  - អាស៊ាន+៣: សមាជិកអាស៊ាន១០+ ៣ (ចិន ជប៉ុន និងកូរ៉េ) China, Japan, South Korea
  - អាស៊ាន+៦: សមាជិកអាស៊ាន១០+ ៦ ឬហៅថា៖ ASEAN Plus Six (ចិន, ជប៉ុន, និងកូរ៉េខាងត្បូង) China, Japan, South Korea (ឥណ្ឌា, អូស្ត្រាលី, និងញូហ្ស៊ីឡែន) India, Australia, Newzealand
- អាស៊ានដក៖
  - អាស៊ាន-៦មានន័យថា៖ សមាជិកអាស៊ាន៥ដំបូង+១ (ប្រុយណេ) Brunei
  - អាស៊ាន-៧: សមាជិកអាស៊ាន៦+១ (វៀតណាម) Vietnam
  - អាស៊ាន-៩: សមាជិកអាស៊ាន៧+១ (ភូមាឬមីយ៉ាន់ម៉ា និងឡាវ) Myanmar, Laos
  - អាស៊ាន-១០: សមាជិកអាស៊ាន+១ (កម្ពុជា) Cambodia

<u>សម្គាល់</u>: ដោយសារប្រទេសមីយ៉ាន់ម៉ា និងឡាវចូលជាសមាជិកក្នុងថ្ងៃតែមួយ(២៤ កក្កដា ១៩៩៧) ដូច្នេះពុំមានអាស៊ាន-៨នោះទេ។

## ផ្នែកទី២. ប្រតិបត្តិការដឹកនាំកិច្ចប្រជុំអាស៊ាន និងប្រទេសជាដៃគូអន្តរជាតិ

### ១. កិច្ចប្រជុំអាស៊ានបូក១

អាស៊ានបូកមួយ សំដៅលើសមាជិកអាស៊ានទាំង ១០ប្រទេសបូកជាមួយនឹងប្រទេសឥណ្ឌា។ ទំនាក់ទំនងរវាងអាស៊ាន និងឥណ្ឌាមានការរីកចម្រើនយ៉ាងច្រើនយ៉ាងឆាប់រហ័សពីភាពជាដៃគូនៅតាមវិស័យនានាក្នុងឆ្នាំ១៩៩២ មកជាដៃគូពេញសិទ្ធិក្នុង ខែធ្នូ ឆ្នាំ១៩៩៥។ ក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី១៣ ដែល

[៣៩] https://www.facebook.com/hrtrainingsolution/posts/1059548497588159/

ប្រារព្ធឡើងនៅក្រុងគូឡាឡាំពួ ថៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ មេដឹកនាំរបស់អាស៊ានបានស្វាគមន៍យ៉ាងកក់ក្តៅនូវគំនិតផ្តួចផ្តើមរបស់ប្រទេសឥណ្ឌាស្តីពីសកម្មភាពគោលនយោបាយបូព៌ា ហើយក៏បានកត់សម្គាល់ឃើញថាគំនិតផ្តួចផ្តើមមួយនេះ នឹងជួយពង្រឹងកិច្ចខំប្រឹងប្រែងកសាងសហគមន៍អាស៊ានឱ្យកាន់តែមានភាពប្រសើរឡើង។ ហេតុដូច្នេះ មេដឹកនាំរបស់អាស៊ានបានលើកទឹកចិត្តប្រទេសឥណ្ឌាឱ្យមកសហការជាមួយអាស៊ានដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់អំពីចក្ខុវិស័យ និងគោលដៅអាស៊ានក្នុងឆ្នាំ២០២៥។ ប្រទេសឥណ្ឌាបានជួយពង្រឹងសន្តិភាព សុវត្ថិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដោយយល់ព្រមចុះសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងអាស៊ីអាគ្នេយ៍( TAC )នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៣ ក្នុងកិច្ចប្រជុំកំពូលអាស៊ាន ឥណ្ឌា លើកទី២ នៅក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។ ក្នុងឱកាសជាមួយគ្នានេះដែរអាស៊ាន និងឥណ្ឌាបានចុះហត្ថលេខាលើសេចក្តីប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើភេរវកម្មអន្តរជាតិ។[៤០]

កិច្ចប្រជុំកំពូលអាស៊ានបូក១ គឺអនុលោមតាមគោលការណ៍ណែនាំស្តីពីទំនាក់ទំនងដៃគូខាងក្រៅរបស់អាស៊ាន, អាស៊ាននិងដៃគូសន្ទនាទាំងអស់អាចរៀបចំកិច្ចប្រជុំកំពូលរៀងរាល់ (ជាទៀងទាត់) បានផ្អែកតាមការព្រមព្រៀងគ្នា។ ប្រទេសដែលមានកិច្ចប្រជុំកំពូលរៀងរាល់ឆ្នាំជាមួយអាស៊ាន មានអាទិ៍៖ អូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, សាធារណៈរដ្ឋកូរ៉េ, សហរដ្ឋអាមេរិក, និងអង្គការសហប្រជាជាតិ។ ក្រៅពីនេះ ប្រទេសដៃគូសន្ទនាអាស៊ានផ្សេងៗ ទៀតអាចស្នើសុំរៀបចំកិច្ចប្រជុំកំពូលជាមួយអាស៊ានតាមការចាំបាច់ និងការព្រមព្រៀងរួមគ្នាប៉ុណ្ណោះរួមមាន កាណាដា, សហភាពអឺរ៉ុប, នូវ៉ែលសេឡង់, និងរុស្ស៊ី។ យោងតាមសេចក្តីថ្លែងការរួមមេដឹកនាំនៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុបឆ្នាំ២០២២មេដឹកនាំទទួលស្គាល់នូវផលប្រយោជន៍ជាយុទ្ធសាស្ត្រគ្នានៃការរក្សាការចូលរួមកម្រិតមេដឹកនាំជាទៀងទាត់រវាងអាស៊ាន និងសហភាពអឺរ៉ុប ហើយទន្ទឹមរង់ចាំការសម្រេចចិត្តលើកិច្ចប្រជុំកំពូលទៀងទាត់រវាងអាស៊ាន និងសហភាពអឺរ៉ុបក្នុងឆ្នាំ២០២៣។

កិច្ចប្រជុំនេះមានការចូលរួមដោយប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ាន និងប្រមុខរដ្ឋ/រដ្ឋាភិបាលប្រទេសដៃគូសន្ទនាអាស៊ាន។ មានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ដែលឯកភាពជាមុន ដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានអាទិ៍៖ ការពិនិត្យកន្លងមក និងលើកទិសដៅអនាគត។ ធ្វើជាសហប្រធានដោយប្រមុខរដ្ឋ/រដ្ឋាភិបាលនៃរដ្ឋសមាជិកជាប្រធានអាស៊ាន និងប្រមុខរដ្ឋ/រដ្ឋាភិបាលនៃប្រទេស ដៃគូសន្ទនាជាមួយអាស៊ាន។ កិច្ចប្រជុំកំពូលអាស៊ាននេះជាធម្មតាអាចរៀបចំធ្វើឡើងនៅខែតុលា ឬខែវិច្ឆិកា នៃឆ្នាំនីមួយៗ។ [៤១]

[៤០]សៀវភៅឈ្វេងយល់ សិក្សាអំពីអាស៊ាន បោះពុម្ពលើកទី២ (របស់ក្រុមអ្នកសរសេរហាតប៊ុក) ទំព័រ៨៦

[៤១] ASEAN-EU 2022 Anniversary Summit: Joint Leaders' Statement. Retrieved from https://asean.org/wp-content/uploads/2022/12/Final-ASEAN-EU-Commemorative-Summit- 2022- Joint Leaders- Statement.pdf

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូក១ ឬសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសដៃគូសន្ទនា គឺត្រូវបានអនុលោមតាមគោលការណ៍នៃនាំស្ដីពីទំនាក់ទំនងដៃគូខាងក្រៅរបស់អាស៊ាន, អាស៊ាន និងប្រទេសដៃគូសន្ទនាទាំងអស់អាចរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយដៃគូសន្ទនារៀងរាល់ឆ្នាំ (ជាទៀងទាត់) បានអាស្រ័យដោយការព្រមព្រៀងរួមគ្នា។ ប្រទេសដែលមានកិច្ចប្រជុំនេះជារៀងរាល់ឆ្នាំជាមួយអាស៊ានមានអាទិ៍៖ អូស្ត្រាលី, កាណាដា, ចិន, សហភាពអឺរ៉ុប, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្សី, ចក្រភពអង់គ្លេស, និងសហរដ្ឋអាមេរិក។ សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយចក្រភពអង់គ្លេសលើកទី១ ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ នៃប្រទេសកម្ពុជា។ កិច្ចប្រជុំនេះមានការចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសនៃប្រទេសដៃគូសន្ទនាអាស៊ាននៅក្នុងប្រទេសរដ្ឋសមាជិកជាប្រធានអាស៊ាន។ ដោយក្នុងនោះ គឺមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទ ដែលឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកអាស៊ានជាប្រទេសសម្របសម្រួលសម្រាប់ទំនាក់ទំនងដៃគូសន្ទនារវាងអាស៊ាន និងដៃគូសន្ទនានោះ។ រដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកអាស៊ាន ដែលជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនា ត្រូវបានធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ។ ជាធម្មតា កិច្ចប្រជុំកំពូលនេះអាចរៀបចំធ្វើនៅក្នុងខែកក្កដា ឬខែសីហានៃឆ្នាំនីមួយៗ។ [៤២]

> ➢ **តួនាទីសំខាន់ៗនៃប្រទេសសម្របសម្រួលរវាងអាស៊ាន និងប្រទេសដៃគូសន្ទនា**

តួនាទីសំខាន់នេះ គឺត្រូវបានអនុលោមតាមគោលការណ៍អាស៊ាន តំណាងឱ្យអាស៊ានដើម្បីពង្រឹងទំនាក់ទំនងជាមួយប្រទេសដៃគូសន្ទនា ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក និងសមភាព។ ប្រាស្រ័យទាក់ទង និងសម្របសម្រួលក្នុងនាមជាអាស៊ានជាមួយប្រទេសដៃគូសន្ទនា, អង្គការតំបន់, និងអង្គការអន្តរជាតិពាក់ព័ន្ធ។ ធ្វើសហប្រធាន និងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំពាក់ព័ន្ធរួមទាំងសិន្នសីទកិច្ចប្រជុំក្រោយរដ្ឋមន្ត្រីការបរទេសរវាងអាស៊ាន និងប្រទេសដៃគូសន្ទនា, អង្គការតំបន់ និងអង្គការអន្តរជាតិពាក់ព័ន្ធ រួមទាំងការរៀបចំកម្មវិធីសកម្មភាព, ដំណើរការកច្ចិប្រជុំ, កំណត់ត្រា, សេចក្ដីថ្លែងការណ៍សហប្រធាន ឬសេចក្ដីថ្លែងការណ៍ព័ត៌មាននៃកិច្ចប្រជុំ។ ធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រទេសជាប្រធានអាស៊ាន និងសន្ទនាដៃគូសន្ទនាពាក់ព័ន្ធដើម្បីរៀបចំការងារដែលចាំបាច់ទាំងអស់ជាអាទិ៍៖ ការកំណត់ប្រធានបទពិភាក្សា និងឯកសារលទ្ធផលនៃកិច្ចប្រជុំកំពូលរលឹកខួបអនុស្សាវរីយ៍រវាងអាស៊ាន និងដៃគូសន្ទនាពាក់ព័ន្ធ។[៤៣]

---

[៤២]សៀវភៅស្ដីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១២៣/២៨៣

[៤៣] សៀវភៅស្ដីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១២៦/២៨៣

ពិនិត្យ និងវាយតម្លៃទៅលើទំនាក់ទំនងជាទៀងទាត់ក្នុងគោលបំណងកំណត់បញ្ហា និងផ្តល់អនុសាសន៍ដើម្បីជំរុញទំនាក់ទំនងឱ្យកាន់តែប្រសើរ។ ផ្តួចផ្តើម និងសម្របសម្រួលគម្រោងសហប្រតិបត្តិការ និងសកម្មភាពលេខាធិការដ្ឋានអាស៊ាន និងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសដៃគូសន្ទនា, អង្គការតំបន់ និងអង្គការអន្តរជាតិពាក់ព័ន្ធ។ រៀបចំរបាយការណ៍ស្តីពីបច្ចុប្បន្នភាព និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការសកម្មភាពអនុសាសន៍ពាក់ព័ន្ធអាណត្តិ និងការសម្រេចចិត្តផ្សេងៗ សម្រាប់ដាក់ជូនកិច្ចប្រជុំពាក់ព័ន្ធរវាងអាស៊ាន និងប្រទេសដៃគូសន្ទនាអង្គការតំបន់ និងអង្គការអន្តរជាតិពាក់ព័ន្ធ។ នៅចុងបញ្ចប់នៃអាណត្តិការងារសម្របសម្រួលរបស់ខ្លួនត្រូវរៀបចំកំណត់ហេតុ និងប្រគល់កំណត់ត្រាស្តីពីការពិនិត្យឡើងវិញនូវទំនាក់ទំនងគូសបញ្ជាក់សំខាន់ៗដែលមិនទាន់សម្រេចបានបញ្ហាត្រូវតាមដានបន្តនិងអនុសាសន៍ស្តីពីទំនាក់ទំនងសន្ទនាជាមួយប្រទេសដៃគូសន្ទនាអង្គការតំបន់ និងអង្គការអន្តរជាតិពាក់ព័ន្ធផ្ទេរទៅប្រទេសសម្របសម្រួលបន្ទាប់។ គាំទ្រដោយគណៈកម្មការធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន( CPR)ស្ថាប័នរដ្ឋមន្ត្រីតាមវិស័យអាស៊ានពាក់ព័ន្ធ, លេខាធិការដ្ឋានអាស៊ាន និងគណៈកម្មាធិការអាស៊ានក្នុងប្រទេសទីបីពាក់ព័ន្ធ និងអង្គការអន្តរជាតិផ្សេងៗទៀត។ អនុវត្តមុខងារផ្សេងៗទៀត តាមការកំណត់ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM)។

### ២. កិច្ចប្រជុំអាស៊ានបូក២

អាស៊ានបូកពីរ សំដៅទៅដល់ប្រទេសដែលជាសមាជិកអាស៊ានទាំង១០បូកជាមួយនឹងប្រទេអូស្ត្រាលី និងប្រទេសនូវែលសេឡង់។ ការធ្វើកិច្ចសហប្រតិបត្តិការមួយនេះបានជួយអាស៊ានឱ្យទទួលបាននូវចំណេះវិជ្ជាដើម្បីអភិវឌ្ឍសហគមន៍របស់ខ្លួន ជួយឱ្យមានភាពរីកចម្រើនលើវិស័យបច្ចេកវិទ្យានិង ធនធានមនុស្សទៀតផង។ បន្ថែមពីនេះ អាស៊ាននឹងមានទីផ្សារពាណិជ្ជកម្មកាន់តែធំទូលាយ ទាំងវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងបច្ចេកវិទ្យាផ្សេងៗទៀត។[៤៤]

### ៣. កិច្ចប្រជុំអាស៊ានបូក៣

អាស៊ានបូកបី ( ASEAN +3 )មានន័យថាសមាជិកអាស៊ានទាំង ១០ប្រទេសបូកជាមួយនឹងប្រទេសដែលមិនមែនជាសមាជិកអាស៊ានដែលមានចំនួនបីផ្សេងៗទៀតគឺ ប្រទេសចិន ជប៉ុន និងប្រទេសកូរ៉េខាងត្បូង។ កិច្ចសហប្រតិបត្តិការអាស៊ានបូកបីបានចាប់ផ្តើមដំណើរការនៅខែធ្នូ ឆ្នាំ១៩៩៧ នាឱកាសកិច្ចប្រជុំកំពូលក្រៅផ្លូវការលើកទីពីរ រវាងមេដឹកអាស៊ាននិងសាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និង សាធារណរដ្ឋកូរ៉េ ( កូរ៉េខាងត្បូង ) ដែលបានប្រព្រឹត្តទៅនៅក្នុងប្រទេសម៉ាឡេស៊ី។ ក្រោយមក កិច្ចប្រជុំកំពូលអាស៊ានបូកបីត្រូវបានបង្កើតឡើងជាផ្លូវការក្នុងឆ្នាំ១៩៩៩ នៅពេលដែលមេដឹកនាំនៃប្រទេសអាស៊ានបូកបីទាំងអស់បានចេញសេចក្តី

[៤៤] សៀវភៅឈ្វេងយល់ សិក្សាអំពីអាស៊ាន បោះពុម្ពលើកទី២ (របស់ក្រុមអ្នកសរសេរហោតប៊ុក) ទំព័រ៨៧

ថ្លែងការណ៍រួមគ្នាមួយស្តីពីកិច្ចសហប្រតិបត្តិការអាស៊ីបូព៌ា នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបីរបស់ពួកគេដែលត្រូវបានរៀបចំធ្វើឡើងនៅក្រុងម៉ានីល ( Manila ) ប្រទេសហ្វីលីពីន។ នៅក្នុងសេចក្តីថ្លែងការណ៍រួមមេដឹកនាំអាស៊ានបូកបី បានបង្ហាញអំពីគោលជំហរនៃការដោះស្រាយនិងពង្រឹងវិស័យផ្សេងៗ នៅក្នុងកិច្ចសហប្រតិបត្តិការអាស៊ីបូព៌ា ជាពិសេសក្នុងវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងវិស័យផ្សេងៗទៀត។

កិច្ចប្រជុំនេះចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសចិន, ជប៉ុន, និងសាធារណរដ្ឋកូរ៉េ។ ក្នុងកិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ ការពិនិត្យឡើងវិញលើកិច្ចសហប្រតិបត្តិការរវាងអាស៊ានបូកបីកន្លងមក និងលើកទិសដៅអនាគត, ការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់អន្តរជាតិ និងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានបូក៣។

រដ្ឋមន្ត្រីការបរទេសរដ្ឋសមាជិកដែលជាប្រធានអាស៊ាន និងរដ្ឋមន្ត្រីការបរទេសជាប្រធានក្នុងចំណោមប្រទេសត្រីភាគី( ចិន, ជប៉ុន, និងសាធារណរដ្ឋកូរ៉េ ) ត្រូវធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ។ ជាធម្មតាកិច្ចប្រជុំកំពូលនេះអាចរៀបចំធ្វើក្នុងខែកក្កដា ឬខែសីហានៃឆ្នាំនីមួយៗ នៅក្នុងកម្មវិធីអមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនិងសន្និសញ្ញាក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសដៃគូសន្ទនាអាស៊ាន។

ដៃគូសន្ទនា គឺជាឋានៈផ្លូវការមួយរបស់រដ្ឋដែលមិនមែនជាសមាជិកអាស៊ាន ដែលត្រូវបានផ្តល់ឱ្យដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដើម្បីឱ្យរដ្ឋនោះអាចអនុវត្តនូវកិច្ចសហប្រតិបត្តិការជាមួយនឹងសមាគមមួយនេះដោយផ្អែកលើការសម្រេចចិត្តរួមនឹងការធ្វើផែនការរួមគ្នាផ្តោតលើកម្មវិធីធំៗ ហើយផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដែលកត្តាទាំងនេះនឹងជះឥទ្ធិពលវិជ្ជមានដល់ការអភិវឌ្ឍតំបន់ភូមិភាគអាស៊ីអាគ្នេយ៍និង ការរីតបន្តឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។

- **កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូក៣**
    - កិច្ចប្រជុំនេះចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ។
    - មានគោលបំណងពិភាក្សាអំពី បញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានអាទិ៍៖ ការពិនិត្យឡើងវិញលើកិច្ចសហប្រតិបត្តិការរវាងអាស៊ានបូកបីកន្លងមក និងលើកទិសដៅអនាគត, ការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់និងអន្តរជាតិ និងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានបូក៣។

- រដ្ឋមន្ត្រីការបរទេសរដ្ឋសមាជិកដែលជាប្រធានអាស៊ាន និងរដ្ឋមន្ត្រីការបរទេសជាប្រធានក្នុងចំណោមប្រទេសត្រីភាគី (ចិន, ជប៉ុន និងសាធារណរដ្ឋកូរ៉េ) ត្រូវធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ។
- ជាធម្មតាកិច្ចប្រជុំកំពូលនេះអាចរៀបចំធ្វើក្នុងខែកក្កដា ឬខែសីហា នៃឆ្នាំនីមួយៗនៅក្នុងកម្មវិធីអមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសដៃគូសន្ទនាអាស៊ាន។

➢ **កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានបូក៣**

- កិច្ចប្រជុំនេះចូលរួមដោយឧត្តមមន្ត្រីអាស៊ាន និងឧត្តមមន្ត្រីចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ។
- មានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ តាមដានការអនុវត្តការសម្រេចនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបីកន្លងមក (ផែនការការងារសហប្រតិបត្តិការអាស៊ានបូកបី និងតាមដានការងារនៃក្រុមទស្សនវិស័យអាស៊ីបូព៌ា),ការផ្លាស់ប្តូរទស្សនៈគ្នាទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិការត្រៀមរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូក៣ និងកិច្ចប្រជុំកំពូលអាស៊ានបូក៣។
- ឧត្តមមន្ត្រីអាស៊ាននៃរដ្ឋសមាជិកប្រធានអាស៊ាន និងឧត្តមមន្ត្រី ដែលជាប្រធានក្នុងចំណោមប្រទេសត្រីភាគី (ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ) ត្រូវធ្វើជាសហប្រធាននៃកិច្ចប្រជុំនេះ។
- កិច្ចប្រជុំនេះអាចរៀបចំធ្វើឡើងពីរដងក្នុងមួយឆ្នាំ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសបូកបី និង កិច្ចប្រជុំកំពូលអាស៊ានបូកបី។

➢ **កិច្ចប្រជុំគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ានបូកបី**

- កិច្ចប្រជុំរវាងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ាន និងឯកអគ្គរាជ/រដ្ឋទូតចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េខាងត្បូងប្រចាំអាស៊ាននៅហ្សាការតា។
- មានគោលបំណងសម្របសម្រួល និងតាមដានដំណើរការនិងសកម្មភាពរបស់អាស៊ានបូកបីដើម្បីជំរុញសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធ។
- ពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាជាមុនមានជាអាទិ៍៖ តាមដានការងារកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានបូកបីកន្លងមករួមទាំងស្ថានភាពការងារកិច្ចសហប្រតិបត្តិការអាស៊ានបូកបី, ស្ថានភាពមូលនិធិសហប្រតិបត្តិការអាស៊ានបូកបី, ការរៀបចំកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានបូកបី និងកិច្ចប្រជុំរដ្ឋមន្ត្រីបរទេសអាស៊ានបូកបី ជាដើម។
- តំណាងអចិន្ត្រៃយ៍នៃរដ្ឋសមាជិកអាស៊ានជាប្រធានអាស៊ាន និងឯកអគ្គរាជ/រដ្ឋទូតប្រចាំអាស៊ានដែលជាប្រធាននៃប្រទេសត្រីភាគី( ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ) ត្រូវធ្វើសហប្រធានកិច្ចប្រជុំ។

- ត្រូវរៀបចំយ៉ាងតិចមួយដង ក្នុងមួយឆ្នាំឬតាមតម្រូវការចាំបាច់ដែលស្នើឡើងដោយអាស៊ាន និងប្រទេសបូកបី។

➢ **កិច្ចប្រជុំក្រុមការងារគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ានបូកបី**

- កិច្ចប្រជុំចូលរួមដោយតំណាងអចិន្ត្រៃយ៍រង ឬអនុប្រធានស្ថានបេសកកម្ម ឬមន្ត្រីការទូតនៃស្ថានបេសកកម្មរដ្ឋជាសមាជិកអាស៊ានប្រចាំហ្សាការតា និងអនុប្រធានស្ថានបេសកកម្មនៃប្រទេសបូកបីរួមមាន ប្រទេសចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ។
- មានគោលបំណងពិភាក្សាអំពីបញ្ហានានាពាក់ព័ន្ធលក្ខណៈបច្ចេកទេសសហប្រតិបត្តិការ អាស៊ានបូកបី និងលើកអនុសាសន៍ជូនកិច្ចប្រជុំគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ានបូកបីដើម្បីពិនិត្យ និងសម្រេច។
- តំណាងអចិន្ត្រៃយ៍រង ឬអនុប្រធានស្ថានបេសកកម្មរដ្ឋសមាជិកអាស៊ានជាប្រធានអាស៊ាន និងអនុប្រធានស្ថានបេសកកម្មប្រចាំអាស៊ានដែលជាប្រធានប្រទេសត្រីភាគី ( ចិន ជប៉ុន និងសាធារណកូរ៉េខាងត្បូង ) ត្រូវធ្វើជាសហប្រធានកិច្ចប្រជុំ។
- ត្រូវរៀបចំយ៉ាងទៀងទាត់ ១ដងក្នុងមួយឆ្នាំ ឬតាមតម្រូវការចាំបាច់ដែលស្នើឡើងដោយអាស៊ាន និងប្រទេសបូកបី។

### ៤. កិច្ចប្រជុំអាស៊ានបូក៦

នាថ្ងៃទី០៩ ខែឧសភា វង់ចរចារដំបូងឆ្ពោះទៅការបង្កើតកិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចតំបន់លើគ្រប់វិស័យ ( RCEP )រវាងប្រទេសជាសមាជិកអាស៊ានចំនួន១០ ជាមួយដៃគូសេដ្ឋកិច្ចសំខាន់របស់ប្លុកចំនួន ៦ ប្រទេសគឺ៖ ចិន, ជប៉ុន, សាធាណរដ្ឋកូរ៉េខាងត្បូង, អ៊ូស្ត្រាលី, នូវ៉ែលហ្សេឡង់, និងឥណ្ឌាហៅថា( អាស៊ាន+៦ )បានចាប់ផ្តើមជាផ្លូវការនៅប្រទេសប្រ៊ុយណេ។ RCEP គឺជាប្លុកពាណិជ្ជកម្មសេរីធំបំផុត១ក្នុងចំណោមប្លុកពាណិជ្ជកម្មសេរីលើសកលលោក។ តាមគំរោងក្នុងរយៈពេល ៥ថ្ងៃជួបចរចារអាស៊ាន+៦ នឹងពិភាក្សាអំពីរបៀបនិងក្របខ័ណ្ឌនៃការចរចារ RCEP សំដៅទទួលបានការព្រមព្រៀងនាឆ្នាំ២០១៥។ ក្រៅពីការបង្កើតគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់មួយអាស៊ាន+៦ នឹងបង្កើតបណ្តាក្រុមការងារដែលទាក់ទិនដល់សកម្មភាពផ្លាស់ប្តូរពាណិជ្ជកម្មសេវាកម្មនិងការវិនិយោគ។ បើសិនជា RCEP ត្រូវបានបង្កើតប្រកបដោយជោគជ័យនោះគឺតំបន់ពាណិជ្ជកម្មសេរីមានមនុស្សចំនួន៣ ពាន់លាននាក់ស្រូបយក១/២ទីផ្សារសកលលោកនិង១/៣ទិន្នផលសេដ្ឋកិច្ចសកល។ [៤៥]

[៤៥]https://vovworld.vn/km-KH/search/%E1%9E%A2%E1%9E%B6%E1%9E%9F%E1%9F%8A%E1% 9E%B6%E1 % 9E %93+%E1%9F%A6.vov

កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ (RTAS) អាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការពង្រីកពាណិជ្ជកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់។ នៅពាក់កណ្តាលឆ្នាំ២០១០ មានកិច្ចព្រមព្រៀងចំនួន៤៧៤ ត្រូវបានជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ហើយ២៨៣ នៃកិច្ចព្រមព្រៀងទាំងនេះបានចូលជាធរមាន។ ក្នុងចំណោមកិច្ចសហប្រតិបត្តិការអាស៊ានបូកបី (បន្តបន្ទាប់ APT) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់មួយ។ APT សំដៅលើកិច្ចសហប្រតិបត្តិការរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ទី១(អាស៊ាន)និងប្រជាជាតិអាស៊ីបូព៌ាទាំងបីគឺចិន ជប៉ុន និងកូរ៉េខាងត្បូង។ ជាងនេះទៅទៀតក្នុងឆ្នាំ២០០៥ អាស៊ានបូកបី(ASEAN+៣) ត្រូវបានពង្រីកដើម្បីរួមបញ្ចូលប្រទេសចំនួនបីបន្ថែមទៀតគឺ អូស្ត្រាលី ឥណ្ឌា និងនូវែលសេឡង់។ នេះជាលទ្ធផលដែលគេហៅថាអាស៊ានបូក៦។[៤៦]

ជាក់ស្តែង កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរវាងអាស៊ាន និងបណ្តាប្រទេស “បូកប្រាំមួយ” ត្រូវបានចុះហត្ថលេខារួចហើយ ហើយបានចូលជាធរមានសម្រាប់អាស៊ាន-ចិន តាំងពីឆ្នាំ២០០៥ សម្រាប់អាស៊ាន-ជប៉ុន តាំងពីឆ្នាំ២០០៨ សម្រាប់អាស៊ាន-អូស្ត្រាលី-នូវែលសេឡង់អាស៊ាន។ ឥណ្ឌា និងអាស៊ានកូរ៉េ (សាធារណរដ្ឋកូរ៉េខាងត្បូង) ចាប់តាំងពីឆ្នាំ២០១០។ ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរវាងអាស៊ាន និងប្រទេសជាដៃគូទាំងប្រាំមួយនឹងបម្រើជាបណ្តុំសម្រាប់ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ីបូព៌ា (EAFTA) ដែលអាចធ្វើទៅបានក្នុងពេលដ៏ខ្លីខាងមុខនាពេលអនាគត។ ដោយសារអត្រាពន្ធទាបដែលមានស្រាប់នៅក្នុងប្រទេសមួយចំនួននៃអាស៊ាន+៦ វាគួរឱ្យចាប់អារម្មណ៍ក្នុងការសួរថាតើមានកន្លែងខ្លះសម្រាប់ការពង្រឹងលំហូរពាណិជ្ជកម្មនៃសមាជិករបស់ខ្លួន។

គោលបំណងចម្បងនៃឯកសារនេះ គឺវាយតម្លៃផលប្រយោជន៍ជាសក្តានុពលនៃការបង្កើតអាស៊ាន+៦។ នេះត្រូវបានធ្វើជាពីរជំហាន។ ទីមួយ យើងប្រើប្រាស់ទិន្នន័យបន្ទះស្តីពីលំហូរនាំចេញទ្វេភាគីដើម្បីវិភាគជាក់ស្តែងអំពីកត្តាកំណត់ពាណិជ្ជកម្មអន្តរជាតិរបស់អាស៊ាន និងដៃគូទាំងប្រាំមួយរបស់ខ្លួន។ កាន់តែច្បាស់ជាងនេះទៅទៀតការសិក្សាផ្តោតលើរបៀប ដែលអំណោយទានកត្តា ទាក់ទងភាពខុសគ្នាទំហំប្រទេសទ្វេភាគីភាពស្រដៀងគ្នានៃទំហំប្រទេសថ្លៃដឹកជញ្ជូន និងអត្រាពន្ធកំណត់ពាណិជ្ជកម្មទ្វេភាគីក្នុងអាស៊ាន+៦។ បន្ទាប់មកការសិក្សានេះធ្វើការវិភាគក្លែងធ្វើដើម្បីវាយតម្លៃពីសក្តានុពលនៃការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសនីមួយៗ។[៤៧]

[៤៦] Sithanonxay Suvannaphakdy, Toshihisa Toyoda, and Chris Czerkawski, Graduate School of Economic Sciences Hirhoshima Shudo University, Japan

[៤៧] https://www.academia.edu/download/68210015/Enhancing_Trade_Flows_in_ASEAN_Plus_Six20210720-23828-1g8ddn0.pdf

**៥. កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ឬអាស៊ានបូក៨**( East Asia summit-EAS)

អស់រយៈពេលប្រាំទសវត្សរ៍មកនេះ អាស៊ានជាស្ថាប័នប្រចាំតំបន់តែមួយគត់នៅអាស៊ីបូព៌ា។ ក្នុងអំឡុងពេលភាគច្រើននៃអត្ថិភាពរបស់វា វាត្រូវបានផ្តោតយ៉ាងទូលំទូលាយនៅក្នុងនិងនៅលើអាស៊ីអាគ្នេយ៍។ ទោះយ៉ាងណាក៏ដោយនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ស្ថានភាពបានចាប់ផ្តើមផ្លាស់ប្តូរវដ្តអាស៊ីបានចាប់ផ្តើមពិសោធន៍ជាមួយយន្តការ និងដំណើរការក្នុងតំបន់ថ្មីហើយអាស៊ានបានចាប់ផ្តើមទទួលយកចក្ខុវិស័យកាន់តែទូលំទូលាយនៃតួនាទីក្នុងតំបន់របស់ខ្លួន។ ទាំងនេះគឺជាដំណើរការបំពេញបន្ថែមពេលខ្លះការបង្កើតអាស៊ានបូកបី (APT) និងវេទិកាតំបន់អាស៊ាន (ARF) ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ គឺជាធាតុផ្សំដំបូងនៃការចូលរួមពីខាងក្រៅ។ អង្គការនេះបានដឹងថានៅក្នុងតំបន់អាស៊ីបូព៌ាដែលមានទំនាក់ទំនងគ្នាកាន់តែខ្លាំងឡើង ផលប្រយោជន៍របស់សមាជិកអាស៊ីអាគ្នេយ៍របស់ខ្លួន នឹងកាន់តែមានរូបរាងឡើងដោយព្រឹត្តិការណ៍ដែលកើតឡើងនៅខាងក្រៅសង្កាត់ និងជាពិសេសដោយប្រទេសចិនដែលកំពុងកើនឡើងជាងពួកគេដោយសារកិច្ចការផ្ទៃក្នុង។ ជាងនេះទៅទៀត វាគឺជាកម្លាំងរុញច្រានទាំងនេះ ដើម្បីបង្កើតរចនាសម្ព័ន្ធស្ថាប័នដែលមានប្រយោជន៍សម្រាប់តំបន់ផ្លាស់ប្តូរ និងចូលរួមជាមួយមហាអំណាចតាមរបៀបដែលរក្សាបាននូវ "ភាពជាកណ្តាល" របស់អាស៊ាន ដែលនាំទៅដល់ការបង្កើតកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) ក្នុងឆ្នាំ ២០០៥។

ទោះបីជាក្រុមសមាជិកចំនួន ១៦នាក់មានសក្តានុពលសន្ធឹកសន្ធាប់ក្នុងការដើរតួនាទីឈានមុខក្នុងតំបន់ក៏ដោយ ក៏នេះមិនទាន់ត្រូវបានសម្រេចនៅឡើយទេ។ មូលហេតុមួយផ្នែកគឺថាការកំណត់ថ្នាក់តំបន់ឥឡូវនេះមានភាពរលូននិងមានការប្រកួតប្រជែង។ ប៉ុន្តែវាក៏ទាក់ទងទៅនឹងភាពតានតឹងជាមូលដ្ឋានផងដែរនៅពេលដែលអាស៊ានព្យាយាមរៀបចំរបៀបវារៈនៅក្នុងក្រុមដែល វាលើសពីសមាជិកដែលមិនមែនជាសមាជិកអាស៊ាន។ អត្ថបទនេះស្វែងយល់ពីបញ្ហាទាំងនេះ ហើយអះអាងថាសមត្ថភាពរបស់ EAS ក្នុងការសម្រេចបាននូវមហិច្ឆតាដែលមនុស្សជាច្រើនមាន ដើម្បីឱ្យវាក្លាយជាស្ថាប័នកំពូលសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ទំនងជាមានការខកចិត្តចំពោះសណ្តាប់ធ្នាប់ក្នុងតំបន់ដែលមានការប្រកួតប្រជែងកាន់តែខ្លាំងឡើងរបស់អាស៊ី។

EAS មានគុណលក្ខណៈមួយចំនួនដែលសម្គាល់វាចេញពីគំនិតផ្តួចផ្តើមក្នុងតំបន់ផ្សេងទៀត។ ទីមួយវាមានការផ្ញើប្រាក់ "ទាំងមូលនៃរដ្ឋាភិបាល" ។ មិនដូច ADMM-Plus ដែលត្រូវបានប្រគល់ភារកិច្ចជាមួយកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ ឬដំណើរការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (APEC) ដែលមានការដកប្រាក់ផ្នែកសេដ្ឋកិច្ចផ្តាច់មុខនោះទេ EAS មានគោលបំណងជំរុញកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយនឹងគោលបំណងដ៏ខ្ពង់ខ្ពស់នៃ " ការលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅអាស៊ីបូព៌ា។ ទីពីរ វាជាដំណើរការដែលដឹកនាំដោយអ្នកដឹកនាំ។ ខណៈពេលដែលវាកំពុងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័នអំប្រីយ៉ុង EAS នៅតែផ្តោតលើការប្រជុំរបស់មេដឹកនាំរដ្ឋាភិបាល។ នេះជាផ្នែកមួយនៃការ

បង្ហាញពីមហិច្ឆិតាសម្រាប់កិច្ចប្រជុំកំពូលដើម្បីឈានមុខគេនៅក្នុងតំបន់ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីការពិតផងដែរ ដែលនៅក្នុងរដ្ឋអំណាច មានរឿងមួយចំនួនដែលមានតែមេដឹកនាំអាចធ្វើបាន។ ទីបី សមាជិកភាពរបស់ខ្លួនរួមមានបណ្តាលប្រទេសសំខាន់ៗទាំងអស់ដែលជាចំណុចកណ្តាលនៃកិច្ចការអន្តរជាតិរបស់អាស៊ីបូព៌ា។ APEC ត្រូវបានរារាំងដោយការពង្រីកលឿនពេកដែលសមាជិកភាពចម្រុះពេកខ្វះផលប្រយោជន៍រួមគ្រប់គ្រាន់។ គំនិតនៃតំបន់ប៉ាស៊ីហ្វិកនៃតំបន់អាស៊ីនៃទសវត្សរ៍ឆ្នាំ១៩៩០ ឥឡូវនេះហាក់ដូចជាមានការយល់ច្រឡំ។[៤៨]

ជាការពិតណាស់ អាស៊ានគឺជាចំណុចកណ្តាលនៃ EAS ។ ជាការពិត នេះនៅតែជាគុណលក្ខណៈសំខាន់ទោះបីជាវាជាប្រភពនៃភាពតានតឹងផ្ទៃក្នុងក៏ដោយ។ ដូចដែលយើងបានឃើញជាមួយនឹង "សហគមន៍អាស៊ីប៉ាស៊ីហ្វិក" ដែលទើបនឹងកើតរបស់ Kevin Rudd ក្នុងឆ្នាំ ២០០៨-២០០៩ កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញពហុភាគីនិយមក្នុងតំបន់នៅតែបន្តទាមទារការគាំទ្រពីអាស៊ាន។ កន្លែងនៅកណ្តាលនៃស្ថាបត្យកម្មក្នុងតំបន់ដែលកំពុងរីកចម្រើន។ វាគឺជាការលាយបញ្ចូលគ្នានៃគោលនយោបាយនេះ កម្រិតដែលវាជួបប្រជុំគ្នាទម្រង់សមាជិកភាព និងទំនាក់ទំនងរបស់ខ្លួនជាមួយអាស៊ាន ដែលផ្តល់នូវសក្តានុពលដ៏សន្ធឹកសន្ធាប់ជាក្រុម។[៤៩]

កិច្ចប្រជុំកំពូលអាស៊ានអាស៊ីបូព៌ា គឺជាកិច្ចប្រជុំកំពូលដែលចូលរួមដោយប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ាន និងប្រមុខរដ្ឋ/រដ្ឋាភិបាលប្រទេសដៃគូអាស៊ានចំនួន ៨ប្រទេសទៀតរួមមានដូចៈ ប្រទេសអូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។ ដំណើរការនៃកិច្ចប្រជុំនេះត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ២០០៥ នៅទីក្រុងគូឡាឡាំពួ។

អាស៊ានបានកំណត់លក្ខណៈវិនិច្ឆ័យមួយចំនួនសម្រាប់ប្រទេសមិនមែនជាអាស៊ាន ដែលមានបំណងសុំចូលជាសមាជិកកិច្ចប្រជុំនេះរួមមានដូចជា៖

- ប្រទេសដៃគូសន្ទនាពេញលេញរបស់អាស៊ាន
- បានចូលជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញា និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍ ឬបង្ហាញបំណងចូលរួម

[៤៨]Bisley, Nick. "The East Asia summit and ASEAN: Potential and Problems." *Contemporary Southeast Asia: A Journal of International and Strategic Affairs* 39, no. 2 (2017): 265-272. muse.jhu.edu/article/667775.

[៤៩] TY - JOUR T1 - The East Asia summit and ASEAN: Potential and Problems A1 - Bisley, Nick JF - Contemporary Southeast Asia: A Journal of International and Strategic Affairs VL - 39 IS - 2 SP - 265 EP - 272 PY - 2017 PB - ISEAS–Yusof Ishak Institute SN - 1793-284X UR - https://muse.jhu.edu/pub/70/article/667775 N1 - Volume 39, Number 2, August 2017 ER -

- មានទំនាក់ទំនងល្អប្រសើរជាមួយនឹងអាស៊ាន។[៥០]

ប្រទេសមួយចំនួនទៀត ក៏បានស្នើសុំចូលជាសមាជិកកិច្ចប្រជុំកំពូលអាស៊ីបូព៌ានេះផងដែល។ ប៉ុន្តែអាស៊ានបានឯកភាពគ្នាផ្អាកទទួលប្រទេសមិនមែនអាស៊ាន ជាសមាជិកកិច្ចប្រជុំកំពូលនេះដោយសារតែមានបំណងចង់បន្តពង្រឹងទំនាក់ទំនងជាមួយប្រទេសជាសមាជិកដែលមានស្រាប់សិន។

កិច្ចប្រជុំកំពូលអាស៊ីបូព៌ាជាវេទិការដឹកនាំដោយប្រមុខរដ្ឋ/រដ្ឋាភិបាលកំពូលសម្រាប់ការសន្ទនា និងសហប្រតិបត្តិការលើយុទ្ធសាស្ត្រដ៏ទូលំទូលាយ, បញ្ហានយោបាយ និងសេដ្ឋកិច្ចដែលជាកង្វល់ និងអត្ថប្រយោជន៍រួមក្នុងគោលបំណងលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពសេដ្ឋកិច្ចនៅអាស៊ីបូព៌ា។

កិច្ចប្រជុំនេះបានរិះរកការពង្រឹងវិស័យសហប្រតិបត្តិការចំនួន៦ ជាអាទិ៍៖ បរិស្ថាន និងថាមពល, អប់រំ, ហិរញ្ញវត្ថុ, បញ្ហាសុខភាព សកលនិងជំងឺរាតត្បាត, ការគ្រប់គ្រងគ្រោះមហន្តរាយ និងការតភ្ជាប់អាស៊ាន។

កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាមុនដោយរដ្ឋសមាជិកដែលជាប្រធានអាស៊ានរួមមានការដោះស្រាយលេចចេញថ្មីៗបញ្ហាដែលជាកង្វល់និងអត្ថប្រយោជន៍រួមនិងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិ។

ប្រមុខរដ្ឋ/រដ្ឋាភិបាលនៃរដ្ឋសមាជិក ជាប្រធានអាស៊ានត្រូវធ្វើជាប្រធាននៅក្នុងកិច្ចប្រជុំនោះ។ ជាធម្មតារដ្ឋសមាជិកជាប្រធានអាស៊ានអាចអញ្ជើញប្រទេសផ្សេងៗ ដែលបានស្នើសុំឬអញ្ជើញដោយប្រធានអាស៊ានផ្ទាល់យោងលើការឯកភាពពីប្រទេសសមាជិកអាស៊ាន ចូលរួមជាភ្ញៀវរបស់ប្រធានអាស៊ាននៅក្នុងសម័យប្រជុំបើកកិច្ចប្រជុំកំពូលអាស៊ីបូព៌ាដោយត្រូវធ្វើបទបង្ហាញលើប្រធានបទជាក់លាក់មួយដែលបានឯកភាពគ្នាមុន។

ជាធម្មតា កិច្ចប្រជុំកំពូលនេះអាចរៀបចំធ្វើក្នុងខែតុលា ឬខែវិច្ឆិកានៃឆ្នាំនីមួយៗនៅក្នុងកម្មវិធីអមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលអាស៊ានពាក់ព័ន្ធ។[៥១]

### ក. កិច្ចប្រជុំមន្ត្រីការបរទេសនៃកិច្ចប្រជុំអាស៊ីបូព៌ា

កិច្ចប្រជុំនេះចូលរួមដោយមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេសនៃប្រទេសដៃគូអាស៊ានចំនួន៨ប្រទេសទៀតរួមមាន៖ ប្រទេសអូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។ មានគោលបំណងពិភាក្សអំពីបញ្ហាជាក់លាក់/ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ ការពិនិត្យឡើងវិញលើសហប្រតិបត្តិការនៃកិច្ចប្រជុំកំពូលអាស៊ី

[៥០] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៣៨/២៨៣

[៥១] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៤០/២៨៣

បូព៌ាកន្លងមក និងកំណត់ទិសដៅអនាគតការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិ និងការត្រៀមរៀបកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។[៥២]

រដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកជាប្រធានអាស៊ាន ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំ។ ជាធម្មតា កិច្ចប្រជុំនេះអាចរៀបចំធ្វើក្នុងខែកក្កដា ឬខែសីហា នៃឆ្នាំនីមួយៗក្នុងកម្មវិធីអមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួប្រទេសដៃគូសន្ទនា។

### ខ. កិច្ចប្រជុំឧត្តមមន្ត្រីនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា

កិច្ចប្រជុំនេះចូលរួមដោយឧត្តមមន្ត្រីអាស៊ាន និងឧត្តមមន្ត្រីនៃប្រទេសដៃគូអាស៊ានចំនួន ៨ប្រទេសទៀត រួមមានដូចជា៖ ប្រទេសអូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។ ដែលមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ប្រធានបទដែលបានឯកភាពគ្នាពីមុន ដោយការអនុវត្តសេចក្តីសម្រេចនានា នៃកិច្ចប្រជុំសកម្មភាពប្រជុំកំពូលអាស៊ីបូព៌ាកន្លងមករបាយការណ៍វឌ្ឍនភាពស្តីពីផែនការសកម្មភាពការងារជំរុញកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសកិច្ចប្រជុំអាស៊ីបូព៌ា ការស្នើឯកសារលទ្ធកិច្ចប្រជុំភៀវកិច្ចប្រជុំកំពូល ការផ្លាស់ប្តូរទន្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាបរទេសអាស៊ាន និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។

ឧត្តមមន្ត្រីរបស់អាស៊ាននៃរដ្ឋសមាជិកជាប្រធានអាស៊ាន ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំនោះ។ កិច្ចប្រជុំអាចរៀបចំធ្វើឡើងពីរដងក្នុងមួយឆ្នាំ ដើម្បីត្រៀមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។

### គ. កិច្ចប្រជុំឯកអគ្គរាជ/រដ្ឋទូតអាស៊ីបូព៌ាប្រចាំហ្សាការតា

ជាកិច្ចប្រជុំរវាងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ាន និងឯកអគ្គរាជ/រដ្ឋទូតប្រទេសអូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។ មានការចូលរួមពីប្រទេសទាំងអស់ចំនួន១៨ ប្រទេស។ ដែលមានគោលបំណងពង្រឹងសហប្រតិបត្តិការ ដើម្បីធានាថាកិច្ចប្រជុំកំពូលអាស៊ីបូព៌ានៅតែជាវេទិកា ដែលដឹកនាំដោយប្រមុខរដ្ឋ/រដ្ឋាភិបាលកំពូលសម្រាប់សន្ទនា និងសហប្រតិបត្តិការយុទ្ធសាស្ត្រដ៏ទូលំទូលាយដែលជាកង្វល់ និងអត្ថប្រយោជន៍រួមលើបញ្ហាសេដ្ឋកិច្ច និងនយោបាយ។ ម៉្យាងទៀតវាក៏នឹងជួយសម្របសម្រួលការអនុវត្តគំនិតផ្តួចផ្តើមសេចក្តីសម្រេចនានារបស់ប្រមុខរដ្ឋ/រដ្ឋាភិបាល នៃប្រទេចូលរួមកិច្ចប្រជុំកំពូលអាស៊ីបូព៌ាផងដែរ។

[៥២] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផលទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៤១/២៨៣

តំណាងអចិន្ត្រៃយ៍ នៃរដ្ឋសមាជិកជាប្រធានអាស៊ានត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំនោះ។ កិច្ចប្រជុំអាចរៀបចំធ្វើឡើង ៣ដង ក្នុងមួយឆ្នាំ ឬច្រើនជាងនេះអាស្រ័យលើការឯកភាពគ្នា។

**ផ្នែកទី៣. វេទិកានៅក្នុងតំបន់អាស៊ាន**

វេទិកានេះបានចាប់ផ្តើមដំបូងនៅខែកក្កដា ឆ្នាំ១៩៩៤ បន្ទាប់ពីបានទទួលការឯកភាពដោយកិច្ចប្រជុំមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនៅថ្ងៃទី២៣-២៥ ខែកក្កដា ឆ្នាំ១៩៩៣។

នៅក្នុងកិច្ចប្រជុំនេះផងដែរ គឺមានគោលបំណងសំខាន់ក្នុងការបង្កើតវេទិកាតំបន់អាស៊ាននេះ គឺ៖

- ជំរុញកិច្ចសន្ទនាប្រកបដោយស្ថាបនា និងពិគ្រោះយោបល់លើបញ្ហានយោបាយ និងសន្តិសុខដែលជាកង្វល់និងអត្ថប្រយោជន៍រួម
- ចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការកសាងទំនុកចិត្ត និងការបង្ការការទូតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ពាក្យសុំចូលជាសមាជិកថ្មីនៃវេទិកានេះត្រូវដាក់ជូនប្រធាន នៃវេទិកាដែលជាប្រធានអាស៊ាន ហើយត្រូវពិគ្រោះយោបល់ជាមួយសមាជិកនៃវេទិកាទាំងអស់នៅកម្រិតឧត្តមមន្ត្រី ដើម្បីបញ្ជាក់ថាមានការឯកភាព ឬគ្មានការឯកភាពទទួលសមាជិកថ្មីនោះ។ ការសម្រេចជាក់ស្តែង លើការចូលរួមត្រូវអនុម័តដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន។ វេទិកានេះមានកិច្ចប្រជុំតែពីរប៉ុណ្ណោះ គឺរដ្ឋមន្ត្រីការបរទេស និងឧត្តមមន្ត្រី។[៩៣]

**១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃវេទិកាតំបន់អាស៊ាន**

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃវេទិកាតំបន់អាស៊ាន គឺជាស្ថាប័នធ្វើសេចក្តីសម្រេចខ្ពស់បំផុត។ ជាកិច្ចប្រជុំដែលចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីប្រទេសចំនួន១៧ ប្រទេសផ្សេងទៀតរួមមាន៖ អូស្ត្រាលី, បង់ក្លាដែស, កាណាដា, ចិន, កូរ៉េខាងជើង, សហភាពអឺរ៉ុប, ឥណ្ឌា, ជប៉ុន, ម៉ុងហ្គោលី, នូវែលសេឡង់, ប៉ាគីស្ថាន, ប៉ាពូញ៉ូវ-ហ្គីណេ, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, ស្រីលង្កា, ទីម័រខាងកើត, និងសហរដ្ឋអាមេរិក។

កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋជាសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ ការពិនិត្យឡើងវិញលើសកម្មភាពវេទិកាតំបន់អាស៊ាន, និងការអនុម័តសេចក្តីសម្រេចប្រកាសផ្សេងៗនៃវេទិកាតំបន់អាស៊ាន និងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិ។ [៩៤]

[៩៣]សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៤៤/២៨៣

[៩៤]ASEAN Regional Forum. Retrieved from http://aseanregionalforum.asean.org/about-arf/.

រដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកជាប្រធានអាស៊ាន ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំ។ ជាធម្មតា កិច្ចប្រជុំនេះ គឺអាចរៀបចំធ្វើឡើងនៅក្នុងខែកក្កដា ឬខែសីហា នៃឆ្នាំនីមួយៗដែលស្របនឹងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ជាមួយប្រទេសជាដៃគូសន្ទនាអាស៊ានប្រចាំឆ្នាំ។[៥៥]

រដ្ឋអាស៊ានបានដើរតួនាទីកណ្តាលនៅក្នុងរបបសន្តិសុខអាស៊ីប៉ូស៊ីហ្វិក។ ជាសជាងផ្តោតលើការដោះស្រាយបញ្ហា ឬការចរចា វេទិកាតំបន់អាស៊ាន (ARF) ឈរជាដំណើរការពិគ្រោះយោបល់មួយ ដើម្បីបន្ថែមអត្ថប្រយោជន៍នៃការចូលរួមក្នុងន័យស្ថាបនា៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងស្ថិរភាព។ ការបង្កើតរបស់ខ្លួនរំលឹកឡើងវិញនូវការព្រួយបារម្ភផ្ទាល់ខ្លួនរបស់អាស៊ានសម្រាប់ការកសាងមតិឯកភាព និងការយល់ដឹងទ្វេភាគីក្នុងការរៀបចំសម្រាប់កិច្ចខិតខំប្រឹងប្រែងពហុភាគី។ រដ្ឋដូចជាអាស៊ានត្រូវបានអំពាវនាវឱ្យអនុវត្តការអត់ធ្មត់ដោយខ្លួនឯងដោយការលះបង់កម្លាំង និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃទៀត។ ជាងនេះទៅទៀតដើម្បីសម្រេចបាននូវស្ថិរភាពក្នុងតំបន់តាមរយៈសមតុល្យនៃមហាអំណាច រដ្ឋអាស៊ានជារឿយៗបានជួយសម្រួលដល់ការដាក់បញ្ចូលទាំងអស់តាមរយៈទំនាក់ទំនងការទូតក្រៅផ្លូវការដែលកំណត់កាតព្វកិច្ច និងពិធីសារ។[៥៦]

## ២. កិច្ចប្រជុំឧត្តមមន្ត្រីនៃវេទិកាតំបន់អាស៊ាន

កិច្ចប្រជុំនេះចូលរួមដោយឧត្តមមន្ត្រីអាស៊ាន និងឧត្តមមន្ត្រីនៃប្រទេស ១៧ផ្សេងទៀត ដែលជាសមាជិកវេទិកាតំបន់អាស៊ានរួមមាន៖ អូស្ត្រាលី, បង់ក្លាដែស, កាណាដា, ចិន, កូរ៉េខាងជើង, សហភាពអឺរ៉ុប, ឥណ្ឌា, ជប៉ុន, ម៉ុងហ្គោលី, នូវែលសេឡង់, ប៉ាគីស្ថាន, ប៉ាពួញូវ-ហ្គីណេ, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, ស្រីលង្កា, ទីម័រខាងកើត, និងសហរដ្ឋអាមេរិក។ កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ប្រធានបទ ដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ ពិនិត្យឡើងវិញលើសកម្មភាពរបស់វេទិកាតំបន់អាស៊ាន, ការអភិវឌ្ឍនៃការពិភាក្សាអំពីសេចក្តីប្រកាសផ្សេងៗ នៃវេទិកាតំបន់អាស៊ាន, ការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិនិងការត្រៀមរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសវេទិកាតំបន់អាស៊ាន។ ឧត្តមមន្ត្រីអាស៊ាននៃរដ្ឋសមាជិកជាប្រធានអាស៊ាន ត្រូវធ្វើជាប្រធានកិច្ចប្រជុំនេះ។ កិច្ចប្រជុំនេះអាចរៀបចំធ្វើឡើងនៅក្នុងខែមិថុនា នៃខែឆ្នាំនីមួយៗផងដែរ។ [៥៧]

---

[៥៥]សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៤៥/២៨៣

[៥៦]The ASEAN Regional Forum: The Spirit of Constructive EngagementMICHAEL ANTOLIK*Contemporary Southeast Asia*, Vol. 16, No. 2 (September 1994), pp. 117-136 (20 pages)

[៥៧]សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៤៦/២៨៣

## ផ្នែកទី៤. កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក( ASEAN Defence Minister's Meeting-ADMM-Plus )

### ១. កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក

កិច្ចប្រជុំនេះបានរៀបចំលើកដំបូងនៅថ្ងៃទី១២ ខែតុលា ឆ្នាំ ២០១០ នៅប្រទេសវៀតណាម។ ចាប់ពីឆ្នាំ ២០១៧មកកិច្ចប្រជុំនេះត្រូវបានរៀបចំធ្វើជារៀងរាល់ឆ្នាំដើម្បីឱ្យមានការពង្រឹងកិច្ចសន្ទនា និងសហប្រតិបត្តិការ ក្នុងចំណោមអាស៊ាននិងប្រទេសបូកនៅចំពេលដែរស្ថានការណ៍សន្តិសុខក្នុងតំបន់កាន់តែមានការប្រកួតប្រជែង។ កិច្ចប្រជុំនេះបានក្លាយជាវេទិកាដ៏មានប្រសិទ្ធភាពសម្រាប់សហប្រតិបត្តិការជាក់ស្តែង ក្នុងចំណោមស្ថាប័នការពារប្រទេសរបស់ប្រទេសចូលរួម។ ផ្តោតលើសហប្រតិបត្តិការក្នុងវិស័យចំនួន ៧ រួមមាន៖ សន្តិសុខលំហសមុទ្រ, ការប្រឆាំងភេរវកម្ម, ជំនួយមនុស្សធម៌និងការគ្រប់គ្រងគ្រោះមហន្តរាយ, ប្រតិបត្តិការរក្សាសន្តិភាព ,ឱសថយោធា, សកម្មភាពមនុស្សធម៌អំពីមីន និងសន្តិសុខតាមអ៊ីនធឺណេត។

គោលការណ៍គ្រឹះសំខាន់ៗសម្រាប់ចូលជាសមាជិកកិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូករួមមាន៖

១. ត្រូវតែជាដៃគូ សន្ទនាពេញសិទ្ធិរបស់អាស៊ាន

២. មានអន្តរកម្មនិងទំនាក់ទំនង សំខាន់ៗក្នុងវិស័យការពារប្រទេសអាស៊ាន

៣. ត្រូវសហការចូលរួមក្នុងការកសាងសមត្ថភាព ដើម្បីបង្កើនសន្តិសុខក្នុងតំបន់លើវិស័យការពារប្រទេស និងសន្តិសុខ តាមមធ្យោបាយសំខាន់ៗ។[៥៨]

កិច្ចប្រជុំនេះចូលរួមដោយរដ្ឋមន្ត្រីការពារប្រទេសអាស៊ាន និងរដ្ឋមន្ត្រីការពារប្រទេសចំនួន៧ ផ្សេងទៀត រួមមាន៖ អូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។

កិច្ចប្រជុំនេះ មានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់/ប្រធានបទដែល បានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ាន មានជាអាទិ៍៖ ការផ្លាស់ប្តូរទស្សនៈស្តីពី បញ្ហាសន្តិសុខ និងការពារ ប្រទេសក្នុងតំបន់ និងអន្តរជាតិ, ការស្ម័គ្រចិត្តក្នុងការបង្ហាញពីគោលនយោបាយការពារប្រទេស និងសន្តិសុខ, ពិភាក្សាអំពីវិស័យសហប្រតិបត្តិការលើបញ្ហាសន្តិសុខដែលអាចប៉ះពាល់ដល់តំបន់ជាពិសេសបញ្ហាប្រឈមដល់សន្តិសុខប្រពៃណី និងសន្តិសុខមិន ប្រពៃណី ដូចជា ភេរវកម្ម សន្តិសុខលំហសមុទ្រ និងជំនួយ មនុស្សធម៌ និងជំនួយសង្គ្រោះគ្រោះមហន្តរាយ។

រដ្ឋមន្ត្រីការពារប្រទេសនៃរដ្ឋសមាជិកជាប្រធានកិច្ចប្រជុំរដ្ឋមន្តី ការពារប្រទេសអាស៊ានដែលជាប្រធានអាស៊ានត្រូវធ្វើជាប្រធាន នៃកិច្ចប្រជុំនេះ។ កិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូកចង្អៀត ឬកិច្ចប្រជុំបន្ទាន់អាចត្រូវរៀបចំឡើងតាមការចាំបាច់។ រដ្ឋមន្ត្រីការពារប្រទេសអាស៊ានគួររាយការណ៍ជូនប្រមុខរាជ/រដ្ឋាភិបាល

[៥៨]ASEAN Regional Forum. Retieved From https:/aseanregionalforum.asean.org/about-arf/.

តាមរយៈក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអំពីលទ្ធផលកិច្ចប្រជុំការពារប្រទេសអាស៊ានបូក។ កិច្ចប្រជុំនេះគាំទ្រដោយក្រុមការងារកិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសបូក (ADMM Plus Working Group)។

ប្រទេសដៃគូសន្ទនាអាស៊ានផ្សេងទៀត ក៏មានបំណងស្នើសុំចូល ជាសមាជិកកិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសបូកនេះដែរ។ ប៉ុន្តែក្នុងឆ្នាំ២០១៣ អាស៊ានបានឯកភាពរក្សាចំនួនសមាជិកដែល មានសម្រាប់នេះ ក្នុងគោលបំណងពង្រឹងសហប្រតិបត្តិការរវាងប្រទេសសមាជិកដែលមានស្រាប់ជាមុនសិន មុននឹងទទួលយកសមាជិកផ្សេងទៀត។ ជាធម្មតា កិច្ចប្រជុំនេះអាចរៀបចំធ្វើនៅក្នុងខែតុលា ឬខែវិច្ឆិកា នៃឆ្នាំនីមួយៗឬតាមការឯកភាពគ្នា។[៥៩]

**២. កិច្ចប្រជុំក្រុមការងាររដ្ឋមន្ត្រីការពារប្រទេសអាស៊ានបូក**(ASEAN Defence Ministerial Meeting Plus Working Group-ADMM Plus WG)

កិច្ចប្រជុំក្រុមការងារនេះចូលរួមដោយឧត្តមមន្ត្រីការពារប្រទេស អាស៊ាន និងឧត្តមមន្ត្រីការពារប្រទេសជាសមាជិកទាំងអស់ រួមមាន៖ អូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, នូវែលសេឡង់, សាធារណរដ្ឋកូរ៉េ, រុស្ស៊ី, និងសហរដ្ឋអាមេរិក។ កិច្ចប្រជុំនេះមានតួនាទីសម្របសម្រួលការអនុវត្តបញ្ហាផ្សេងៗ, កិច្ចព្រមព្រៀង និងសេចក្តីសម្រេចធ្វើឡើងដោយកិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសបូក។

មានគោលបំណងពិភាក្សា អំពីបញ្ហាជាក់លាក់/ប្រធានបទដែលបាន ឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រធានអាស៊ានមានជាអាទិ៍៖ ការផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាសន្តិសុខ និងការពារ ប្រទេសក្នុងតំបន់ និងអន្តរជាតិ, ការស្ម័គ្រចិត្តក្នុងការបង្ហាញពីគោលនយោបាយការពារប្រទេស និងសន្តិសុខ, ពិភាក្សាអំពីវិស័យកិច្ចសហប្រតិបត្តិការសម្រាប់បញ្ហាសន្តិសុខ ដែលអាចប៉ះពាល់ដល់តំបន់ ជាពិសេសបញ្ហាប្រឈមដល់សន្តិសុខប្រពៃណី និងសន្តិសុខមិនប្រពៃណីដូចជា ភេរវកម្ម សន្តិសុខលំហសមុទ្រ ជំនួយមនុស្សធម៌ និងជំនួយសង្គ្រោះគ្រោះមហន្តរាយ និងការត្រៀមរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការពារប្រទេសបូក។[៦០]

## ផ្នែកទី៥. កិច្ចប្រជុំរវាងអាស៊ាន និងក្រុមតំបន់ផ្សេងៗ

ជាការអនុវត្តជាក់ស្តែងកន្លងមក ការពង្រឹងទំនាក់ទំនងសហប្រតិបត្តិការរវាងអាស៊ាន និងក្រុមតំបន់ផ្សេងៗត្រូវធ្វើឡើងតាមរយៈតែក្នុងកម្រិតកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងកិច្ចប្រជុំជាមួយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ានប៉ុណ្ណោះ។

---

[៥៩] សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្ធផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៥០/២៨៣

[៦០] https://www.academia.edu/download/68610564/an-appraisal-of-asean-defence-ministers-meeting-admm- as- part-of-defence-diplomacy-initiative-for-conflict-resolution.pdf

## ១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីនៃក្រុមតំបន់ផ្សេងៗ

កិច្ចប្រជុំនេះចូលរួមដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រី នៃក្រុមតំបន់ផ្សេងៗ ដូចជាសម្ព័ន្ធភាពប៉ាស៊ីហ្វិក (PA), សហគមន៍ប្រទេសអាមេរិកឡាទីននិងការីប៊ីន (CELAC), ទីផ្សាររួមភាគខាងត្បូង (MERCOSUR), អង្គការសហប្រតិបត្តិការសៀងហៃ (SCO), សមាគមអាស៊ីខាងត្បូងសម្រាប់សហប្រតិបត្តិការក្នុងតំបន់ (SAARC), អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច (ECO) និង ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ (GCC)។

មានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ប្រធានបទ ដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រទេសសម្របសម្រួលទំនាក់ទំនងអាស៊ាន និងប្រធានតំណាងក្រុមតំបន់ផ្សេងៗរួមមាន៖ ពិនិត្យឡើងវិញលើសហប្រតិបត្តិការរវាងអាស៊ាន និង ក្រុមតំបន់នីមួយៗកន្លងមក និងលើកទិសដៅនាពេលអនាគត និងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកស្តីពីបញ្ហាតំបន់ និងអន្តរជាតិ។

រដ្ឋមន្ត្រីការបរទេសរដ្ឋសមាជិកអាស៊ានជាប្រទេសសម្របសម្រួលទំនាក់ទំនងអាស៊ាន និងប្រធានតំណាងក្រុមតំបន់ផ្សេងៗ ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំនេះ។

កិច្ចប្រជុំនេះអាចរៀបចំធ្វើនៅក្នុងខែកញ្ញានៃឆ្នាំនីមួយៗនៅក្នុង កម្មវិធីអមកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក អាស្រ័យតាមការឯកភាពគ្នា។

## ២. កិច្ចប្រជុំរវាងគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាននិងតំបន់ផ្សេងៗ

កិច្ចប្រជុំនេះចូលរួមដោយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍នៅ ទីក្រុងហ្សាការតា និងឯកអគ្គរាជ/រដ្ឋទូតនៃក្រុមតំបន់ផ្សេងៗ ដែលមានមូលដ្ឋាននៅទីក្រុងហ្សាការតា ឬប្រចាំរាជ/រដ្ឋធានី នៃរដ្ឋសមាជិកដទៃទៀត ដូចជា សម្ព័ន្ធភាពប៉ាស៊ីហ្វិក (PA), សហគមន៍ប្រទេសអាមេរិកឡាទីន និងការីប៊ីន (CELAC),ទីផ្សាររួមភាគខាងត្បូង (MERCOSUR), អង្គការសហប្រតិបត្តិការសៀងហៃ (SCO), សមាគមអាស៊ីខាងត្បូងសម្រាប់សហប្រតិបត្តិការក្នុងតំបន់ (SAARC), អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច (ECO) និងក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ (GCC)។

មានគោលបំណងពិភាក្សាអំពីបញ្ហាជាក់លាក់ប្រធានបទដែលបានឯកភាពគ្នាជាមុនដោយរដ្ឋសមាជិកជាប្រទេសសម្របសម្រួលទំនាក់ទំនងអាស៊ាន និងប្រធានតំណាងក្រុមតំបន់ផ្សេងៗមានជាអាទិ៍៖ ការវិវឌ្ឍន៍នៅក្នុងអាស៊ាន និងនៅក្រុមតំបន់ទាំងនោះ, ពិនិត្យឡើងវិញលើសហប្រតិបត្តិការរវាងអាស៊ាន និងក្រុមតំបន់នីមួយៗកន្លងមក និងលើកទិសដៅនាពេលអនាគតនិងត្រៀមសម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីដែលនៅក្នុងក្រុមតំបន់ផ្សេងៗនៅក្នុងកម្មវិធីអមកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងទី

ក្រុងញូវយ៉ក។ តំណាងអចិន្ត្រៃយ៍រដ្ឋសមាជិកអាស៊ាន គឺជាប្រធានសម្របសម្រួលទំនាក់ទំនងអាស៊ាន និង ប្រធានតំណាងក្រុមតំបន់ផ្សេងៗ ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំ។[៦១]

[៦១]សៀវភៅស្តីពី សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងកសារផទ្វផលសម្រាប់កិច្ចប្រជុំ អាស៊ានពាក់ព័ន្ធ ៖ របស់លោក សុខ ធា ទំព័រ១៥២/២៨៣

# សេចក្តីសន្និដ្ឋាន

ក្រោយពី ពួកយើងទាំងពីរបានខិតខំសិក្សាស្រាវជ្រាវបញ្ចប់ការសរសេរសារណាមួយនេះក្រោមប្រធានបទ "ដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអាស៊ាន " ពួកយើងយល់ឃើញថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ គឺជាសមាគមដ៏ធំមួយដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលគេនិយមហៅកាត់ថា "អាស៊ាន" ដែលមានបណ្តាប្រទេសជាច្រើនស្ថិតនៅក្នុងតំបន់អាស៊ីចូលជាសមាជិករបស់សមាគមអាស៊ាន។

ជាក់ស្តែង សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះបានបង្កើតច្បាប់សម្រាប់គ្រប់គ្រងច្បាស់លាស់ទៅលើប្រទេសដែលជាសមាជិករបស់អាស៊ានដោយបង្កើតឱ្យមានរដ្ឋធម្មនុញ្ញអាស៊ាន សម្រាប់ឱ្យសមាជិករបស់អាស៊ានត្រូវអនុវត្តតាមជាចាំបាច់។ លើសពីនេះទៅទៀត សមគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះបានរៀបចំឱ្យមានកិច្ចសហប្រតិបត្តិការណ៍ប្រជុំកំពូលរបស់អាស៊ានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជំនាញ និងការិយាល័យផ្សេងៗដែលទាក់ទងទៅនឹងសមាគមអាស៊ាន។ មិនតែប៉ុណ្ណោះទេ សមាគមអាស៊ានមួយនេះបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសដែលជាសមាជិករបស់អង្គការអាស៊ានដូចជា បានជួយឱ្យប្រទេសដែលជាសមាជិកទាំងអស់បញ្ចៀសពីជម្លោះផ្សេងៗដែលបង្កឱ្យមានសង្គ្រាម ដឹកដៃប្រទេសដែលជាសមាជិកទាំងអស់ក្នុងអង្គការអាស៊ានប្រកាន់ភ្ជាប់នូវសន្តិភាព ជួយឱ្យប្រទេសដែលជាសមាជិកទាំងអស់មានទំនាក់ទំនងល្អជាមួយនឹងគ្នា ដែលអាចឱ្យសមាជិកនៅក្នុងសមាគមអាស៊ានអាចធ្វើការចែករំលែកបទពិសោធន៍វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ សេដ្ឋកិច្ចឱ្យគ្នាទៅវិញទៅមក។ ជាងនេះទៅទៀតរាល់ការការសម្រេចចិត្តអ្វីមួយដែលទាក់ទងនឹងការសម្រេចដោគវាសនារបស់អង្គការអាស៊ាន គឺត្រូវធ្វើឡើងដោយឈរលើគោលការណ៍គ្រឹះរបស់សមាគមអាស៊ានគឺគោលការណ៍កុងសង់ស៊ីស មានន័យថាទាល់តែមានការសម្រេចយល់ស្របជាឯកចន្ទរបស់សមាជិករបស់អង្គការអាស៊ានទាំងអស់ទើបអាចធ្វើការសម្រេចចិត្តទៅបាន។ ម្យ៉ាងវិញទៀត រាល់បញ្ហាដែលកើតមាននៅក្នុងសមាគមអាស៊ានមួយនេះ គឺតែងតែមានកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំថ្នាករដ្ឋមន្ត្រីជំនាញ ដើម្បីដោះស្រាយបញ្ហាឬវិវាទផ្សេងៗដែលពាក់ព័ន្ធនឹងប្រទេសដែលជាសមាជិកអាស៊ានដោយសន្តិវិធី និងមិនលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសទាំងអស់ដែលជាសមាជិករបស់ខ្លួនជាដាច់ខាត។ លើសពីនេះទៅទៀត គេសង្កេតឃើញថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បាននឹងកំពុងខិតខំយ៉ាងសស្រាក់សស្រាំ ដើម្បីបន្តពង្រឹងដៃគូនិងកិច្ចសហប្រតិបត្តិការជាមួយប្រទេសខាងក្រៅតំបន់អាស៊ានជាបន្តបន្ទាប់។ តាមរយៈកិច្ចការសហប្រតិបត្តិការ និងយន្តការដឹកនាំរបស់សមាគមអាស៊ាននេះហើយ ទើបធ្វើឱ្យសមាគមមួយនេះមានកំណើន ដៃគូជាបន្តបន្ទាប់ដោយសារតែការកើនឡើងនៃការពាក់ព័ន្ធ និងសារៈសំខាន់របស់សមាគមអាស៊ាននៅក្នុង កិច្ចការតំបន់ និងពិភពលោកត្រូវការជាចាំបាច់។

សរុបសេចក្ដីមក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់និងបានផ្ដល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសទាំងអស់ដែលជាសមាជិករបស់សមាគមមួយនេះ ដែលប្រទេសដែលសមាជិកត្រូវការសមាគមនេះជាចាំបាច់ក្នុងការរួបរួមគ្នា បង្កើតទំនាក់ទំនងល្អជាមួយគ្នា ការចែករំលែកបទពិសោធន៍ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ សាសនានិងសេដ្ឋកិច្ចទៅឱ្យគ្នាទៅវិញទៅមកព្រមទាំងដឹកដៃគ្នានាំប្រទេសទាំងអស់ ដែលសមាជិកអាស៊ានមានការអភិវឌ្ឍនិងការរីកចម្រើនទៅមុខប្រកបដោយសេចក្ដីសុខសន្តិភាព និងសន្តិសុខសង្គម។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវអំពីសមាគមអាស៊ាន រួចមកយើងគ្នាឃើញថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ គឺជាសមាគមមួយដ៏ធំដែលមានបណ្ដាប្រទេសជាច្រើននៅក្នុងតំបន់អាស៊ីចូលជាសមាជិកសមាគមមួយនេះ។ ហើយក្នុងចំណោមប្រទេសទាំងអស់នោះក៏មានប្រទេសកម្ពុជាយើងផងដែរ ដែលក្នុងនាមយើងជាជនជាតិខ្មែរ ត្រូវតែយល់ដឹងសិក្សាស្រាវជ្រាវអំពីសហគមអាស៊ានមួយនេះឱ្យកាន់តែច្បាស់លាស់ជាងនេះទៀត ដែលយើងមិនអាចមើលរំលងបានឡើយ។ ជាចុងក្រោយបំផុត ដោយពួកយើងឃើញថាការអភិវឌ្ឍសង្គម គឺសេដ្ឋកិច្ចមួយអាចសម្រេចទៅបានដរាបណាតែសមាគមនោះមាន ស្ថិរភាព និងសុខសន្តិភាពពេញលេញ ដូច្នេះពួកយើងទាំងពីរសូមអនុញ្ញាតនូវអនុសាសន៍មួយចំនួនពាក់ព័ន្ធ និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដូចខាងក្រោម៖

- អាស៊ានត្រូវបង្កើតគោលការណ៍ច្បាប់បន្ថែមទៀត ដើម្បីឱ្យប្រទេសជាសមាជិកបញ្ចៀសនូវជម្លោះផ្សេងៗ ដែលបង្កឱ្យមានសង្គ្រាមដោយគ្មានអ្នកឈ្នះនិងអ្នកចាញ់។
- អាស៊ានត្រូវធ្វើខ្លួនជាតំបន់គាំទ្រដល់ប្រទេសដែលជាសមាជិកទាំងអស់ ដោយត្រូវរួបរួមគ្នាធានាឱ្យបាននូវសុខសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់អាស៊ានត្រូវពង្រឹងឯកភាព ដោយការប្រកាន់ភ្ជាប់ជានិច្ចនូវភាពជាដៃគូ និងយន្តការក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង។
- អាស៊ានត្រូវប្រកាន់ភ្ជាប់នូវភាពជាកណ្ដាល និងដើរតួនាទីយ៉ាងសំខាន់ជាវេទិការួមមួយសម្រាប់ការសន្ទនា និងកិច្ចសហប្រតិបត្តិការជាមួយនឹងការពង្រឹងតំបន់ផ្សេងៗ ដែលធ្វើឡើងជាលក្ខណៈបើកចំហមានតម្លាភាព បរិយាបន្នសង្គម និងយកច្បាប់ជាគោលមកអនុវត្ត។
- អាស៊ានត្រូវបង្កើតឱកាសការងារសម្រាប់ឱ្យប្រជាជន ដែលនៅក្នុងរដ្ឋជាសមាជិកអាចចូលបំពេញការងារក្នុងស្ថាប័នអាស៊ាន
- អាស៊ានត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើការលើកកម្ពស់សន្តិសុខសេដ្ឋកិច្ច ធានាការទទួលបានផលប្រយោជន៍ ពីកំណើនសេដ្ឋកិច្ចក្នុងប្រទេស និងក្នុងតំបន់តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយុទ្ធសាស្ត្រ និងការពង្រឹងសហគ្រិនអាស៊ានដឹកដៃរួមគ្នាជាមួយប្រទេសទាំងអស់ដែលជាសមាជិកដោយរួមគ្នា ចូលរួមអភិវឌ្ឍសមាគមមួយនេះឱ្យកាន់តែរីកចម្រើនប្រកប ដោយសមធម៌ និងផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីឱ្យជោគវាសនារបស់សមាគមអាស៊ានឱ្យក្នុងពិភពលោកបានស្គាល់កាន់តែច្បាស់។

# ឯកសារយោង

## ១.ច្បាប់

- ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ដែលបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨)

## ២. លិខិតបទដ្ឋានអន្តរជាតិ

- សេចក្តីថ្លែងការណ៍អាស៊ាន(សេចក្តីប្រកាសក្រុងបាងកក)ទីក្រុងបាងកក ថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៦៧
- យោងតាម ឧបសម្ពន្ធទី១ នៃធម្មនុញ្ញអាស៊ាន
- យោងតាម ឧបសម្ពន្ធទី២ នៃធម្មនុញ្ញអាស៊ាន
- យោងតាម ឧបសម្ពន្ធទី៣ នៃធម្មនុញ្ញអាស៊ាន
- យោងតាម ឧបសម្ពន្ធទី៤ នៃធម្មនុញ្ញអាស៊ាន

## ៣. សៀវភៅ

- សៀវភៅស្តីពី៖ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ស្ថាប័ននិងយន្តការ និងនីតិវិធីតាក់តែងឯកសារផទូផលសម្រាប់កិច្ចប្រជុំអាស៊ានពាក់ព័ន្ធ ៖ របស់លោក **សុខ ឆា** បោះពុម្ពខែមករា ឆ្នាំ២០២៣។
- សៀវភៅឈ្វេងយល់ សិក្សាអំពីអាស៊ាន បោះពុម្ពលើកទី២ (**របស់ក្រុមអ្នកសរសេរហោតម៉ឹក**) បោះពុម្ពខែវិច្ឆិការ ឆ្នាំ២០២២។

## ៤. គេហទំព័រផ្សេងៗ


- "ASEAN talks fail over South China Sea dispute". 14 July 2012. *Al Jazeera*, http://www.aljazeera.com/news/asia-pacific/2012/07/201271381350228798.html
- https://en.wikipedia.org/wiki/Southeast_Asia_Treaty_Organization
- Leifer , M. (1962). Cambodia and SEATO. International Journal, 17(2), 122-132.
- Institute of Current World Affairs. Retrieved from http://www.icwa.org/wp-content / uploads /2015 /09 / GDN-14.pdf.
- Pollard, V.K. (1970). ASA and ASEAN, 1961-1967: Southeast Asian Regionalism. Asian Survey, 10(3), pp.244-255. http/ www. jstor.org/stable/2642577.
- Duterte vows to pursue Philippines claim to Sabah". 27 May 2016. *Straits Times*.
- Thanat Khoman, "ASEAN Conception and Evolution", from www.asean.org, ៩ July ២០១២, http://asean.org/?static_post=asean-conception-and-evolution-by-thanat-kho man.

Reprinted from K.S. Sandhu et.al. (comps.), *The ASEAN Reader* (Singapore: Institute of South-East Asian Studies, ໑໙໙໒).

- ASEAN Summit. Retrieved from https://asean.org/about-us/asean-summit/
- Overview. Retrieved from https://asean.org/asean-foreign-ministerial-meeting/
- Thuzer, M.and Thi Ha. H. (1998). ASEAN Retreat: Origins and Functions. The ASEAN Studies Centre, ISEAS-Yusof Ishak Institute. Issue on 01/2018. Retrieved from https:/www.issue.edu.sg/images /pdf/ASEANM atterslssue1.pdf
- ASEAN, *The Foundation of ASEAN.* http://www.asean.org/asean/about-asean/ history/ Founding-fathersof-Asean'. 9August2011 .*The-Brunei-Times* .http://news.asiaone.com /News/Latest +News/Asia/Story/A1Story20110809-293603.html.
- ASEAN, "ASEAN Member States", http://asean.org/asean/asean-member-states/
- URL Source: http://www.asean.org/asean/about-asean/asean-anthem/ .
- https://www.asean.org/wp-content/uploads/images/archive/AC-Cambodia.pdf
- ASEAN-EU 2022 Anniversary Summit: Joint Leaders' Statement. Retrieved from https://asean.org/wp-content/uploads/2022/12/Final-ASEAN-EU-Commemorative-Summit - 2022- Joint Leaders- Statement.pdf
- ASEAN External Relations Coordinatorship. Retrieved form https://asean.org/wp-content/ uploads /2021 /11/ ASEAN-Country- Coordinatorship-as-of-Nov-2021.pdf
- Bangkok Post | Publication date 09 July 2013 | 16:43 ICT
- Sithanonxay Suvannaphakdy, Toshihisa Toyoda, and Chris Czerkawski, Graduate School of Economic Sciences Hirhoshima Shudo University, Japan
- https://www.academia.edu/download/68210015/Enhancing_Trade_Flows_in_ASEAN_Plus_Six20210720-23828-1g8ddn0.pdf
- ASEAN includes Brunei, Cambodia, Indonesia, Laos, Malaysia, Myanmar, the Philippines, Singapore, Thailand, and Vietnam.

- Bisley, Nick. "The East Asia summit and ASEAN: Potential and Problems." *Contemporary Southeast Asia: A Journal of International and Strategic Affairs*, vol. 39 no. 2, 2017, p. 265-272. *Project MUSE* muse.jhu.edu/article/667775.
- Bisley, N. (2017). The East Asia summit and ASEAN: Potential and Problems. *Contemporary Southeast Asia: A Journal of International and Strategic Affairs 39*(2), 265-272. https://www.muse.jhu.edu/article/667775.
- Priority of Cooperation. Retrieved from https:/asean.org/our-communities/asean-politicalsecurity-community/outward-looking-community/treaty-of-amity-and-cooperatio n-in-southeast-asia-tac/
- TY - JOUR T1 - The East Asia summit and ASEAN: Potential and Problems A1 - Bisley, Nick JF - Contemporary Southeast Asia: A Journal of International and Strategic Affairs VL - 39 IS - 2 SP - 265 EP - 272 PY - 2017 PB - ISEAS–Yusof Ishak Institute SN - 1793-284X UR - https://muse.jhu.edu/pub/70/article/667775 N1 - Volume 39, Number 2, August 2017 ER –
- ASEAN Regional Forum. Retrieved from http://aseanregionalforum.asean.org/about-arf/.
- The ASEAN Regional Forum: The Spirit of Constructive EngagementMICHAEL ANTOLIK*Contemporary Southeast Asia*, Vol. 16, No. 2 (September 1994), pp. 117-136 (20 pages)
- https://km.wikipedia.org/wiki/អាស៊ាន
- https://www.slideshare.net/maretapratiwi/the-asean-structure
- https://www.facebook.com/hrtrainingsolution/posts/1059548497588159/
- Organization. Retrieved from https://www.mfaic.gov.kh/Ogranization
- https://www.vayofm.com/news/detail/107438-657210126.html
- https://www.facebook.com/aseansecretariat/videos/១០១៥១១១៦១២២៥៨៨៥៨/
- https://www.khsearch.com/qna/12935
- https://www.youtube.com/watch?v=YNEhIqQRMgw

- https://www.academia.edu/download/68610564/an-appraisal-of-asean-defence-ministers-meeting-admm-as-part-of-defence-diplomacy-initiative-for-conflict-resolution. pdf
- https://vovworld.vn/kmKH/search/%E1%9E%A2%E1%9E%B6%E1%9E%9F%E1%9F%8A%E1% 9E%B6%E1% 9E %93+%E1%9F%A6.vov
- https://thmeythmey.com/？page=detail&id=120376.

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ៖

ឧបសម្ព័ន្ធ៖ ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ដែលបានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨)

ឧបសម្ព័ន្ធ៖ "The Asean Declaration ( Bangkok Declaration ) Bangkok, 8 August 1967".

# ធម្មនុញ្ញ
## នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

# ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

≈≈≈≈≈≈≈≈≈≈≈≈≈≈

## បុព្វកថា

**យើងជាប្រជាជន** នៃរដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ តំណាងដោយប្រមុខរដ្ឋ ឬរដ្ឋាភិបាល នៃប្រទេសប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម :

**ដោយកត់សំគាល់**ប្រកបដោយសេចក្តីពេញចិត្តចំពោះសមិទ្ធផលសំខាន់ៗ និងការពង្រីករបស់អាស៊ាន ចាប់តាំងពីការបង្កើតសមាគមនេះ នៅទីក្រុងបាងកក តាមរយៈការប្រកាសជាផ្លូវការនូវសេចក្តីថ្លែងការណ៍អាស៊ាន ។

**ដោយរំលឹកឡើងវិញ**នូវសេចក្តីសម្រេចចិត្តបង្កើតធម្មនុញ្ញអាស៊ាន ដែលកំណត់ក្នុងកម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទ សេចក្តីថ្លែងការណ៍ទីក្រុងគូឡាឡាំពួរស្តីពីការបង្កើតធម្មនុញ្ញអាស៊ាន និងសេចក្តីថ្លែងការណ៍ទីក្រុងសេប៊ូស្តីពីផែនការលំអិតនៃធម្មនុញ្ញអាស៊ាន ។

**ដោយយកចិត្តទុកដាក់**ចំពោះអត្ថិភាពនៃផលប្រយោជន៍ និងការពឹងពាក់គ្នាទៅវិញទៅមក ក្នុងចំណោមប្រជាជន និងរដ្ឋសមាជិកអាស៊ាន ទៅតាមភូមិសាស្ត្រ គោលដៅរួម និងជោគវាសនារួមគ្នា ។

**ដោយបានយល់ច្បាស់ និងរួបរួមគ្នា**ក្រោមចក្ខុវិស័យមួយ អត្តសញ្ញាណមួយ និងសហគមន៍មួយ ដែលរួមរស់ជាមួយគ្នាប្រកបដោយសុភមង្គល ។

**ដោយរួបរួមគ្នា**ក្នុងគោលបំណង និងឆន្ទៈរួម ដើម្បីរស់នៅក្នុងតំបន់មួយប្រកបដោយសន្តិភាព សន្តិសុខ និងស្ថិរភាពយូរអង្វែង កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព វិបុលភាពរួម និងវឌ្ឍនភាពសង្គម និងដើម្បីលើកតម្កើងសារប្រយោជន៍ជាសារវ័ន្ត ឧត្តមគតិ និងបំណងប្រាថ្នារបស់យើង ។

***ដោយគោរព***ចំពោះសារសំខាន់ជាមូលដ្ឋាននៃមិត្តភាព សហប្រតិបត្តិការ និងគោលការណ៍អធិបតេយ្យភាព សមភាព បូរណភាពទឹកដី ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង គោលការណ៍កុងសង់ស៊ីស និងការឯកភាពក្នុងពហុភាព ។

***ដោយប្រកាន់ខ្ជាប់***នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិបាលកិច្ចល្អ ការគោរព និងកិច្ចការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

***ដោយមានការសម្រេចចិត្ត***ធានានឹងធានាការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សម្រាប់ពេលបច្ចុប្បន្ន និងអនាគតរបស់មនុស្សជំនាន់ក្រោយ និងចាត់ទុកភាពសុខដុមរមនា ជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាជនជាចម្បងក្នុងដំណើរការកសាងសហគមន៍អាស៊ាន ។

***ដោយមានជំនឿជឿជាក់***ទៅលើតម្រូវការចាំបាច់ ក្នុងការពង្រឹងចំណងសាមគ្គីភាពក្នុងតំបន់ ដើម្បីសម្រេចបាននូវសហគមន៍អាស៊ាន ដែលមានការរួបរួមផ្នែកនយោបាយ សមាហរណកម្មសេដ្ឋកិច្ច និងការទទួលខុសត្រូវសង្គម ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការប្រឈម និងកាលានុវត្តភាព ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

***ដោយប្ដេជ្ញាចិត្ត***ពង្រឹងការកសាងសហគមន៍ តាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ ជាពិសេស តាមរយៈការបង្កើតសហគមន៍អាស៊ាន ដែលរួមមានសហគមន៍សន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន ដូចដែលបានចែងក្នុងសេចក្ដីថ្លែងការណ៍ទីក្រុងបាលីនៃកិច្ចស្រុះស្រួលអាស៊ានទី ២ ។

***អាស្រ័យហេតុនេះ*** តាមរយៈធម្មនុញ្ញនេះ សម្រេចបង្កើតក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់អាស៊ាន ។

***ហើយដើម្បីសម្រេចគោលដៅនេះ*** ប្រមុខរដ្ឋ ឬរដ្ឋាភិបាល នៃរដ្ឋសមាជិកអាស៊ាន បានជួបប្រជុំគ្នានៅប្រទេសសិង្ហបុរី នាឱកាសជាប្រវត្តិសាស្ត្រនៃខួបអនុស្សាវរីយ៍លើកទី ៤០ នៃការបង្កើតអាស៊ាន បានឯកភាពលើធម្មនុញ្ញនេះ ។

## ជំពូកទី ១
## គោលបំណង និងគោលការណ៍

### មាត្រា ១
### អំពីគោលបំណង

គោលបំណងរបស់អាស៊ានគឺ :

១. ថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព និងពង្រឹងថែមទៀតនូវតម្លៃឆ្ពោះទៅរកសន្តិភាពក្នុងតំបន់ ។

២. លើកកម្ពស់ភាពរឹងមាំនៃតំបន់ តាមរយៈការជំរុញឱ្យកាន់តែខ្លាំងថែមទៀតនូវសហប្រតិបត្តិការផ្នែកនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌ ។

៣. រក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងគ្មានអាវុធប្រល័យលោកផ្សេងទៀត ។

៤. ធានាថា ប្រជាជន និងរដ្ឋសមាជិកអាស៊ានរស់នៅប្រកបដោយសន្តិភាពជាមួយពិភពលោកទាំងមូល ក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា ។

៥. បង្កើតទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្មរួម ដែលមានស្ថិរភាព វិបុលភាព មានការប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មសេដ្ឋកិច្ច ជាមួយនឹងការសម្របសម្រួលដ៏មានប្រសិទ្ធភាពសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ ដែលក្នុងនោះមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម និងវិនិយោគ សម្រួលចលនាពាណិជ្ជករ អ្នកមានវិជ្ជាជីវៈ អ្នកមានទេពកោសល្យ និងពលករ និងលំហូរដោយម្ចាស់ការនៃទុន ។

៦. កាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតនៃការអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ាន តាមរយៈការជួយគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ ។

៧. ពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ ការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយយកចិត្តទុកដាក់ចំពោះសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋសមាជិកអាស៊ាន ។

៨. ឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ទៅតាមគោលការណ៍នៃសន្តិសុខពេញលេញ ចំពោះការគំរាមគំហែងគ្រប់រូបភាព ឧក្រិដ្ឋកម្មឆ្លងដែន និងបញ្ហាប្រឈមឆ្លងដែននានា ។

៩. លើកស្ទួយការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដើម្បីធានាការការពារបរិស្ថានតំបន់ និរន្តរភាពនៃធនធានធម្មជាតិ និងការអភិរក្សមរតកវប្បធម៌ និងគុណភាពនៃជីវភាពរស់នៅខ្ពស់របស់ប្រជាជន ។

១០. អភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ក្នុងការអប់រំ និងការសិក្សាក្នុងមួយជីវិត និងលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីផ្តល់ជូនប្រជាជនអាស៊ាន និងការពង្រឹងសហគមន៍អាស៊ាន ។

១១. លើកកម្ពស់ភាពសុខដុមរមនា និងជីវភាពរស់នៅរបស់ប្រជាជនអាស៊ាន ដោយការផ្តល់ឱ្យនូវលទ្ធភាពទទួលបានសមភាព ក្នុងការអភិវឌ្ឍន៍មនុស្ស សុខុមាលភាពសង្គម និងយុត្តិធម៌ ។

១២. ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាងបរិស្ថានប្រកបដោយសុវត្ថិភាព សន្តិសុខ និងភាពគ្មានគ្រឿងញៀនសម្រាប់ប្រជាជនអាស៊ាន ។

១៣. ជំរុញការយកចិត្តទុកដាក់ដល់ប្រជាជនអាស៊ាន ក្នុងនោះ គ្រប់ផ្នែកទាំងអស់នៃសង្គមត្រូវបានលើកទឹកចិត្តឱ្យចូលរួម និងទទួលយកផលប្រយោជន៍ពីដំណើរការសមាហរណកម្ម និងការកសាងសហគមន៍អាស៊ាន ។

១៤. ជំរុញអត្តសញ្ញាណអាស៊ាន តាមរយៈការជំរុញឱ្យចម្រើនឡើងនូវការយល់ដឹងអំពីវប្បធម៌ និងមរតកចម្រុះក្នុងតំបន់ និង

១៥. ថែរក្សាតួនាទីស្នូលដ៏សកម្មរបស់អាស៊ាន ជាកម្លាំងចលករដ៏សំខាន់ ក្នុងទំនាក់ទំនង និងសហប្រតិបត្តិការរបស់ខ្លួនជាមួយដៃគូក្រៅតំបន់ ក្នុងស្ថាបត្យកម្មតំបន់ប្រកបដោយភាពបើកចំហ តម្លាភាព និងការរួមបញ្ចូលគ្នា ។

## មាត្រា ២
## អំពីគោលការណ៍

១, ដោយយោងតាមគោលបំណង ដែលបានចែងក្នុងមាត្រា ១ អាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនអះអាងជាថ្មី និងប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋាន ដូចមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា កិច្ចស្រុះស្រួល និងលិខិតូបករណ៍ដទៃទៀតរបស់អាស៊ាន ។

២, អាស៊ាន និងរដ្ឋសមាជិកត្រូវអនុវត្តឱ្យស្របតាមគោលការណ៍ដូចខាងក្រោម :

ក. គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់

ខ. ចូលរួមការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់

គ. បដិសេធនូវអំពើឈ្លានពាន និងការគំរាមគំហែង ឬការប្រើប្រាស់កម្លាំង ឬសកម្មភាពទាំងឡាយណាក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ

ឃ. ប្រកាន់យកដំណោះស្រាយជម្លោះដោយសន្តិវិធី

ង. មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃរដ្ឋសមាជិកអាស៊ាន

ច. គោរពសិទ្ធិរបស់រដ្ឋសមាជិកនីមួយៗ ក្នុងការដឹកនាំអត្ថិភាពជាតិរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីខាងក្រៅ ការធ្វើវិទ្ធង្សនា និងការបង្ខិតបង្ខំ

ឆ. លើកកម្ពស់ការពិគ្រោះយោបល់លើបញ្ហាធ្ងន់ធ្ងរទាំងឡាយ ដែលមានឥទ្ធិពលប៉ះពាល់ដល់ផលប្រយោជន៍រួមរបស់អាស៊ាន

ជ. ប្រកាន់ខ្ជាប់នូវនីតិរដ្ឋ អភិបាលកិច្ចល្អ គោលការណ៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាលអាស្រ័យដោយរដ្ឋធម្មនុញ្ញ

ឈ. គោរពសេរីភាពជាមូលដ្ឋាន លើកស្ទួយ និងការពារសិទ្ធិមនុស្ស និងលើកកម្ពស់យុត្តិធម៌សង្គម

ញ. លើកតម្កើងធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិនានា ដែលរដ្ឋសមាជិកអាស៊ានទាំងអស់បានយល់ព្រម

ដ. មិនចូលរួមក្នុងគោលនយោបាយ ឬសកម្មភាពណាមួយ ដែលរួមមានការដាក់ឱ្យប្រើប្រាស់នូវទឹកដីរបស់ខ្លួនឱ្យរដ្ឋសមាជិកអាស៊ាន ឬរដ្ឋមិនមែនជាសមាជិកអាស៊ាន ឬឱ្យតួអង្គដទៃទៀតដែលពុំមែនជារដ្ឋ គំរាមគំហែងដល់អធិបតេយ្យភាព បូរណភាពទឹកដី ឬស្ថិរភាពសេដ្ឋកិច្ច និងនយោបាយរបស់រដ្ឋសមាជិកអាស៊ាន

ឋ. គោរពវប្បធម៌ផ្សេងៗគ្នា ភាសា និងសាសនារបស់ប្រជាជនអាស៊ាន ដោយសង្កត់ធ្ងន់ទៅលើតម្លៃរួម ក្នុងស្មារតីភាពឯកភាពក្នុងពហុភាព

ឌ. ភាពជាស្នូលរបស់អាស៊ាន ក្នុងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ក្រៅតំបន់ ដោយរក្សាការចូលរួមដ៏សកម្ម ការសម្លឹងមើលឆ្ពោះទៅខាងក្រៅ ភាពរួមបញ្ចូលគ្នា និងភាពមិនរើសអើង និង

ឍ. ប្រកាន់ខ្ជាប់នូវវិធានពាណិជ្ជកម្មពហុភាគី និងរបបផ្អែកលើមូលដ្ឋានច្បាប់របស់អាស៊ាន ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចខិតខំប្រឹងប្រែងផ្អែកសេដ្ឋកិច្ច និងកាត់បន្ថយជាវិជ្ជមានឆ្ពោះទៅលុបបំបាត់របាំងទាំងស្រុង សម្រាប់សមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចទីផ្សារ ។

## ជំពូកទី ២
## បុគ្គលភាពគតិយុត្ត

### មាត្រា ៣
### អំពីបុគ្គលភាពគតិយុត្តរបស់អាស៊ាន

អាស៊ានដែលជាអង្គការអន្តររដ្ឋាភិបាលមួយត្រូវបានផ្តល់បុគ្គលិកលក្ខណៈជាបុគ្គលភាពគតិយុត្ត ។

## ជំពូកទី ៣
## សមាជិកភាព

### មាត្រា ៤
### អំពីរដ្ឋសមាជិក

រដ្ឋសមាជិកអាស៊ានមានប្រទេសប្រ៊ុយណេដារូសាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

### មាត្រា ៥
### អំពីសិទ្ធិ និងភារកិច្ច

១. ក្រោមធម្មនុញ្ញនេះ រដ្ឋសមាជិកអាស៊ានទាំងអស់មានសិទ្ធិ និងកាតព្វកិច្ចស្មើៗគ្នា ។

២. រដ្ឋសមាជិកត្រូវចាត់គ្រប់វិធានការចាំបាច់ រួមទាំង ការអនុម័តច្បាប់ក្នុងស្រុករបស់ខ្លួនឱ្យមានលក្ខណៈស្រមស្រប ដើម្បីអនុវត្តដោយមានប្រសិទ្ធភាពនូវបទប្បញ្ញត្តិនៃធម្មនុញ្ញនេះ និងឱ្យបានសមស្រុបគ្រប់កាតព្វកិច្ចនៃសមាជិកភាព ។

៣. ក្នុងករណីមានការរំលោភធ្ងន់ធ្ងរ ឬមិនគោរពតាមធម្មនុញ្ញនេះនឹងត្រូវអនុវត្តទៅតាមមាត្រា ២០ ។

## មាត្រា ៦
## អំពីការទទួលយកសមាជិកថ្មី

១. នីតិវិធីនៃការដាក់ពាក្យ និងការទទួលចូលជាសមាជិកអាស៊ានត្រូវបញ្ញត្តិដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

២. ការទទួលយកសមាជិកថ្មីត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

   ក. ទីតាំងភូមិសាស្ត្រដែលត្រូវបានទទួលស្គាល់ថា ស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍

   ខ. មានការទទួលស្គាល់ពីបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់

   គ. ឯកភាពគោរព និងប្រតិបត្តិតាមធម្មនុញ្ញអាស៊ាន និង

   ឃ. មានលទ្ធភាព និងឆន្ទៈអនុវត្តនូវកាតព្វកិច្ចទាំងអស់នៃសមាជិកភាព ។

៣. ការទទួលយកជាសមាជិកថ្មីត្រូវសម្រេចដោយកុងសង់ស៊ីស នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន បន្ទាប់ពីបានទទួលអនុសាសន៍ពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

៤. រដ្ឋស្នើសុំនឹងទទួលបានសមាជិកភាព បន្ទាប់ពីការចុះហត្ថលេខាលើលិខិតូបករណ៍នៃការយល់ព្រមចំពោះធម្មនុញ្ញអាស៊ាននេះ ។

## ជំពូកទី ៤
## អង្គការចាត់តាំង

## មាត្រា ៧
## អំពីកិច្ចប្រជុំកំពូលអាស៊ាន

១. កិច្ចប្រជុំកំពូលអាស៊ានត្រូវចូលរួមដោយប្រមុខរដ្ឋ/រដ្ឋាភិបាលនៃរដ្ឋសមាជិក ។

២. កិច្ចប្រជុំកំពូលអាស៊ាន :

   ក. ជាអង្គភាពរៀបចំគោលនយោបាយកំពូលរបស់អាស៊ាន

   ខ. ពិគ្រោះយោបល់ ផ្តល់មាគ៌ានយោបាយ និងធ្វើការសម្រេចលើបញ្ហាជាគន្លឹះដែលទាក់ទងទៅនឹងសមិទ្ធផលនៃគោលដៅរបស់អាស៊ាន បញ្ហាសំខាន់ៗដែលជាផលប្រយោជន៍របស់រដ្ឋសមាជិក និងរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធ តាមរយៈក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ក្រុមប្រឹក្សាសហគមន៍អាស៊ាន និងអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ាន

គ. ណែនាំរដ្ឋមន្ត្រីពាក់ព័ន្ធ ក្នុងក្រុមប្រឹក្សានីមួយៗ ឱ្យរៀបចំកិច្ចប្រជុំអាដហុកថ្នាក់អន្តររដ្ឋមន្ត្រី និងដោះស្រាយបញ្ហាសំខាន់ៗដែលកើតមានឡើងក្នុងក្រុមប្រឹក្សាសហគមន៍ ។ វិធាននៃនីតិវិធីដំណើរការកិច្ចប្រជុំនេះត្រូវអនុម័ត ដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

ឃ. ដោះស្រាយស្ថានភាពបន្ទាន់ដែលប៉ះពាល់ដល់អាស៊ាន តាមរយៈការប្រើប្រាស់សកម្មភាពសមស្រប

ង. សម្រេចបញ្ហាផ្សេងៗ ដោយអនុវត្តតាមជំពូកទី ៧ និងទី ៨ នៃធម្មនុញ្ញនេះ

ច. អាចបង្កើត និងរំលាយចោលនូវអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែក និងស្ថាប័នអាស៊ានដទៃទៀត និង

ឆ.. តែងតាំងអគ្គលេខាធិការអាស៊ាន ដែលមានតំណែង និងឋានៈស្មើរដ្ឋមន្ត្រី ដែលត្រូវបម្រើការងារដោយទំនុកចិត្ត និងទទួលបានការពេញចិត្តពីប្រមុខរដ្ឋ/រដ្ឋាភិបាល តាមការស្នើឡើងដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

៣. កិច្ចប្រជុំកំពូលអាស៊ានត្រូវ :

ក. រៀបចំឡើង ២ដង ក្នុងមួយឆ្នាំ ក្នុងរដ្ឋសមាជិក ដែលទទួលបន្ទុកជាប្រធានអាស៊ាន និង

ខ. ក្នុងករណីចាំបាច់ ត្រូវរៀបចំកិច្ចប្រជុំពិសេស ឬកិច្ចប្រជុំអាដហុកក្រោមអធិបតីភាពនៃរដ្ឋសមាជិក ដែលទទួលបន្ទុកជាប្រធានអាស៊ាន នៅទីកន្លែងនៃកិច្ចប្រជុំនេះដែលកំណត់តាមការឯកភាពពីរដ្ឋសមាជិកអាស៊ានទាំងអស់ ។

## មាត្រា ៨
## អំពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

១. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន រួមមាន សមាសភាពរដ្ឋមន្ត្រីការបរទេសអាស៊ាន និងត្រូវជួបប្រជុំយ៉ាងតិច ២ដង ក្នុងមួយឆ្នាំ ។

២. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវ :

ក. រៀបចំកិច្ចប្រជុំកំពូលអាស៊ាន

ខ. សម្របសម្រួលការអនុវត្តន៍កិច្ចព្រមព្រៀង និងសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូលអាស៊ាន

គ. សម្របសម្រួលជាមួយក្រុមប្រឹក្សាសហគមន៍អាស៊ាន ដើម្បីលើកកម្ពស់ភាពរលូននៃគោលនយោបាយ ប្រសិទ្ធភាព និងសហប្រតិបត្តិការ ក្នុងចំណោមគ្នានិងគ្នា

ឃ. សម្របសម្រួលរបាយការណ៍នានារបស់ក្រុមប្រឹក្សាសហគមន៍អាស៊ានដាក់ជូនកិច្ចប្រជុំកំពូលអាស៊ាន

ង. ពិនិត្យពិចារណាលើរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការ ស្តីពីការងារអាស៊ាន

ច. ពិនិត្យពិចារណាលើរបាយការណ៍របស់អគ្គលេខាធិការស្តីពីមុខងារ និងប្រតិបត្តិការនៃលេខាធិការដ្ឋានអាស៊ាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត

ឆ. ឯកភាពចំពោះការតែងតាំង និងការបញ្ចប់អាណត្តិអគ្គលេខាធិការរង បន្ទាប់ពីបានទទួលអនុសាសន៍របស់អគ្គលេខាធិការ និង

ជ. អនុវត្តការងារផ្សេងៗទៀត ដែលកំណត់ឡើងក្នុងធម្មនុញ្ញនេះ ឬមុខនាទីដទៃទៀតដែលអាចកំណត់ឡើងដោយកិច្ចប្រជុំកំពូលអាស៊ាន

៣. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានគាំទ្រដោយឧត្តមមន្ត្រីពាក់ព័ន្ធ ។

## មាត្រា ៩
## អំពីក្រុមប្រឹក្សាសហគមន៍អាស៊ាន

១. ក្រុមប្រឹក្សាសហគមន៍អាស៊ាន រួមមាន ក្រុមប្រឹក្សាសហគមន៍សន្តិសុខ-នយោបាយអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន ។

២. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ មានអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែកនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។

៣. រដ្ឋសមាជិកនីមួយៗ ត្រូវតែងតាំងតំណាងជាតិរបស់ខ្លួន សម្រាប់ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នីមួយៗ ។

៤. ដើម្បីសម្រេចគោលដៅនីមួយៗ នៃសសរគ្រឹះទាំងបីរបស់សហគមន៍អាស៊ាន ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗត្រូវ :

ក. ធានាអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់កិច្ចប្រជុំកំពូលអាស៊ាន

ខ. សម្របសម្រួលការងារផ្នែកផ្សេងៗ ក្រោមសមត្ថកិច្ចរបស់ខ្លួន និងលើបញ្ហាដែលកើតមានឡើងក្នុងក្រុមប្រឹក្សាសហគមន៍ដទៃទៀត និង

គ. ដាក់របាយការណ៍ និងអនុសាសន៍ផ្សេងៗ ជូនកិច្ចប្រជុំកំពូលអាស៊ានលើបញ្ហា ដែលស្ថិតនៅក្រោមវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

៥. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ត្រូវប្រជុំយ៉ាងតិច ២ដងក្នុងមួយឆ្នាំ ។ កិច្ចប្រជុំនេះត្រូវដឹកនាំដោយរដ្ឋមន្ត្រីពីរដ្ឋសមាជិក ដែលទទួលបន្ទុកជាប្រធានអាស៊ាន ។

៦. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ត្រូវបានគាំទ្រដោយឧត្តមមន្ត្រីពាក់ព័ន្ធទៅនឹងសហគមន៍នីមួយៗនោះ ។

## មាត្រា ១០

## អំពីអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ាន

១. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ានត្រូវ :

ក. ដំណើរការមុខងារស្របតាមអាណត្តិរបស់ខ្លួន

ខ. អនុវត្តកិច្ចព្រមព្រៀង និងសេចក្តីសម្រេចនៃកិច្ចប្រជុំកំពូលអាស៊ាន ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន

គ. ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងផ្នែករបស់ខ្លួននីមួយៗ ដើម្បីទ្រទ្រង់សមាហរណកម្មអាស៊ាន និងការកសាងសហគមន៍ និង

ឃ. ដាក់របាយការណ៍ និងអនុសាសន៍ជូនក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ។

២. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកនីមួយៗរបស់អាស៊ានអាចមានឧត្តមមន្ត្រីពាក់ព័ន្ធនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និងអង្គភាពក្រោមឱវាទ ដើម្បីបំពេញមុខងារដូចមានក្នុងឧបសម្ព័ន្ធទី ១ ។ ឧបសម្ព័ន្ធនេះអាចធ្វើបច្ចុប្បន្នភាព ដោយអគ្គលេខាធិការអាស៊ាន បន្ទាប់ពីមានអនុសាសន៍ពីគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ដោយមិនចាំបាច់មានការធ្វើវិសោធនកម្មនៃធម្មនុញ្ញនេះ ។

## មាត្រា ១១

## អំពីអគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋានអាស៊ាន

១. អគ្គលេខាធិការអាស៊ានត្រូវបានតែងតាំងដោយកិច្ចប្រជុំកំពូលអាស៊ាន សម្រាប់អាណត្តិប្រាំឆ្នាំដែលអាណត្តិនេះមិនអាចបន្តទៀតបានទេ ហើយត្រូវជ្រើសរើសចេញពីក្នុងចំណោមជនជាតិនៃរដ្ឋសមាជិកអាស៊ាន ផ្អែកទៅលើការប្តូរវេនគ្នាតាមលំដាប់អក្ខរក្រមនៃឈ្មោះរដ្ឋសមាជិក ដោយពិចារណាល្អិតល្អន់ទៅលើសុច្ចរិតធម៌ សមត្ថភាព បទពិសោធន៍វិជ្ជាជីវៈ និងសមភាពយេនឌ័រ ។

២. អគ្គលេខាធិការអាស៊ានត្រូវ :

ក. អនុវត្តភារកិច្ច និងការទទួលខុសត្រូវនៃការិយាល័យជាន់ខ្ពស់នេះ ដោយយោងទៅតាមបទប្បញ្ញត្តិនៃធម្មនុញ្ញនេះ និងលិខិតតូបករណ៍ ពិធីសារ និងកិច្ចប្រតិបត្តិពាក់ព័ន្ធទាំងឡាយរបស់អាស៊ាន

ខ. សម្រួល និងត្រួតពិនិត្យមើលការរីកចម្រើននៃការអនុវត្តន៍កិច្ចព្រមព្រៀង និងសេចក្តីសម្រេចរបស់អាស៊ាន និងដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការងារអាស៊ានជូនកិច្ចប្រជុំកំពូលអាស៊ាន

គ. ចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន កិច្ចប្រជុំរបស់អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមវិស័យរបស់អាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធដទៃទៀតរបស់អាស៊ាន

ឃ. បង្ហាញអំពីទស្សនៈរបស់អាស៊ាន និងចូលរួមក្នុងកិច្ចប្រជុំជាមួយភាគីក្រៅតំបន់ ដោយអនុលោមទៅតាមគោលមាគ៌ានយោបាយ ដែលបានឯកភាព និងអាណត្តិដែលបានប្រគល់ជូនអគ្គលេខាធិការ និង

ង. ស្នើសុំការអនុម័តពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន តែងតាំង និងបញ្ចប់អាណត្តិរបស់អគ្គលេខាធិការរង ។

៣. អគ្គលេខាធិការក៏ត្រូវទទួលតួនាទីជាប្រធានរដ្ឋបាលរបស់អាស៊ាន ។

៤. អគ្គលេខាធិការមានអគ្គលេខាធិការរង ៤រូប ដែលមានតំណែង និងឋានៈស្មើអនុរដ្ឋមន្ត្រី ជាជំនួយការ ។ អគ្គលេខាធិការរងត្រូវទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ ក្នុងការអនុវត្តន៍មុខងាររបស់ខ្លួន ។

៥. អគ្គលេខាធិការរងទាំងបួនត្រូវមានសញ្ជាតិខុសពីអគ្គលេខាធិការ និងមកពីរដ្ឋសមាជិកបួនផ្សេងគ្នា ។

៦. អគ្គលេខាធិការរងទាំងបួនមានសមាសភាព :

ក. អគ្គលេខាធិការរង ២រូប មានអាណត្តិកំណត់ ៣ឆ្នាំ ដែលអាណត្តិនេះមិនអាចបន្តបាន និងដែលបានជ្រើសរើសចេញពីជនជាតិនៃរដ្ឋសមាជិកអាស៊ាន ដោយផ្អែកទៅលើការប្តូរវេនគ្នាតាមលំដាប់អក្ខរក្រម និងដោយពិចារណាល្អិតល្អន់ទៅលើសុច្ចរិតធម៌ គុណសម្បត្តិ សមត្ថភាព បទពិសោធន៍ និងសមភាពយេនឌ័រ

ខ. អគ្គលេខាធិការរង ២រូបទៀត មានអាណត្តិ ៣ឆ្នាំដូចគ្នា ប៉ុន្តែអាណត្តិនេះអាចបន្តបានមួយអាណត្តិទៀត ។ អគ្គលេខាធិការរងទាំងពីររូបនេះត្រូវជ្រើសរើសជាចំហដោយផ្អែកទៅលើលក្ខណៈសម្បត្តិ ដែលសមនឹងទទួលបានតួនាទីនេះ ។

៧. លេខាធិការដ្ឋានអាស៊ានមានអគ្គលេខាធិការ និងបុគ្គលិកតាមចំនួនដែលអាចត្រូវការ ។

៨. អគ្គលេខាធិការ និងបុគ្គលិកត្រូវ :

ក. ប្រកាន់ឱ្យបានភាពខ្ពង់ខ្ពស់បំផុតនូវសុច្ចរិតភាព ប្រសិទ្ធភាព និងសមត្ថភាព ក្នុងការបំពេញការងាររបស់ខ្លួន

ខ. មិនស្វែងរក ឬទទួលបញ្ជាពីរដ្ឋាភិបាលណាមួយ ឬភាគីខាងក្រៅអាស៊ាន និង

គ. ទប់ស្កាត់សកម្មភាពណាមួយដែលអាចឆ្លុះបញ្ចាំងលើគោលជំហររបស់ខ្លួនជាមន្ត្រីលេខាធិការដ្ឋានអាស៊ាន ដែលមានការទទួលខុសត្រូវចំពោះតែអាស៊ានប៉ុណ្ណោះ ។

៩. រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវគោរពលក្ខណៈទទួលខុសត្រូវទាំងស្រុងរបស់អគ្គលេខាធិការ និងបុគ្គលិក និងមិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនទៅលើពួកគេដែលធ្វើឱ្យបាត់ការទទួលខុសត្រូវ ។

## មាត្រា ១២

## អំពីគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន

១. រដ្ឋសមាជិកអាស៊ាននីមួយៗត្រូវតែងតាំងតំណាងអចិន្ត្រៃយ៍របស់ខ្លួនមួយរូប ប្រចាំអាស៊ាន ដែលមានឋានៈជាឯកអគ្គរដ្ឋទូត/រាជទូត មានទីតាំងនៅទីក្រុងហ្សាការតា ។

២. តំណាងអចិន្ត្រៃយ៍ទាំងនេះរួមគ្នាបង្កើតបានជាគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍មួយដែលត្រូវ :

ក. ទ្រទ្រង់ការងារក្រុមប្រឹក្សាសហគមន៍អាស៊ាន និងអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញអាស៊ានតាមផ្នែក

ខ. សម្របសម្រួលជាមួយលេខាធិការដ្ឋានជាតិអាស៊ាន និងអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកដទៃទៀតរបស់អាស៊ាន

គ. ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋានអាស៊ានលើគ្រប់វិស័យពាក់ព័ន្ធទាំងឡាយដល់ការងាររបស់ខ្លួន

ឃ. សម្របសម្រួលសហប្រតិបត្តិការរបស់អាស៊ានជាមួយដៃគូក្រៅតំបន់

ង. បំពេញការងារដទៃទៀតដែលអាចកំណត់ឡើងដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

## មាត្រា ១៣
## អំពីលេខាធិការដ្ឋានជាតិអាស៊ាន

រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតលេខាធិការដ្ឋានជាតិអាស៊ានមួយរបស់ខ្លួនដែលត្រូវ :

ក. ដើរតួនាទីជាចំណុចទំនាក់ទំនងគ្នាថ្នាក់ជាតិ

ខ. ជាកន្លែងតម្កល់ព័ត៌មានទាំងអស់នៃកិច្ចការរបស់អាស៊ានថ្នាក់ជាតិ

គ. សម្របសម្រួលការអនុវត្តន៍សេចក្តីសម្រេចរបស់អាស៊ានថ្នាក់ជាតិ

ឃ. សម្របសម្រួល និងជួយរៀបចំកិច្ចប្រជុំអាស៊ានថ្នាក់ជាតិ

ង. លើកស្ទួយអត្តសញ្ញាណ និងការយល់ដឹងអំពីអាស៊ានថ្នាក់ជាតិ

ច. រួមចំណែកកសាងសហគមន៍អាស៊ាន ។

## មាត្រា ១៤
## អំពីអង្គភាពសិទ្ធិមនុស្សអាស៊ាន

១. ដោយអនុលោមតាមគោលបំណង និងគោលការណ៍របស់ធម្មនុញ្ញអាស៊ានដែលទាក់ទងទៅនឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន អាស៊ានត្រូវបង្កើតអង្គភាពសិទ្ធិមនុស្សអាស៊ានមួយ ។

២. អង្គភាពសិទ្ធិមនុស្សអាស៊ាននេះត្រូវធ្វើការ ដោយអនុលោមទៅតាមឯកសារគោល ដែលនឹងកំណត់ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

## មាត្រា ១៥
## អំពីគ្រឹះស្ថានអាស៊ាន

១. គ្រឹះស្ថានអាស៊ានត្រូវគាំទ្រដល់អគ្គលេខាធិការអាស៊ាន និងសហការជាមួយអង្គភាពអាស៊ានពាក់ព័ន្ធ ដើម្បីទ្រទ្រង់ការកសាងសហគមន៍អាស៊ាន តាមរយៈការជំរុញការយល់ដឹងឱ្យកាន់តែច្បាស់អំពីអត្តសញ្ញាណអាស៊ាន អន្តរទំនាក់ទំនងរវាងប្រជាជន និងប្រជាជន និងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយផ្នែកធុរកិច្ច សង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងផ្នែកពាក់ព័ន្ធដទៃទៀត ។

២. គ្រឹះស្ថានអាស៊ានទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់របាយការណ៍ជូនកិច្ចប្រជុំកំពូលអាស៊ាន តាមរយៈក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

## ជំពូកទី ៥
## អង្គភាពពាក់ព័ន្ធអាស៊ាន

### មាត្រា ១៦
### អង្គភាពពាក់ព័ន្ធអាស៊ាន

១. អាស៊ានអាចបំពេញការងារជាមួយអង្គភាពនានា ដែលគាំទ្រធម្មនុញ្ញអាស៊ាននេះ ជាពិសេសចំពោះគោលបំណង និងគោលការណ៍របស់ធម្មនុញ្ញអាស៊ាន ។ អង្គភាពពាក់ព័ន្ធអាស៊ានមានរាយនាមក្នុងឧបសម្ព័ន្ធទី ២ នៃធម្មនុញ្ញនេះ ។

២. វិធាននៃនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ការចូលរួមជាមួយអង្គភាពទាំងនេះត្រូវកំណត់ដោយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ នៅពេលដែលបានទទួលអនុសាសន៍ពីអគ្គលេខាធិការអាស៊ាន ។

៣. ឧបសម្ព័ន្ធទី ២ អាចត្រូវធ្វើបច្ចុប្បន្នភាព ដោយអគ្គលេខាធិការអាស៊ាននៅពេលមានអនុសាសន៍ពីគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ដោយពុំចាំបាច់ធ្វើវិសោធនកម្មនៃធម្មនុញ្ញនេះ ។

## ជំពូកទី ៦
## បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

### មាត្រា ១៧
### អំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អាស៊ាន

១. អាស៊ានមានសិទ្ធិទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៅក្នុងទឹកដីនៃរដ្ឋសមាជិក តាមភាពចាំបាច់សម្រាប់ការបំពេញគោលបំណងរបស់ខ្លួន ។

២. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនេះ ត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងដោយឡែករវាងអាស៊ាន និងរដ្ឋសមាជិកជាម្ចាស់ផ្ទះ ។

## មាត្រា ១៨
## អំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អគ្គលេខាធិការអាស៊ាន និងមន្ត្រីលេខាធិការដ្ឋានអាស៊ាន

១. អគ្គលេខាធិការអាស៊ាន និងបុគ្គលិកនៃលេខាធិការដ្ឋានអាស៊ានដែលចូលរួមក្នុងសកម្មភាពជាផ្លូវការរបស់អាស៊ាន ឬជាតំណាងអាស៊ាន ប្រចាំរដ្ឋសមាជិក ចាំបាច់ត្រូវបានទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដើម្បីបំពេញមុខនាទីរបស់ខ្លួនដោយឯករាជ្យ ។

២. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលមានចែងក្នុងមាត្រានេះ ត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងដោយឡែកមួយទៀតរបស់អាស៊ាន ។

## មាត្រា ១៩
## អំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តំណាងអចិន្ត្រៃយ៍ និងមន្ត្រីដែលកំពុងបំពេញភារកិច្ចនៅអាស៊ាន

១. តំណាងអចិន្ត្រៃយ៍របស់រដ្ឋសមាជិក ប្រចាំនៅអាស៊ាន និងមន្ត្រីរបស់រដ្ឋសមាជិក ដែលចូលរួមក្នុងសកម្មភាពជាផ្លូវការរបស់អាស៊ាន ឬដែលជាតំណាងអាស៊ានប្រចាំរដ្ឋសមាជិក ចាំបាច់ត្រូវបានទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដើម្បីបំពេញការងាររបស់ខ្លួនដោយឯករាជ្យ ។

២. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តំណាងអចិន្ត្រៃយ៍ និងមន្ត្រី ដែលកំពុងបំពេញភារកិច្ចនៅអាស៊ាន ត្រូវស្ថិតនៅក្រោមអនុសញ្ញាទីក្រុងវីយែន (Vienna) ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ឬអនុលោមទៅតាមច្បាប់ជាតិរបស់រដ្ឋសមាជិកអាស៊ាននីមួយៗ ។

# ជំពូកទី ៧
# ការធ្វើសេចក្តីសម្រេច

## មាត្រា ២០
## អំពីការប្រឹក្សាយោបល់ និងកុងសង់ស៊ីស

១. ជាគោលការណ៍គ្រឹះ រាល់សេចក្តីសម្រេចរបស់អាស៊ានត្រូវឈរលើមូលដ្ឋាននៃការប្រឹក្សាយោបល់ និងកុងសង់ស៊ីស ។

២. ក្នុងករណីដែលមិនមានកុងសង់ស៊ីស កិច្ចប្រជុំកំពូលអាស៊ានអាចនឹងធ្វើការសម្រេចអំពីរបៀបនៃការធ្វើសេចក្តីសម្រេចជាក់លាក់មួយ ។

៣. សេចក្ដីដែលមានចែងក្នុងកថាខណ្ឌ ១ និង ២ នៃមាត្រានេះ មិនធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រធ្វើសេចក្ដីសម្រេចនានារបស់អាស៊ាន ដូចដែលមានកំណត់ក្នុងលិខិតូបករណ៍គតិយុត្តពាក់ព័ន្ធរបស់អាស៊ានដទៃទៀត ។

៤. ក្នុងករណីមានការរំលោភធ្ងន់ធ្ងរ ឬការប្រព្រឹត្តិផ្ទុយទៅនឹងធម្មនុញ្ញនេះ សេចក្ដីសម្រេចនេះត្រូវដាក់ជូនកិច្ចប្រជុំកំពូលអាស៊ាន ។

## មាត្រា ២១
## អំពីការអនុវត្តន៍ និងនីតិវិធី

១. ក្រុមប្រឹក្សាសហគមន៍អាស៊ានទីមួយៗ ត្រូវបញ្ញត្តិនូវវិធាននៃនីតិវិធីរបស់ខ្លួន ។

២. នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច រូបមន្តសម្រាប់ការចូលរួម ដែលមានភាពទន់ភ្លន់ ដូចជា ការប្រើរូបមន្តអាស៊ានដកអ៊ិច [ASEAN Minus X formula] អាចអនុវត្តបានប្រសិនបើមានកុងសង់ស៊ីសក្នុងការអនុវត្តន៍ ។

# ជំពូកទី ៨
# ការដោះស្រាយជម្លោះ

## មាត្រា ២២
## អំពីគោលការណ៍ទូទៅ

១. រដ្ឋសមាជិកអាស៊ានត្រូវខិតខំប្រឹងប្រែងដោះស្រាយជម្លោះទាំងឡាយ ដោយសន្តិវិធីឱ្យទាន់ពេលវេលា តាមរយៈកិច្ចសន្ទនា ការប្រឹក្សាយោបល់ និងការចរចា ។

២. អាស៊ានត្រូវរក្សា និងបង្កើតយន្តការដោះស្រាយជម្លោះលើគ្រប់វិស័យនៃកិច្ចសហប្រតិបត្តិការរបស់ខ្លួន ។

## មាត្រា ២៣
## អំពីអន្តរការី ការផ្សះផ្សា និងការនាំសម្រុះសម្រួល

១ រដ្ឋសមាជិកដែលជាភាគីនៃជម្លោះ អាចព្រមព្រៀងគ្នានៅពេលណាមួយក្នុងការស្វែងរកមធ្យោបាយដោះស្រាយវិវាទ តាមរយៈអន្តរការី ការផ្សះផ្សា ឬការសម្រុះសម្រួល ក្នុងពេលវេលាជាក់លាក់ដែលបានព្រមព្រៀងគ្នា ។

២. ភាគីក្នុងជម្លោះអាចស្នើសុំប្រធានអាស៊ាន ឬអគ្គលេខាធិការអាស៊ាន ក្នុងតួនាទីជាមន្ត្រីផ្លូវការ ដើម្បីផ្តល់នូវអន្តរការី ការផ្សះផ្សា ឬការនាំសម្រុះសម្រួល ។

## មាត្រា ២៤
## អំពីយន្តការដោះស្រាយជម្លោះក្នុងលិខិតូបករណ៍ពិសេស

១. រាល់ជម្លោះដែលទាក់ទងនឹងលិខិតូបករណ៍ពិសេសរបស់អាស៊ាន ត្រូវដោះស្រាយ តាមរយៈយន្តការ និងនីតិវិធីដែលមានចែងក្នុងលិខិតូបករណ៍ទាំងនោះ ។

២, ចំពោះជម្លោះ ដែលមិនពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍តាមលិខិតតូបករណ៍អាស៊ានណាមួយ ត្រូវដោះស្រាយដោយសន្តិវិធី ដោយអនុលោមតាមសន្ធិសញ្ញាស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការ នៅអាស៊ីអាគ្នេយ៍ (TAC) និងវិធាននៃនីតិវិធីរបស់សន្ធិសញ្ញានេះ ។

៣. ប្រសិនបើមិនមានបញ្ញត្តិផ្សេងពីនេះទេ ជម្លោះដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន ត្រូវដោះស្រាយទៅតាមពិធីសារអាស៊ានស្តីពីយន្តការពង្រឹងការដោះស្រាយជម្លោះ ។

## មាត្រា ២៥
## អំពីការបង្កើតយន្តការដោះស្រាយជម្លោះ

ប្រសិនបើពុំមានការបញ្ញត្តិផ្ទុយពីនេះ យន្តការដោះស្រាយជម្លោះសមស្រប ដែលរួមទាំងមជ្ឈត្តវិនិច្ឆ័យនឹងត្រូវបង្កើតឡើង សម្រាប់ជម្លោះដែលពាក់ព័ន្ធដល់ការបកស្រាយ ឬការអនុវត្តន៍ធម្មនុញ្ញនេះ និងលិខិតូបករណ៍អាស៊ានដទៃទៀត ។

## មាត្រា ២៦
## អំពីជម្លោះដែលមិនអាចដោះស្រាយបាន

ក្នុងករណីដែលជម្លោះនៅតែពុំអាចដោះស្រាយបាន បន្ទាប់ពីបានអនុវត្តតាមបទប្បញ្ញត្តិ ដែលមានចែង ក្នុងបញ្ញត្តិខាងលើនៃជំពូកនេះ ជម្លោះនោះត្រូវដាក់ជូនកិច្ចប្រជុំកំពូលអាស៊ាន ដើម្បីធ្វើសេចក្តីសម្រេច ។

## មាត្រា ២៧
## អំពីការប្រតិបត្តិ

១. អគ្គលេខាធិការអាស៊ាន ដែលជួយជ្រោមជ្រែងពីលេខាធិការដ្ឋានអាស៊ាន ឬអង្គភាពអាស៊ាន ដែលមានការតែងតាំងណាមួយ ត្រូវត្រួតពិនិត្យការប្រតិបត្តិតាមកស្តុតាងជាក់ស្តែង អនុសាសន៍ ឬសេចក្តីសម្រេច ដែលចេញពីយន្តការដោះស្រាយជម្លោះអាស៊ាន ហើយត្រូវផ្តល់របាយការណ៍ នេះ ជូនកិច្ចប្រជុំកំពូលអាស៊ានជ្រាប ។

២. រដ្ឋសមាជិកណាមួយ ដែលរងផលប៉ះពាល់ដោយសារការមិនគោរពទៅតាមកស្តុតាងជាក់ស្តែង ឬអនុសាសន៍ ឬសេចក្តីសម្រេចចេញពីយន្តការដោះស្រាយជម្លោះអាស៊ាន អាចដាក់បញ្ហានេះ ជូនទៅកិច្ចប្រជុំកំពូលអាស៊ាន ដើម្បីធ្វើសេចក្តីសម្រេច ។

## មាត្រា ២៨
## អំពីបទប្បញ្ញត្តិធម្មនុញ្ញអង្គការសហប្រជាជាតិ និងនីតិវិធីអន្តរជាតិពាក់ព័ន្ធដទៃទៀត

ប្រសិនបើពុំមានចែងក្នុងធម្មនុញ្ញនេះទេ រដ្ឋសមាជិកមានសិទ្ធិប្រើប្រាស់វិធីដោះស្រាយជម្លោះដោយសន្តិវិធី ដូចមានចែងក្នុងមាត្រា ៣៣ (១) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឬលិខិតូបករណ៍គតិយុត្តអន្តរជាតិ ដទៃទៀត ដែលរដ្ឋសមាជិកគឺជាភាគី ។

# ជំពូកទី ៩
# ថវិកា និងហិរញ្ញវត្ថុ

## មាត្រា ២៩
## អំពីគោលការណ៍ទូទៅ

១. អាស៊ានត្រូវបង្កើតវិធានហិរញ្ញវត្ថុ និងនីតិវិធីដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ។

២. អាស៊ានត្រូវពិនិត្យមើលគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តន៍ និងបទបញ្ញាថវិកា ។

៣. គណនីហិរញ្ញវត្ថុត្រូវស្ថិតនៅក្រោមសវនកម្មផ្ទៃក្នុង និងមកពីខាងក្រៅ ។

## មាត្រា ៣០
## អំពីថវិកា និងហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការលេខាធិការដ្ឋានអាស៊ាន

១. លេខាធិការដ្ឋានអាស៊ាននឹងត្រូវបានផ្តល់ឱ្យនូវធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

២. ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានអាស៊ាន ត្រូវផ្គត់ផ្គង់ដោយរដ្ឋសមាជិកអាស៊ានតាមរយៈវិភាគទានប្រចាំឆ្នាំស្មើៗគ្នា និងត្រូវបង់ឱ្យទាន់ពេលវេលា ។

៣. អគ្គលេខាធិការត្រូវរៀបចំសំណើថវិកា សម្រាប់ប្រតិបត្តិការប្រចាំឆ្នាំរបស់លេខាធិការដ្ឋានអាស៊ាន ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ក្រោយពីទទួលបានអនុសាសន៍របស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ។

៤. លេខាធិការដ្ឋានអាស៊ានត្រូវប្រតិបត្តិតាមវិធាន និងនីតិវិធីហិរញ្ញវត្ថុ ដែលកំណត់ដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន តាមអនុសាសន៍របស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ។

# ជំពូកទី ១០
# រដ្ឋបាល និងនីតិវិធី

## មាត្រា ៣១
## អំពីប្រធានរបស់អាស៊ាន

១. ប្រធានរបស់អាស៊ានត្រូវប្តូរវេនជារៀងរាល់ឆ្នាំ តាមលំដាប់អក្ខរក្រមនៃឈ្មោះជាភាសាអង់គ្លេសរបស់រដ្ឋសមាជិក ។

២. សម្រាប់រយៈពេលពេញមួយឆ្នាំ អាស៊ានត្រូវមានប្រធានតែមួយ ។ រដ្ឋសមាជិកដែលទទួលឋានៈជាប្រធានអាស៊ានក្នុងឆ្នាំនោះត្រូវធ្វើជាប្រធាននៃ :

ក. កិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ

ខ. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

គ. ក្រុមប្រឹក្សាសហគមន៍អាស៊ានទាំងបី

ឃ. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកពាក់ព័ន្ធរបស់អាស៊ាន និងឧត្តមមន្ត្រីតាមកាលសមស្រប និង

ង. គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍របស់អាស៊ាន ។

## មាត្រា ៣២
## អំពីតួនាទីរបស់ប្រធានអាស៊ាន

រដ្ឋសមាជិក ដែលទទួលធ្វើជាប្រធានរបស់អាស៊ានត្រូវ :

ក. លើកស្ទួយយ៉ាងសកម្ម និងធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍ និងសុខុមាលភាពរបស់អាស៊ាន រួមទាំងការខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន តាមរយៈការផ្តួចផ្តើមគោលនយោបាយ ការសម្របសម្រួល កុងសង់ស៊ីស និងសហប្រតិបត្តិការ

ខ. ធានាភាពជាស្នូល (Centrality) របស់អាស៊ាន

គ. ធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេល ចំពោះបញ្ហាបន្ទាន់ ឬសភាពការណ៍ដែលមានវិបត្តិប៉ះពាល់ដល់អាស៊ាន រួមទាំងការផ្តល់ការជួយសម្រុះសម្រួល និងការរៀបចំផ្សេងៗទៀត ដើម្បីដោះស្រាយជាបន្ទាន់នូវបញ្ហាទាំងនេះ

ឃ. តំណាងឱ្យអាស៊ានក្នុងការពង្រឹង និងជំរុញទំនាក់ទំនងជិតស្និទ្ធជាមួយដៃគូក្រៅតំបន់ និង

ង. អនុវត្តនូវកិច្ចការ និងភារកិច្ចដទៃទៀត តាមអាណត្តិដែលទទួលបាន ។

## មាត្រា ៣៣
## អំពីពិធីការការទូត និងការអនុវត្តន៍

អាស៊ាន និងរដ្ឋសមាជិកត្រូវប្រកាន់ខ្ជាប់នូវពិធីការការទូតដែលមានស្រាប់ និងការប្រតិបត្តិក្នុងការរៀបចំសកម្មភាពដែលពាក់ព័ន្ធនឹងអាស៊ាន ។ រាល់ការផ្លាស់ប្តូរទាំងឡាយត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន តាមអនុសាសន៍របស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ។

## មាត្រា ៣៤
## អំពីភាសាប្រើប្រាស់ជាផ្លូវការក្នុងអាស៊ាន

ភាសាប្រើប្រាស់ជាផ្លូវការក្នុងអាស៊ានគឺ : ភាសាអង់គ្លេស ។

# ជំពូកទី ១១
# អត្តសញ្ញាណ និងនិមិត្តសញ្ញា

## មាត្រា ៣៥
## អំពីអត្តសញ្ញាណអាស៊ាន

អាស៊ានត្រូវលើកកម្ពស់អត្តសញ្ញាណរួមរបស់ខ្លួន និងក្នុងន័យជារបស់ប្រជាជន ដើម្បីធ្វើឱ្យសម្រេចនូវតម្លៃ គោលដៅ និងជោគវាសនារួមគ្នារបស់អាស៊ាន ។

## មាត្រា ៣៦
## អំពីបាវចនាអាស៊ាន

បាវចនាអាស៊ានគឺ : ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ ។

### មាត្រា ៣៧
### អំពីទង់អាស៊ាន

ទង់របស់អាស៊ានត្រូវមានទ្រង់ទ្រាយដូចបានបង្ហាញក្នុងឧបសម្ព័ន្ធទី ៣ ។

### មាត្រា ៣៨
### អំពីនិមិត្តសញ្ញារបស់អាស៊ាន

និមិត្តសញ្ញាអាស៊ានត្រូវមានទ្រង់ទ្រាយដូចបានបង្ហាញក្នុងឧបសម្ព័ន្ធទី ៤ ។

### មាត្រា ៣៩
### អំពីទិវាអាស៊ាន

ថ្ងៃទី ៨ ខែសីហា ត្រូវកំណត់ជាទិវាអាស៊ាន ។

### មាត្រា ៤០
### អំពីភ្លេងអាស៊ាន

អាស៊ានត្រូវមានភ្លេងរបស់ខ្លួន ។

## ជំពូកទី ១២
## ទំនាក់ទំនងក្រៅតំបន់

### មាត្រា ៤១
### អំពីការអនុវត្តន៍ទំនាក់ទំនងក្រៅតំបន់

១. អាស៊ានត្រូវអភិវឌ្ឍទំនាក់ទំនងជាមិត្តភាព និងកិច្ចសន្ទនាដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក ក្នុងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយបណ្តាប្រទេស និងអនុតំបន់ តំបន់ និងអង្គការអន្តរជាតិ និងស្ថាប័នដទៃទៀត ។

២. ទំនាក់ទំនងក្រៅតំបន់របស់អាស៊ានត្រូវប្រកាន់ខ្ជាប់នូវគោលបំណង និងគោលការណ៍ទាំងឡាយដែលមានចែងក្នុងធម្មនុញ្ញនេះ ។

៣. អាស៊ានត្រូវតែជាកម្លាំងនាំមុខជាចម្បងមួយ នៅក្នុងការរៀបចំតំបន់ ដែលខ្លួនផ្តួចផ្តើម និងរក្សាភាពជាស្នូលរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងការកសាងសហគមន៍ ។

៤. ក្នុងការអនុវត្តន៍ទំនាក់ទំនងក្រៅតំបន់អាស៊ាន រដ្ឋសមាជិកត្រូវសម្របសម្រួល និងខិតខំប្រឹងប្រែង អភិវឌ្ឍជំហររួម និងធ្វើសកម្មភាពរួមគ្នាលើមូលដ្ឋាននៃភាពឯកភាព និងសាមគ្គីភាព ។

៥. ទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រនៃទំនាក់ទំនងក្រៅតំបន់របស់អាស៊ាន ត្រូវដាក់ចេញដោយកិច្ចប្រជុំកំពូលអាស៊ាន តាមអនុសាសន៍របស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

៦. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ត្រូវធានាឱ្យមានភាពស្របគ្នា និងភាពរលូនក្នុងការអនុវត្តន៍ទំនាក់ទំនងក្រៅតំបន់របស់អាស៊ាន ។

៧. អាស៊ានអាចសម្រេចកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេស ឬអនុតំបន់ តំបន់ និងអង្គការអន្តរជាតិ និងស្ថាប័នទាំងឡាយបាន ។ នីតិវិធីនៃការសម្រេចកិច្ចព្រមព្រៀងនេះត្រូវបញ្ញត្តិដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសហគមន៍អាស៊ាន ។

## មាត្រា ៤២
## អំពីអ្នកសម្របសម្រួលប្រទេសដៃគូសន្ទនាអាស៊ាន

១. រដ្ឋសមាជិក ដែលដើរតួនាទីជាប្រទេសសម្របសម្រួល ត្រូវប្តូរវេនគ្នាទទួលខុសត្រូវទាំងស្រុងក្នុងការសម្របសម្រួល និងជំរុញផលប្រយោជន៍អាស៊ាន ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយដៃគូសន្ទនាពាក់ព័ន្ធ និងជាមួយអង្គការតំបន់ និងអន្តរជាតិ និងស្ថាប័នដទៃទៀត ។

២. ក្នុងទំនាក់ទំនងជាមួយដៃគូក្រៅតំបន់ ប្រទេសសម្របសម្រួលត្រូវ :

   ក. តំណាងអាស៊ាន និងលើកកម្ពស់ទំនាក់ទំនង ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក និងសមភាព ស្របទៅតាមគោលការណ៍របស់អាស៊ាន

   ខ. ធ្វើជាសហប្រធានកិច្ចប្រជុំពាក់ព័ន្ធរវាងអាស៊ាន និងដៃគូក្រៅតំបន់ និង

   គ. គាំទ្រដោយគណៈកម្មាធិការអាស៊ានពាក់ពន្ធ័នានាទៅក្នុងប្រទេសទីបី និងនៅអង្គការអន្តជាតិនានា ។

## មាត្រា ៤៣
## អំពីគណៈកម្មាធិការអាស៊ានក្នុងប្រទេសទីបី និងអង្គការអន្តរជាតិ

១. គណៈកម្មាធិការអាស៊ានក្នុងប្រទេសទីបី អាចត្រូវបង្កើតឡើងនៅក្នុងប្រទេសពុំមែនជាសមាជិកអាស៊ាន ដែលក្នុងនោះ មានប្រធានបេសកកម្មការទូតនៃរដ្ឋសមាជិកអាស៊ាន ។ គណៈកម្មាធិការស្រដៀងគ្នានេះក៏អាចនឹងត្រូវបង្កើតឡើងដោយទាក់ទងទៅនឹងអង្គការអន្តរជាតិ ។ គណៈ-

កម្មាធិការនេះត្រូវលើកស្ទួយផលប្រយោជន៍ និងអត្តសញ្ញាណអាស៊ាននៅក្នុងប្រទេសម្ចាស់ផ្ទះ និងអង្គការអន្តរជាតិ ។

២. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានត្រូវកំណត់អំពីវិធាននីតិវិធីរបស់គណៈកម្មាធិការនេះ ។

## មាត្រា ៤៤
## អំពីលក្ខន្តិកៈរបស់ភាគីក្រៅតំបន់

១. ក្នុងការអនុវត្តន៍ទំនាក់ទំនងក្រៅតំបន់ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានអាចផ្តល់ដល់ភាគីក្រៅតំបន់នូវឋានៈផ្លូវការជាដៃគូសន្ទនា ជាដៃគូសន្ទនាតាមផ្នែក ជាដៃគូអភិវឌ្ឍន៍ ជាអ្នកសង្កេតការពិសេស ជាភ្ញៀវ ឬអាចផ្តល់នូវឋានៈផ្សេងទៀតដែលអាចបង្កើតឡើងពីនេះតទៅ ។

២. ដោយអនុលោមទៅតាមវិធាននៃនីតិវិធី ភាគីក្រៅតំបន់អាចនឹងត្រូវអញ្ជើញឱ្យចូលរួមកិច្ចប្រជុំអាស៊ាននានា ឬក្នុងសកម្មភាពសហប្រតិបត្តិការផ្សេងៗ ដោយពុំចាំបាច់ផ្តល់នូវឋានៈផ្លូវការណាមួយឡើយ ។

## មាត្រា ៤៥
## អំពីទំនាក់ទំនងជាមួយប្រព័ន្ធនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ និងស្ថាប័នដទៃទៀត

១. អាស៊ានអាចស្វែងរកឋានៈសមស្របណាមួយជាមួយនឹងប្រព័ន្ធអង្គការសហប្រជាជាតិ ក៏ដូចជាមួយនឹងអង្គការអន្តរជាតិ អង្គការតំបន់ អនុតំបន់ និងស្ថាប័នដទៃទៀត ។

២. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវសម្រេចអំពីការចូលរួមរបស់អាស៊ានក្នុងអង្គការអន្តរជាតិ ក្នុងអង្គការតំបន់ ក្នុងអង្គការអនុតំបន់ និងស្ថាប័នដទៃទៀត ។

## មាត្រា ៤៦
## អំពីការទទួលស្គាល់រដ្ឋដែលពុំមែនជាសមាជិកអាស៊ានឱ្យប្រចាំនៅអាស៊ាន

រដ្ឋដែលពុំមែនជាសមាជិកអាស៊ាន និងអង្គការអន្តររដ្ឋាភិបាលពាក់ព័ន្ធ អាចតែងតាំងអគ្គរដ្ឋទូត/រាជទូតឱ្យប្រចាំនៅអាស៊ានបាន ។ ការទទួលស្គាល់នូវការតែងតាំងនេះ ត្រូវសម្រេចដោយកិច្ចប្រជុំនៃរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

# ជំពូកទី ១៣
# បទប្បញ្ញត្តិទូទៅ និងអវសានប្បញ្ញត្តិ

## មាត្រា ៤៧
## អំពីការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការតម្កល់ឯកសារ និងការចូលជាធរមាន

១. ធម្មនុញ្ញអាស៊ាននេះត្រូវចុះហត្ថលេខាដោយរដ្ឋសមាជិកអាស៊ានទាំងអស់ ។

២. ធម្មនុញ្ញនេះត្រូវផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំងអស់ ដោយអនុលោមតាមនីតិវិធីផ្ទៃក្នុងរបស់រដ្ឋសមាជិកនីមួយៗ ។

៣. រាល់លិខិតូបករណ៍សច្ចាប័នត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ហើយត្រូវជូនដំណឹងនេះជាបន្ទាន់ទៅរដ្ឋជាសមាជិកទាំងអស់ស្តីពីការតម្កល់ទុកនេះ ។

៤. ធម្មនុញ្ញនេះត្រូវចូលជាធរមាននៅកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់ទុកលិខិតូបករណ៍សច្ចាប័នទីដប់ ជាមួយអគ្គលេខាធិការអាស៊ាន ។

## មាត្រា ៤៨
## អំពីការធ្វើវិសោធនកម្ម

១. រដ្ឋសមាជិកអាស៊ាននីមួយៗ មានសិទ្ធិស្នើសុំធ្វើវិសោធនកម្មធម្មនុញ្ញនេះបាន ។

២. ការស្នើសុំធ្វើវិសោធនកម្មធម្មនុញ្ញនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាសម្របសម្រួលអាស៊ានសម្រេចដោយកុងសង់ស៊ីស ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលអាស៊ានធ្វើសេចក្តីសម្រេច ។

៣. ការធ្វើវិសោធនកម្មធម្មនុញ្ញ ដែលបានឯកភាពដោយកុងសង់ស៊ីសដោយកិច្ចប្រជុំកំពូលអាស៊ានចាំបាច់ត្រូវផ្តល់សច្ចាប័នពីរដ្ឋសមាជិកទាំងអស់ ដោយអនុលោមតាមមាត្រា ៤៧ ។

៤. វិសោធនកម្មត្រូវចូលជាធរមានរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់ទុកលិខិតូបករណ៍សច្ចាប័នចុងក្រោយជាមួយអគ្គលេខាធិការអាស៊ាន ។

## មាត្រា ៤៩
## អំពីឯកសារគោល និងវិធាននៃនីតិវិធី

ប្រសិនបើពុំមានចែងច្បាស់លាស់នៅក្នុងធម្មនុញ្ញនេះទេ ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវកំណត់ និងធានាឱ្យឯកសារគោល និងវិធាននៃនីតិវិធីមានភាពស្របគ្នា ។

## មាត្រា ៥០
## ការពិនិត្យឡើងវិញ

ធម្មនុញ្ញនេះអាចនឹងត្រូវពិនិត្យឡើងវិញក្នុងរយៈពេល ៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាន ឬក៏អាចពិនិត្យឡើងវិញ ក្នុងរយៈពេលណាមួយទៀត តាមការកំណត់របស់កិច្ចប្រជុំកំពូលអាស៊ាន ។

## មាត្រា ៥១
## ការបកស្រាយធម្មនុញ្ញអាស៊ាន

១. បន្ទាប់ពីទទួលបានសំណើរបស់រដ្ឋសមាជិកណាមួយ ការបកស្រាយធម្មនុញ្ញត្រូវធ្វើឡើង ដោយលេខាធិការដ្ឋានអាស៊ាន ដោយអនុលោមតាមវិធាននៃនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

២. រាល់ទំនាស់ ដែលកើតឡើងពីការបកស្រាយធម្មនុញ្ញនេះត្រូវដោះស្រាយ តាមរយៈបទប្បញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងជំពូកទី ៨ នៃធម្មនុញ្ញនេះ ។

៣. ចំណងជើង ដែលប្រើប្រាស់ក្នុងធម្មនុញ្ញនេះមានគោលបំណងតែមួយគត់ គឺសម្រាប់ជាឯកសារយោង ។

## មាត្រា ៥២
## អំពីភាពបន្តនៃច្បាប់

១. រាល់សន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង កិច្ចស្រុះស្រួលគ្នា (Concord) សេចក្តីថ្លែងការណ៍ ពិធីសារ និងលិខិតូបករណ៍ផ្សេងៗរបស់អាស៊ាន ដែលមានតាំងពីមុនការចូលជាធរមាននៃធម្មនុញ្ញនេះនៅតែបន្តមានសុពលភាព ។

២. ត្រូវយកធម្មនុញ្ញអាស៊ានជាគោល ក្នុងករណីមានភាពមិនស្របគ្នារវាងសិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋសមាជិកអាស៊ាន ដែលមានចែងក្នុងលិខិតូបករណ៍ខាងលើជាមួយនឹងធម្មនុញ្ញនេះ ។

**THE ASEAN DECLARATION (BANGKOK DECLARATION)**
**BANGKOK, 8 AGUSTUS 1967**

The Presidium Minister for Political Affairs/Minister for Foreign Affairs of Indonesia, the Deputy Prime Minister of Malaysia, the Secretary of Foreign Affairs of the Philippines, the Minister for Foreign Affairs of Singapore and the Minister of Foreign Affairs of Thailand:

**MINDFUL** of the existence of mutual interest and common problems among countries of South-East Asia and convinced of the need to strengthen further the existing bonds of regional solidarity and cooperation;

**DESIRING** to establish a firm foundation for common action to promote regional cooperation in South-East Asia in the spirit of equality and partnership and thereby contribute towards peace, progress and prosperity in the region;

**CONSCIOUS** that in an increasingly interdependent world, the cherished ideals of peace, freedom, social justice and economic well-being are best attained by fostering good understanding good neighbourliness and meaningful cooperation among the countries of the region already bound together by ties of history and culture;

**CONSIDERING** that the countries of South-East Asia share a primary responsibility for strengthening the economic and social stability of the region and ensuring their peaceful and progressive national development, and that they are determined to ensure their stability and security from external interference in any form or manifestation in order to preserve their national identities in accordance with the ideals and aspirations of their peoples;

**AFFIRMING** that all foreign bases are temporary and remain only with the expressed concurrence of the countries concerned and are not intended to be used directly or indirectly to subvert the national independence and freedom of States in the ares or prejudice the orderly processes of their national development;

**DO HEREBY DECLARE:**

**FIRST,** the establishment of an Association for Regional Cooperation among the countries of South-East Asia to be known as the Association of South-East Asian Nations (ASEAN).

**SECOND,** that the aims and purposes of the Association shall be:

1. To accelerate the economic growth, social progress and cultural development in the region through joint endeavours in the spirit of equality and partnership in order to strengthen the foundation for a prosperous and peaceful community of South-East Asian Nations;

2. To promote regional peace and stability through abiding respect for justice and the rule of law in the relationship among countries of the region and adherence to the principles of the United Nations Charter;

3. To promote active collaboration and mutual assistance on matters of common interest in the economic, social, cultural, technical, scientific and administratif fields;

4. To provide assistance to each other in the form of training and research facilities in the educational, professional, technical and administrative spheres;

5. To collaborate more effectively for the greater utilization of their agriculture and industries, the expansion of their trade, including the study of the problems of international commodity trade, the improvement of their transportation and communication facilities and the raising of the living standards of their peoples;

6. To promote South-East Asian studies;

7. To maintain close and beneficial cooperation with existing international and regional organizations with similar aims and purposes, and explore all avenues for even closer cooperation among themselves.

**THIRD,** that to carry out these aims and purposes, the following machinery shall be established:

(a) Annual Meeting of Foreign Ministers, which shall be by rotation and referred to as ASEAN Ministerial Meeting Special Meetings of Foreign Ministers may be convened as required.

(b) A Standing Committee, under the chairmanship of the Foreign Minister of the host country or his representative and having as its members the accredited Ambassadors of the other member countries, to carry on the work of the Association in between Meetings of Foreign Ministers.

(c) Ad-Hoc Committees and Permanent Committees of specialist and officials on specific subjects.

(d) A National Secretariat in each member country to carry out the work of the Association on behalf of that country and to service the Annual or Special Meetings of Foreign Ministers, the Standing Committee and such other committees as may hereafter be established.

**FOURTH,** that the Association is open for participation to all States in the South-East Asian Region subscribing to the aforementioned aims, principles and purposes.

**FIFTH,** that the Association represent the collective will of the nations of South-East Asia to bind themselves together in friendship and cooperation and, through joint efforts and sacrifices, secure for their peoples and for posterity the blessings of peace, freedom and prosperity.

**DONE** in Bangkok on the Eighth Day of August in the Year One Thousand Nine Hundred and Sixty-Seven.

**FOR THE REPUBLIC OF INDONESIA**

**ADAM MALIK**
**Presidium Minister for Political Affairs/**
**Minister for Foreign Affairs**

**FOR MALAYSIA**

**TUN ABDUL RAZAK**
**Deputy Prime Minister,**
**Minister of Defence and**
**Minister of National Development**

**FOR THE REPUBLIC OF THE PHILIPPINES**

**NARSISCO RAMOS**
**Secretary of Foreign Affairs**

**FOR THE REPUBLIC OF SINGAPORE**

**S. RAJARATNAM**
**Minister of Foreign Affairs**

**FOR THE KINGDOM OF THAILAND**

**THANAT KHOMAN**
**Minister of Foreign Affairs**

Copy naskah resmi
Certified true Copy

Direktur Perjanjian Internasional
Departemen Luar Negeri
Director, Legal and treaties Affairs
Department of Foreign Affairs.

P.I